ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០៩**

**សវនាការលើកទី៦៧**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន
លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍
*(Judge Silvia Carwright)*
លោក យ៉ា សុខន
លោក ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc Lavegne)*
លោក ធូ មណី
លោក យូរ ឧត្តរា
លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី
លោក ឌុច ផារី
កញ្ញា ណាតាចា វ៉ីសែល រីសឺ
*(Ms. Natacha Wexels-Riser)*
លោក ម៉ាត្ធូ គ្រីស្ពារ *(Mr. Matteo Crippa)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក តាន់ សេណារ៉ុង
លោក អានីស អះម៉េដ *(Mr.Anees AHMED)*
លោក ប៉ាក ច័ន្ទលីណូ

**ជនជាប់ចោទ៖**

លោក កាំង ហ្កេកអ៊ាវ

**មេធាវីការពារជនជាប់ចោទ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ *(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

កញ្ញា ទី ស្រ៊ុនណា

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Christine MARTINEAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# ឧបសម្ព័ន្ធ

## សាក្សីជំនាញ

### លោក វេជ្ជ. កា ស៊ុនបុណ្ណាត និង វេជ្ជ. ហ្វ្រង់ស័រ ស៊ីរ៉ូនី ឡឿលបុ

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី ........................................ ទំព័រ ៥
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី ........................................ ទំព័រ ២៥
សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ ផ្ដើមពី ........................................ ទំព័រ ៤៤
សួរដោយលោក តាន់ សេណារ៉ុង ផ្ដើមពី ........................................ ទំព័រ ៤៩
សួរដោយលោក អានីស អះមេដ ផ្ដើមពី ........................................ ទំព័រ ៥៧
សួរដោយលោក ការ សាវុត្ថ ផ្ដើមពី ........................................ ទំព័រ ៧៣

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោក អានីស អះមេដ | អង់គ្លេស |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោកស្រី គ្រីស្ទីន ម៉ាទីណូ | បារាំង |
| លោក ការ សាវុត្ថ | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ | បារាំង |
| លោក ហ្វ្រង់ស្វ័រ រូ | បារាំង |
| លោក តាន់ សេណារ៉ុង | ខ្មែរ |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោក អាឡាំង វែនណឺ | បារាំង |
| កញ្ញា ទី ស្រ៊ីនណា | ខ្មែរ |
| លោកស្រី វេជ្ជ. ហ្វ្រង់ស័រ ស៊ីរ៉ូនី ហ្គៀលបូ | បារាំង |
| លោក វេជ្ជ. កា ស៊ុនបូណាត | ខ្មែរ |

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលមកក្នុងបន្ទប់សវនាការ)*

[០៩:០៨:៤០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ ។ នៅព្រឹកនេះ អង្គជំនុំជម្រះ ស្តាប់នូវបទបង្ហាញរបស់អ្នកជំនាញចិត្តសាស្ត្រចំនួនពីររូប គឺលោកស្រី ហ្វ្រង់ស័រ ស៊ីរ៉ូនី ហ្កៀលបូ និង សាស្ត្រាចារ្យ កាស៊ុន បូណាត តាមកាលវិភាគដែលបានគ្រោងទុក ។

ហើយមុននឹងឈានចូលដល់ដំណើរនៃការស្តាប់ នូវបទបង្ហាញរបស់អ្នកជំនាញ ក្រឡាបញ្ជីឡើង រាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគី និងបុគ្គល ដែលត្រូវអញ្ជើញចូលរួមនៅក្នុងកិច្ច ដំណើរការនីតិវិធីសវនាការសម្រាប់ថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន ។ ភាគីដែលត្រូវចូលរួមនៅក្នុងកិច្ចដំណើរការនីតិវធីសវនាការ ក្នុងថ្ងៃ នេះមានវត្តមានគ្រប់ចំនួន លើកលែងតែមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទីពីរ និងក្រុមទីបី និងក្រុមទីបួនអវត្តមាន ។ ក្នុងថ្ងៃនេះមេធាវីអន្តរជាតិ តំណាងដើមបណ្តឹងរដ្ឋប្បវេណីក្រុមទីបី លោកស្រី គ្រីស្ទីន ម៉ាទីណូ ទើបតែមានវត្តមាននៅក្នុងថ្ងៃនេះ ។ អ្នកជំនាញពីររូបដែលត្រូវមកផ្តល់សក្ខីកម្មនៅ ក្នុងថ្ងៃនេះ លោកវេជ្ជបណ្ឌិត កា ស៊ុនបូណាត និងលោកស្រី ហ្វ្រង់ស័រ ស៊ីរ៉ូនី ហ្កៀលបូ មានវត្តមាន រង់ចាំការកោះហៅពីអង្គជំនុំជម្រះ ។ អ្នកជំនាញទាំងពីររូបនេះ មិនមានចំណងញាតិលោហិត ឬញាតិ ពន្ធជានឹងមួយជនជាប់ចោទ ឬភាគីដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។ អ្នកជំនាញនឹងត្រូវមកធ្វើសម្បថ នៅចំពោះមុខអង្គជំនុំជម្រះ ។

[០៩:១១:២១]

**ប្រធានអង្គជំនុំ៖**

នៅថ្ងៃនេះ ដោយមានមេធាវីអន្តរជាតិថ្មីមួយរូប ដែលបានធ្វើសម្បថរួចហើយ ប៉ុន្តែមិនទាន់បាន ធ្វើការប្រកាសទទួលស្គាល់នៅចំពោះមុខអង្គជំនុំជម្រះ ។ ដូច្នេះ អង្គជំនុំជម្រះដំណើរការនីតិវិធីនៃការ បង្ហាញខ្លួន និងប្រកាសទទួលស្គាល់ពីអង្គជំនុំជម្រះ នៅចំពោះមុខអង្គជំនុំជម្រះ ។ ដោយមុនចាប់ផ្តើម ដំណើរការនីតិវិធី ដោយអនុលោមតាមវិធាន ២៣.៧(ង) ចំណុច(១) នៃវិធានផ្ទៃក្នុងអង្គជំនុំជម្រះ

សាលាដំបូងសូមអញ្ជើញមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី-- មេធាវីជាតិតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី ឡើងធ្វើការស្នើសុំការទទួលស្គាល់មេធាវីអន្តរជាតិ ដែលមិនទាន់បានស្នើសុំទទួលស្គាល់ពីអង្គជំនុំជម្រះសាលាដំបូងកន្លងមកនៅឡើយ ។ សូមអញ្ជើញ ។

[០៩:១២:២៤]

**កញ្ញា ទី ស្រ៊ុនណា៖**

សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម! ដោយសារតែមេធាវីជាតិនៅក្នុងក្រុមមួយគាត់អវត្តមាន ដូច្នេះនាងខ្ញុំជាមេធាវីក្រុមទីមួយ-- មេធាវីក្រុមបីគាត់អវត្តមាន អ៊ីចឹងនាងខ្ញុំសូមធ្វើការស្នើសុំទទួលស្គាល់ជំនួស ដោយធ្វើជាតំណាង តើលោកប្រធានអនុញ្ញាតទេ? ប្រសិនបើអនុញ្ញាតនាងនឹងខ្ញុំនឹងធ្វើការស្នើសុំទទួលស្គាល់ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ ។

**កញ្ញា ទី ស្រ៊ុនណា៖**

សូមអរគុណ ។ ជាបឋម នាងខ្ញុំសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រមជាតិ និងអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញនៃតុលាការកម្ពុជា ។ នាងខ្ញុំឈ្មោះ ទី ស្រ៊ុនណា ជាមេធាវីជាតិប្រចាំក្រុមមួយ និងជាតំណាងឲ្យមេធាវីជាតិក្រុមបី សូមស្នើ-- ស្នើសុំលោក លោកស្រី លោកប្រធាន លោក លោកស្រីចៅក្រម មេត្តាទទួលស្គាល់លោកស្រី គ្រីស្ទីន ម៉ាទីណូ ជាមេធាវីនៃគណៈទីក្រុងប៉ារីសប្រទេសបារាំង ដែលបានស្បថនៅចំពោះមុខសាលាឧទ្ធរណ៍នៃព្រះរាជាណាចក្រកម្ពុជាកាលពីខែ១២ ឆ្នាំ ២០០៨ ជាមេធាវីអន្តរជាតិប្រចាំក្រុមទីបី ចាប់ពីពេលនេះតទៅ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

លោកស្រី គ្រីស្ទីន ម៉ាទីណូ អង្គជំនុំជម្រះសាលាដំបូង ទទួលលោកស្រីធ្វើជាមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបី សម្រាប់គោលបំណងនៃកិច្ចដំណើរការនីតិវិធីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនេះ ។ ដោយយោងទៅតាមការទទួលស្គាល់នេះ លោកស្រីមានសិទ្ធិនិងបុព្វសិទ្ធិដូចគ្នា នឹងមេធាវីជាតិដែរ ។ សូមអញ្ជើញអង្គុយចុះ ។

អញ្ជើញមេធាវី អាឡាំង វ៉ែនណឺ ។

[០៩:១៤:៤១]

**លោក អាឡាំង វែនណឺ៖**

សូមអរគុណលោកប្រធាន ។ សូមជម្រាបសួរលោក លោកស្រីចៅក្រម ។ ដូចដែលលោកចៅក្រម លោកស្រីចៅក្រមជ្រាបហើយ ដើមបណ្តឹងរដ្ឋប្បវេណីចំពោះវត្តមាន ដើមបណ្តឹងរដ្ឋប្បវេណីប្រាំខែកន្លងមកហ្នឹង ហើយក៏យើងរំពឹងផងដែរថា គេនឹងចូលរួមសប្តាហ៍នេះ ។ ប៉ុន្តែ ដោយផ្ទាល់នោះគេបានសម្រេចចិត្តថា មិនចូលរួមទេក្នុងសប្តាហ៍នេះ ថ្ងៃច័ន្ទ ថ្ងៃអង្គារ៍ និងថ្ងៃពុធ ។ ហើយសូមឲ្យយើងខ្ញុំជម្រាបដល់អង្គជំនុំជម្រះ ថាកាយវិការរបស់គេនោះ គឺមានការពាក់ព័ន្ធដោយផ្ទាល់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះថ្ងៃទី២៧ ខែសីហា ដែលមិនអនុញ្ញាតឲ្យពួកគេតាំងសំណួរទៅអ្នកជំនាញ ហើយនិងសាក្សីមួយចំនួនដែលគេចង់ពន្យល់សួរនោះ ។

ចំពោះកូនក្តីរបស់យើងមួយចំនួន ដែលជាកូនក្តីរបស់យើង-- ។ ខ្ញុំសូមឲ្យអង្គជំនុំជម្រះមេត្តាបញ្ជាក់ពីមូលហេតុ និងសេចក្តីសំអាងហេតុនៃការសម្រេចរបស់អង្គជំនុំជម្រះ ។ ហើយពួកគេក៏សូមឲ្យយើងខ្ញុំជម្រាបអង្គជំនុំជម្រះផងដែរ គេនឹងសម្តែងមតិរបស់គេនៅខាងក្រៅតុលាការនេះ ហើយពួកគេនិងបញ្ជូនលិខិតចំហាមកជូនអង្គជំនុំជម្រះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី អាឡាំង វ៉ែនណឺ ដែលមេធាវីអន្តរជាតិតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមមួយដែលបានផ្តល់យោបល់អំពីបញ្ហានេះ ។ ហើយមុនឹងអញ្ជើញអ្នកជំនាញចូលមកកាន់សវនាការអង្គជំនុំជម្រះ សូមជម្រាបជូនដំណឹងដល់ភាគី និងសាធារណជនបានជ្រាបអំពីកាលវិភាគនៃដំណើរការសវនាការរបស់អង្គជំនុំជម្រះ ដែលគ្រោងធ្វើនៅថ្ងៃបន្តបន្ទាប់ ។

នៅថ្ងៃនេះអង្គជំនុំជម្រះនឹងស្តាប់នៅបទបង្ហាញរបស់អ្នកជំនាញចំនួនពីររូប ដែលនឹងផ្តល់សក្ខីកម្មរួមគ្នា ហើយដំបូងអ្នកជំនាញទាំងពីរនឹងសង្ខេបនូវរបាយាការណ៍របស់គាត់ ដែលបានធ្វើនៅក្នុងដំណាក់កាលស៊ើបអង្កេត ។ បន្ទាប់មកនឹងធ្វើបច្ចុប្បន្នភាពនៃរបាយការណ៍របស់គាត់។ បន្ទាប់មកទៀតសំណួរដល់អ្នកជំនាញទាំងពីរចាប់ផ្តើម ដូចដែលបានចង្អុលបង្ហាញនៅក្នុងតារាង ដែលភ្ជាប់មកជាមួយ ។

ដោយសារកាលវិភាគនៃសវនាការបានកំណត់ច្បាស់លាស់ អង្គជំនុំជម្រះបានសម្រេចថានឹងស្តាប់សក្ខីកម្មរបស់សាក្សី D1, D2, D3, D4, D5 និង D6 ដូចដែលបានគ្រោងកោះហៅសម្រាប់សប្តាហ៍រួចមកហើយ បន្ទាប់ពីផ្តល់សក្ខីកម្មរបស់អ្នកជំនាញទាំងពីររូប ។

ប្រសិនបើការផ្តល់សក្ខីកម្ម ដែលបានគ្រោងរួចហើយសម្រាប់សប្តាហ៍ក្រោយបញ្ចប់មុនពេល

កំណត់ អង្គជំនុំជម្រះនឹងបន្តសួរសំណួរដល់ជនជាប់ចោទ ទាក់ទងទៅនឹងអត្តចរិតរបស់គាត់ ។

[០៩:១៨:៣៦]

ប្រសិនបើមានពេលសហព្រះរាជអាជ្ញា និងមេធាវីការពារក្តី អាចសួរសំណួរដល់ជនជាប់ចោទ ទាក់ទងទៅនឹងអត្តចរិតរបស់គាត់បាននៅពេលនោះ ។ នៅថ្ងៃទី១៤,១៥ ខែកញ្ញា ឆ្នាំ២០០៩ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មរបស់អ្នកជំនាញ និងសាក្សី រីឆាត ហ្គោលស្តូន, រ៉ាអ៊ូល ម៉ាកចេនណា, គ្រីស្តូហ្វ័រ ឡាប៉ែល D8 និងស្តេហ្វេន ហាស់សែល នៅថ្ងៃទី១៦ ខែកញ្ញា គឺពេញមួយថ្ងៃ និងនៅថ្ងៃទី១៧ ខែកញ្ញា សម្រាប់ពេលព្រឹកអង្គជំនុំជម្រះ សហព្រះរាជអាជ្ញា និងមេធាវីការពារក្តី ប្រសិនបើមានពេលគ្រប់គ្រាន់ នឹងបញ្ចប់ការសួរសំណួរដល់ជនជាប់ចោទ អំពីអត្តចរិតរបស់គាត់ ។ ហើយបន្ទាប់មកអង្គជំនុំជម្រះនឹងពិភាក្សាបញ្ហាអំពីដំណើរការនីតិវិធីដូចជា ការដាក់ឯកសារនៅចំពោះមុខអង្គជំនុំជម្រះ ផ្អែកតាមវិធាន ៨៧ ។ ប្រសិនបើសវនាការមិនអាចបញ្ចប់ តាមកាលវិភាគដែលបានគ្រោងទុក សវនាការនឹងលើកបន្តនៅថ្ងៃទី២២ ខែកញ្ញា ឬចាំបាច់ត្រូវបន្តរហូតដល់ថ្ងៃទី២៣ ខែកញ្ញា ។

នេះជាកាលវិភាគថ្មី ដែលមានការសម្រេចចុងក្រោយ នៃដំណើរការពិភាក្សាដេញដោលរបស់យើង ។ សូមអញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

[០៩:២០:១២]

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ មេធាវីការពារសូមរំឭកជូនអង្គជំនុំជម្រះថា អ្នកជំនាញដែលបានកំណត់កាលវិភាគ លោក ហិនរី យើង នោះ ជាអកុសលនោះគាត់បានទទួលមរណភាពទៅហើយ ។ ប៉ុន្តែគាត់បានរៀបចំជាឯកសារលាយលក្ខណ៍អក្សរ ។ ដូច្នេះ មេធាវីការពារសូមអនុញ្ញាតអង្គជំនុំជម្រះដើម្បីអាននូវសេចក្តីថ្លែងការណ៍របស់គាត់ ជាសេចក្តីថ្លែងការណ៍របស់សាស្ត្រាចារ្យ ហិនរី យើង ។

យើងខ្ញុំសូមឲ្យអង្គជំនុំជម្រះទទួលធ្វើការងារនេះ ក្នុងពេលដែលសាក្សីរបស់មេធាវីការពារ ត្រូវបានកោះមកផ្តល់សក្ខីកម្ម ។ ដូច្នេះ នៅពេលដែលយើងចោទសួរសាក្សីទាំងនោះ អង្គជំនុំជម្រះនឹងត្រូវប្រើនូវសេចក្តីដកស្រង់ នៅក្នុងសវនាការ *អុបរាណូវិច* ក្នុងរឿងក្តី *អុបរាណូវិច* នៅក្នុង *អាយធីស៊ីអ* ដែលគាត់បានរៀបចំ ដែលសេចក្តីដកស្រង់របស់អ្នកជំនាញនេះ ដែលបានផ្តល់មកឲ្យភាគី ។

ដូចគ្នានេះដែរ លោកប្រធាន ហើយនិងលោក លោកស្រីចៅក្រម មេធាវីការពារសូមគោរពស្នើជូនអង្គជំនុំជម្រះថា ទាក់ទងនឹងសាក្សីទាំងអស់នេះ សាក្សីដែលនិយាយអំពីអត្តចរិតនោះ យើងអនុញ្ញាត

ឲ្យសាក្សីមួយរូបៗ ដើម្បីសម្តែងអំពីសេចក្តីថ្លែងការណ៍ព្រមគ្នា មុនពេលនឹងយើងសួរសំណួរទៅគាត់ យើងចាត់ទុកថា ការធ្វើបែបនេះនឹងធ្វើឲ្យមានភាពរលូន ហើយអនុញ្ញាតឲ្យយើងធ្វើដំណើរការទៅមុខបានលឿននៅក្នុងការថ្លែងរបស់ពួកគាត់ ។

ចំណុចចុងក្រោយមួយទៀត យើងបានដឹងអំពីកាលវិភាគ ដែលលោកប្រធានទើបតែបានប្រកាសនេះ គឺថាដល់ពេលនេះ ខ្ញុំសូមជម្រាបជូនអង្គជំនុំជម្រះថា យើងអាចនឹងប្រឈមមុខនឹងការលំបាកមួយចំនួនទាក់ទងនឹងពេលវេលាដែលបានកំនត់ឲ្យលោក វ៉ាអ៊ីល មាកចេនណា ប៉ុន្តែពេលនេះខ្ញុំសូមរំឭកអង្គជំនុំជម្រះថា ដើម្បីផ្តល់ពេលបន្ថែមខ្លះទៀត សម្រាប់លោក វាអ៊ីល មាកចេនណា ។ ដូចដែលលោកប្រធានជ្រាបហើយ គឺថាសហព្រះរាជអាជ្ញាបានលើកឡើងអ្នកជំនាញមក គឺថាបានធ្វើការផ្តល់សក្ខីកម្មហ្នឹង គឺជាងពីរថ្ងៃ ដូចជាលោក គ្រេក អេតឆេសាន់ ជាដើម ។

អ៊ីចឹងហើយយើងខ្ញុំក៏ចង់ឲ្យអ្នកជំនាញដែលស្នើឡើងដោយមេធាវីការពារ នឹងបានពេលច្រើនគួរសមដែរ ។ អ៊ីចឹង ប្រសិនជាអាចធ្វើទៅបានយើងសូមស្នើពីរម៉ោង ម្ភៃនាទី អ៊ីចឹង លោក ចេនណា មិនប្រើពេលពីរថ្ងៃនោះទេ ប៉ុន្តែគាត់ត្រូវការពេលពីរម៉ោង ហើយនិងម្ភៃនាទី ។

នេះជាសេចក្តីស្នើសុំរបស់មេធាវីការពារ ដែលខ្ញុំសូមជូនឲ្យអង្គជំនុំជម្រះមេត្តាសម្រេច ដោយក្តីអនុគ្រោះ ។ សូមអរគុណ ។

[០៩:២៤:០៣]

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តមន្ត្រីតុលាការ អញ្ជើញអ្នកជំនាញទាំងពីររូប ជាតិមួយរូប និងអន្តរជាតិមួយរូប ចូលមកកាន់សាលសវនាការ ។

*(លោកវេជ្ជ. កា ស៊ុនបូណាត និង លោកស្រីវេជ្ជ. ស៊ីរ៉ូនី ហ្គៀលបូ ចូលក្នុងបន្ទប់សវនាការ)*

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

អរុណសួស្តី លោក លោកស្រី អ្នកជំនាញ ។ ជាដំបូងនេះ អង្គជំនុំជម្រះសូមសួរទៅអ្នកជំនាញ

ជាតិជាមុនទាក់ទិនជាមួយនឹងសារតារ ហើយនិងភាពពាក់ព័ន្ធទៅនឹងនីតិវិធី ។

**ស៖** លោកអ្នកជំនាញ តើនាមត្រកូល និងនាមខ្លួន របស់លោកនៃអ្នកជំនាញជាតិ កាស៊ុន បូណាត អ៊ីចឹងពិតមែនដែរឬទេ?

**លោក វេជ្ជ. កា ស៊ុនបូណាត៖**

**ឆ៖** ពិតមែនហើយបាទ ។

**ស៖** លោក កា ស៊ុនបូណាត តើលោកមានអាយុប៉ុន្មានឆ្នាំ?

**ឆ៖** ខ្ញុំមានអាយុ៥៦ឆ្នាំ ។

**ស៖** តើលោកមានមុខរបរធ្វើអ្វីសព្វថ្ងៃ?

**ឆ៖** ខ្ញុំជាវេជ្ជបណ្ឌិត ឯកទេសខាងវិកលវិទ្យា និងជាព្រឹទ្ធបុរសនៃមហាវិទ្យាល័យវេជ្ជសាស្ត្រ។

[០៩:២៦:៣៣]

**ស៖** លោក កា ស៊ុនបូណាត តើលោកមានទីលំនៅបច្ចុប្បន្ននេះ នៅទីកន្លែងណា?

**ឆ៖** ផ្ទះរបស់ខ្ញុំនៅផ្ទះលេខ១៨អា ផ្លូវ១១៣ សង្កាត់បឹងព្រលិត ខណ្ឌ៧មករា រាជធានីភ្នំពេញ។

**ស៖** តើលោកមានចំណងញាតិលោហិត ឬញាតិពន្ធ ឬជាសហព័ទ្ធជាមួយនឹងភាគីនៃរឿងក្ដីនេះដែរឬទេ?

**ឆ៖** បាទ, អត់មានទេ ។

**ស៖** តើលោកបានស្បថរួចហើយឬនៅ មុនអញ្ជើញចូលមកកាន់ក្នុងបន្ទប់សវនាការនេះ?

**ឆ៖** បាទ, មិនទាន់ទេ ។

**ស៖** លោកកាន់សាសនាអ្វីដែរ? ម្ដងទៀត តើលោកកាន់សាសនាអ្វី?

**ឆ៖** (អត់បើកមីក្រូហ្វូន)

**ស៖** ចាំៗមានភ្លើងក្រហម បាននិយាយទៅសំឡេងរបស់លោកចូលក្នុងប្រព័ន្ធសំឡេង ហើយមានការកត់ត្រា និងមានការបកប្រែផងបាទ ។ ហើយចំណុចនេះសំខាន់ ។ តើលោកកាន់សាសនាអ្វី?

**ឆ៖** បាទ, ខ្ញុំអត់មានកាន់សាសនាណាមួយទេ ។

**ប្រធានអង្គជំនុំ៖**

ជាបន្តទៀត អង្គជំនុំជម្រះសូមសួរព័ត៌មាន អំពីលោកស្រី ស៊ីរ៉ូនី ហ្កៀលបូ ។

**ស៖** អរុណសួស្ដីលោកស្រីអ្នកជំនាញ តើនាមត្រកូល និងនាមខ្លួនរបស់លោកស្រីអ្នកជំនាញ ស៊ីរ៉ូនី ហ្កៀលបូ អ៊ីចឹងពិតមែនដែរឬទេ?

**លោកស្រី វេជ្ជ. ស៊ីរ៉ូនី ហ្កៀលបូ៖**

**ឆ៖** ជាការពិតដូច្នោះមែន ។

**ស៖** តើលោកស្រីអ្នកជំនាញមានអាយុប៉ុន្មានឆ្នាំ?

**ឆ៖** ខ្ញុំមានអាយុ៥១ឆ្នាំ ។

**ស៖** តើលោកស្រីមានមុខរបរអ្វីសព្វថ្ងៃនេះ?

**ឆ៖** ខ្ញុំជាសាស្ត្រាចារ្យ និងអ្នកចិត្តសាស្ត្រ នៅសាកលវិទ្យាល័យប៉ារីសប្រាំបី ។

**ស៖** តើលោកស្រីមានទីលំនៅសព្វថ្ងៃនៅទីកន្លែងណា?

**ឆ៖** ខ្ញុំរស់ក្នុងទីក្រុងប៉ារីស ។

[០៩:៣០:១៥]

**ស៖** តើលោកស្រីមានចំណងលោហិត ឬក៏ញាតិពន្ធសហព័ទ្ធ ជាមួយនឹងភាគីនៃរឿងក្ដីនេះដែរឬទេ?

**ឆ៖** ខ្ញុំគ្មានញាតិលោហិត ញាតិពន្ធណាមួយ ចំពោះភាគីនៅក្នុងរឿងក្ដីនេះទេ ។

**ស៖** លោកស្រីកាន់សាសនាអ្វីដែរ?

**ឆ៖** ខ្ញុំគឺជាសាសនាកាតូលិក ។

**ប្រធានអង្គជំនុំ៖**

ក្រឡាបញ្ជីសវនាការ កញ្ញា ណាតាចា សម្របសម្រួលដល់លោកស្រីអ្នកជំនាញ លោកស្រីស៊ីរ៉ូនី ហ្គៀលបូ ដើម្បីឲ្យគាត់ធ្វើសម្បថនៅចំពោះមុខអង្គជំនុំជម្រះ ។

**កញ្ញា ណាតាចា វីស៊ែល វីស៖**

សូមឲ្យលោកស្រីអានតាមខ្ញុំ ។

ខ្ញុំសូមប្រកាសជាឱឡារិកថា ខ្ញុំនឹងផ្ដល់ជំនួយដល់អង្គជំនុំជម្រះដោយស្មោះត្រង់ ដោយរក្សាការសម្ងាត់ និងខិតខំប្រឹងប្រែងអស់ពីសមត្ថភាព ។

**លោកស្រី វេជ្ជ. ស៊ីរ៉ូនី ហ្គៀលបូ៖**

ខ្ញុំសូមប្រកាសជាឱឡារិកថា ខ្ញុំនឹងផ្ដល់ជំនួយដល់អង្គជំនុំជម្រះដោយស្មោះត្រង់ ដោយរក្សាការសម្ងាត់ និងខិតខំប្រឹងប្រែងអស់ពីសមត្ថភាព ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ អញ្ជើញលោក ឌុច ផារី សម្របសម្រួលដើម្បីអ្នកជំនាញ កាស៊ុន បូណាត ធ្វើសច្ចាប្រណិធានទៅតាមជំនឿរបស់ខ្លួន នៅចំពោះមុខអង្គជំនុំជម្រះ ។

**លោក ឌុច ផារី៖**

សូមលោកនិយាយតាមខ្ញុំ។ សូមបំពេញមុខងារជាអ្នកជំនាញដោយស្មោះត្រង់ រក្សាការសម្ងាត់ និងខិតខំប្រឹងប្រែងឲ្យអស់ពីសមត្ថភាព ។

**លោក វេជ្ជ. កា ស៊ុនបូណាត៖**

ខ្ញុំសូមបំពេញមុខងារជាអ្នកជំនាញដោយស្មោះត្រង់ រក្សារការសម្ងាត់ និងខិតខំប្រឹងប្រែងឲ្យអស់ពីសមត្ថភាព ។

**សួរដោយប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តអង្គជំនុំជម្រះ សូមសួរជីវប្រវត្តិ និងបទពិសោធន៍ដល់អ្នកជំនាញ ។ ហើយមុននឹងស្តាប់របាយការណ៍អ្នកជំនាញចិត្តសាស្ត្រជនជាប់ចោទ ។ ខ្ញុំសូមធ្វើការសួរនូវជីវប្រវត្តិខ្លះៗរបស់អ្នកជំនាញទាំងពីរូប ដូចខាង--

**ស៖** លោកស្រី ស៊ីរ៉ូនី ហ្យៀលបូ លោកស្រីទទួលបាននូវបណ្ឌិតផ្នែកចិត្តវិទ្យា និងបច្ចុប្បន្នជាសាស្ត្រាចារ្យជំនួយផ្នែកចិត្តវិទ្យានៅសាកលវិទ្យាល័យប៉ារីសប្រាំបីនៃប្រទេសបារាំងពិតមែនដែរឬទេ?

[០៩:៣៥:០០]

**ឆ៖** គឺពិតជាត្រឹម លោកប្រធាន ។

**ស៖** ហើយចាប់តាំងពីឆ្នាំ២០០៤មក លោកស្រីគឺជាអ្នកជំនាញមួយរូប នៅអមសាលាឧទ្ធរណ៍នៅទីក្រុងប៉ារីស តើជាការពិតមែនដែរឬទេ?

**ឆ៖** គឺពិតជាត្រឹមត្រូវ ។

**ស៖** បន្ថែមទៅលើអត្ថបទចំនួនទាក់ទងទៅនឹងមន្ទីរព្យាបាលរោគនិងរោគចិត្តរបស់ជនរងគ្រោះដែលទទួលរងការធ្វើទារុណកម្មនោះ ។ លោកស្រីបានសរសេរសៀវភៅមួយក្បាលមានចំណងជើងថា "អ្នកធ្វើទារុណកម្ម និងជនរងគ្រោះ ចិត្តសាស្ត្រនៃការធ្វើទារុណកម្ម " ដូច្នេះពិតមែនដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយលោកប្រធាន ។

**ស៖** លោកស្រីបានធ្វើការសិក្សាលើការស្វែងរកមធ្យោបាយ ដើម្បីសម្របសម្រួលផ្លូវចិត្តសាស្ត្រដល់ជនរងគ្រោះដែលទទួលរងទារុណកម្ម ។ លោកស្រីធ្លាប់សិក្សាផងដែរ អំពីទំនាក់ទំនងរវាងចិត្តវិធីសាស្ត្រដែលត្រូវប្រើប្រាស់សម្រាប់ធ្វើទារុណកម្ម និងផលវិបាកផ្នែកចិត្តសាស្ត្រ តើជាការពិតដែរឬទេ?

**ឆ៖** ពិតជាត្រឹមត្រូវ ។

**ស៖** លោកស្រីធ្លាប់បានចូលរួមក្នុងការបង្កើតមជ្ឈមណ្ឌលមួយនៅទីក្រុងប៉ារីស សម្រាប់ជនរងគ្រោះដែលទទួលរងនូវអំពើទារុណកម្មដែលមជ្ឈមណ្ឌលនោះមានឈ្មោះថា *ព្រីមូលើវី* ហើយសព្វថ្ងៃនេះលោកស្រីក៏កំពុងគ្រប់គ្រងមជ្ឈមណ្ឌលព្យាបាល និងមជ្ឈមណ្ឌលស្រាវជ្រាវមួយទៅលើអ្នកជំងឺដែលរងគ្រោះផ្នែកសតិអារម្មណ៍នៅសាកលវិទ្យាល័យ ដោយផ្តោតការសិក្សាស្រាវជ្រាវទៅលើជនរងគ្រោះដោយអំពើទារុណកម្ម អំពើប្រល័យពូជសាសន៍ ការសម្លាប់រង្គាល អំពើភេរវកម្ម ជាការពិតដែរឬទេ?

**ឆ៖** លោកប្រធាន គឺពិតជាដូច្នោះមែន ។ គឺខ្ញុំបានធ្វើការទៅលើការងារហ្នឹង គឺទាក់ទងទៅនឹងចំពោះអ្នកដែលគាត់ត្រូវបានគេធ្វើទារុណកម្ម ប៉ុន្តែខ្ញុំពុំមែនជាប្រធាននៃ-- និងស្ថាប័ននោះទៀតទេ ហើយខ្ញុំពុំមានការទទួលខុសត្រូវទៅលើស្ថាប័ននោះទៀតទេ ។

**ស៖** បាទ, អរគុណ ។ លោកស្រីធ្លាប់ចូលព្យាបាលអ្នកប្រព្រឹត្តបទឧក្រិដ្ឋកម្មទាក់ទងទៅនឹងអំពើហិង្សាក្នុងបរិបទនយោបាយ ហើយចូលរួមបង្កើតមជ្ឈមណ្ឌលនីតិសម្បទាននៅទីក្រុងពែម ប្រទេសរុស្ស៊ី សម្រាប់ទាហានចាស់ៗដែលបានចូលរួមក្នុងសង្គ្រាមនៅអាហ្គានីស្ថាន ចំណែកនៅប្រទេសបារាំងលោកស្រីធ្លាប់បានចូលរួមការព្យាបាលទាហានចាស់ៗក្នុងសង្គ្រាមអាល់ហ្សេរី និងអ្នកប្រព្រឹត្តបទឧក្រិដ្ឋទាក់ទងទៅនឹងអំពើហិង្សាក្នុងបរិបទនយោបាយផងដែរ តើការលើកឡើងរបស់ខ្ញុំនេះ ត្រឹមត្រូវដែរឬទេ?

**ឆ៖** គឺពិតជាត្រឹមត្រូវលោកប្រធាន ។ នៅក្នុងប្រទេសរុស្ស៊ី វាជាមជ្ឈមណ្ឌលមួយសម្រាប់យុទ្ធជនដែលគាត់បានចូលរួមនៅក្នុងសង្គ្រាម គឺមិនមែននៅប៉ាហ្គីស្ថានទេ គឺនៅអាហ្គានីស្ថាន ។ នៅប្រទេសបារាំង ខ្ញុំធ្វើការជាមួយនឹងអតីតទាហានដែលគាត់បានធ្វើសង្គ្រាមនៅអាល់ហ្សេរី ។

[០៩:៣៩:១៦]

**ស៖** អរគុណលោកស្រី ។

លោកសាស្ត្រាចារ្យ កាស៊ុន បូណាត១ លោកជាសាស្ត្រាចារ្យចិត្តវិទ្យា និងព្រឹទ្ធបុរសនៃវេជ្ជ-សាស្ត្រនៃសាកលវិទ្យាវេជ្ជសាស្ត្រសុខាភិបាលនៅទីក្រុងភ្នំពេញ និងជានាយកកម្មវិធីទាក់ទងនឹងសុខភាពផ្លូវចិត្តនៅក្រសួងសុខាភិបាល តើការលើកឡើងរបស់ខ្ញុំនេះត្រឹមត្រូវដែរឬទេ?

**ឆ៖** (វេជ្ជ. កាស៊ុន បូណាត) បាទ, លោកនាយក នេះជាការពិត ។

**ប្រធានអង្គជំនុំ៖**

តនៅនេះ គឺបញ្ហាទូទៅ ដែលអ្នកជំនាញត្រូវពន្យល់ដល់អង្គជំនុំជម្រះនូវលើរបាយការណ៍របស់ខ្លួន ។ យើងសូមរំឭកឡើងវិញថា ដោយយោងតាមដីការបស់សហព្រះរាជអាជ្ញា-- សហចៅក្រមស៊ើប

អង្កេត ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០០៨ លោក លោកស្រី ត្រូវបានតែងតាំងជាអ្នកជំនាញក្នុងការរៀបចំដំណើរការនីតិវិធី ដើម្បីវាយតម្លៃរបស់អ្នកជនជាប់ចោទ ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច ។ លោក លោកស្រីត្រូវបានតែងតាំងធ្វើកោសល្យវិច័យចិត្តសាស្ត្រលើជនជាប់ចោទ ឈ្មោះ កាំង ហ្គេកអ៊ាវ ហៅ ឌុច សំដៅស្វែងយល់អំពីបញ្ហាពិពណ៌នាអំពីបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ ដោយផ្តោតទៅលើទិដ្ឋភាពអត្តចរិត កម្រិតនៃការយល់ដឹងរបស់គាត់ សមត្ថភាពក្នុងការពិចារណា និងភាពវៃឆ្លាត ថាតើគាត់ជាមនុស្សងាយទទួលឥទ្ធិពលពីអ្នកដទៃ ឬក៏ងាយរំភើបដែរឬទេ? សមត្ថភាពក្នុងការយល់ដឹងអំពីអារម្មណ៍អ្នកដទៃ ។ តើគាត់មានភាពទន់ជ្រាយមិនប្រក្រតី មានជំងឺវិកលចរិតផ្សេងៗប្រសិនបើអាចពិពណ៌នាពីចំណុចទាំងនេះ និងចង្អុលបង្ហាញអំពីវិសាលភាពដែលចំណុចទាំងនេះបានទទួលរងដោយអំពើរបស់គាត់ ។ វិភាគទៅលើដំណើរការជីវិតរបស់គាត់ ដោយផ្អែកលើបរិបទវប្បធម៌ នយោបាយ និងសង្គម ចាប់តាំងពីអំឡុងនៃអង្គហេតុថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ៧៩ រហូតហ្នឹង រហូតដល់សព្វថ្ងៃនេះ ។ ធ្វើការកំណត់សម្គាល់បញ្ហាសំខាន់ៗខ្លះទៀតតាមរយៈដីកាជំនាញបន្ថែមរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០០៨ លោក លោកស្រី ត្រូវបានស្នើសុំឲ្យឆ្លើយតបទៅនឹងសំណួររបស់មេធាវីការពារក្តី ថាតើជនជាប់ចោទ អាចត្រូវបានធ្វើឲ្យមាននីតិសម្បទា និងអាចចូលរួមក្នុងសង្គមសាជាថ្មីវិញបានដែរឬទេ?

លោក លោកស្រី បានដាក់នូវរបាយការណ៍វាយតម្លៃជារបាយការណ៍លាយលក្ខណ៍អក្សរ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៨ គឺឯកសារដែលមានលេខ B1/4 ដែលមានលេខ ERN ជាភាសាខ្មែរ 00210946 រហូតដល់ 00211081 ។ ជាភាសាអង់គ្លេស 00211082 រហូតដល់ 00211151 និងភាសាបារាំង 00177506 ដល់ 00177576 ។ លើសពីនេះទៅទៀត លោក លោកស្រី ត្រូវបានស្នើដោយអង្គជំនុំជម្រះក្នុងដំណើរការនីតិវិធីនេះ នូវការវាយតម្លៃជាថ្មីនៅបច្ចុប្បន្នភាពនៃរបាយការណ៍ខាងលើដោយផ្ទាល់មាត់ ។

ឥឡូវនេះ អង្គជំនុំជម្រះសូមផ្តល់ជូនទៅលោក លោកស្រី នូវការរៀបរាប់ឆ្លើយតបដោយផ្ទាល់មាត់នូវសំណួរដែលបានរៀបរាប់ខាងដើម ដូច្នេះលោក លោកស្រី ធ្វើការសង្ខេបអំពីរបាយការណ៍លាយលក្ខណ៍អក្សរ និងបច្ចុប្បន្នភាពរបស់វា ។

[០៩:៤៣:៤៦]

មុននឹងចាប់ផ្តើមយើងខ្ញុំសូមធ្វើការបញ្ជាក់ដល់លោក លោកស្រី ដែលជាអ្នកជំនាញថា ក្នុងការ

ធ្វើការបទបង្ហាញនូវរបាយការណ៍ដោយផ្ទាល់មាត់ ក៏ដូចជាឆ្លើយតបនូវសំណួរដែលអង្គជំនុំជម្រះហើយនិងភាគីធ្វើការសួរបន្ទាប់ពីបទបង្ហាញនេះទៅ លោក លោកស្រី អាចធ្វើរបាយការណ៍រួមគ្នាដោយធ្វើការបែងចែកគ្នាតាមការស្ម័គ្រចិត្ត ឬស្រុះស្រួលគ្នារវាងអ្នកជំនាញទាំងពីរ ឬម្នាក់ក្នុងចំណោមអ្នកទាំងពីរជាអ្នកធ្វើបង្ហាញៗសរុបក៏បាន ។ ទាក់ទងទៅនឹងការឆ្លើយនិងសំណួរដែលអង្គជំនុំជម្រះ ហើយនិងភាគីធ្វើការសាកសួរ បន្ទាប់ពីបង្ហាញនេះទៅ ប្រសិនបើសំណួរមានលក្ខណៈទូទៅមិនសំដៅអ្នកជំនាញណាមួយទេនោះ អ្នកជំនាញម្នាក់ក្នុងចំណោមអ្នកទាំងពីរ អាចឆ្លើយនឹងសំណួរ ហើយអ្នកជំនាញម្នាក់ទៀតអាចបំពេញបន្ថែម ឬក៏នៅស្ងៀមមិនឆ្លើយតបក៏បាន ។

ទាក់ទងនឹងបញ្ហាធ្វើការបង្ហាញនូវរបាយការណ៍ ក៏ដូចជាឆ្លើយតបនឹងសំណួរអ្នកជំនាញទាំងពីរនាក់ កំណត់ដោយខ្លួនឯងថា អ្នកណាជាអ្នកធ្វើការបង្ហាញ? ឬអ្នកណាជាអ្នកឆ្លើយតបនោះ? អង្គជំនុំជម្រះក៏សូមរំឭកផងដែរថា វាជាមានសារសំខាន់ខ្លាំងណាស់ ក្នុងការនិយាយយឺតៗតាមលំដាប់លំដោយដើម្បីងាយស្រួលដល់អ្នកបកប្រែភាសាផ្ទួរការ និងចៀសវាងការប្រើពាក្យបច្ចេកទេសជ្រៅពេក ដើម្បីឲ្យច្បាស់ និងងាយយល់ ។

តទៅនេះ សូមអញ្ជើញអ្នកជំនាញទាំងពីរបង្ហាញនូវរបាយការណ៍ចិត្តសាស្ត្រ ដែលបានលើកឡើង ព្រមទាំងបច្ចុប្បន្នភាពរបស់វាផង ។ សូមអញ្ជើញ ។

[០៩:៤៥:៤៦]

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្សៀលប្ញ)** លោកប្រធាន! យើងនឹងពិចារណាទៅលើការណែនាំ របស់លោកប្រធាន ។ លោក លោកស្រីចៅក្រម ខ្ញុំនឹងធ្វើការផ្តល់នូវបទបង្ហាញសង្ខេប អំពីកោសល្យវិច័យចិត្តសាស្ត្រ ដែលសាស្ត្រាចារ្យ កា ស៊ុនបូណាត និងខ្ញុំ បានធ្វើឡើងនៅក្នុងឆ្នាំ២០០៨ លើជនជាប់ចោទ ។

បទបង្ហាញនេះ គឺវាក៏រួមទៅនឹងព័ត៌មានបច្ចុប្បន្នភាពមួយទៀតដែលបានធ្វើឡើងកាលពីសប្តាហ៍មុន ។ សូមអរគុណ ដែលបានផ្តល់យើងខ្ញុំរយៈពេលហុកសិបនាទី ។ មុនពេលចាប់ផ្តើម យើងខ្ញុំសូមសម្តែង នូវសេចក្តីគោរព ចំពោះជនរងគ្រោះដែលបានបាត់បង់ជីវិត និងសេចក្តីគោរពយ៉ាងជ្រាលជ្រៅចំពោះជនដែលរស់រានមានជីវិតទាំងអស់ កូនចៅ និងក្រុមគ្រួសាររបស់ពួកគេ ។

យើងខ្ញុំសូមពន្យល់ ជាពិសេស ចំពោះជនរងគ្រោះដែលមានវត្តមាននៅទីនេះ ថាកោសល្យវិច័យលើជនជាប់ចោទពុំមែនជាបញ្ជាក់ថា ឧក្រិដ្ឋកម្មលើគាត់នោះគឺជាអំពើត្រឹមត្រូវនោះទេ ។ របាយការណ៍កោសល្យវិច័យ គឺមានគោលបំណងៗ ជាកញ្ចក់ឆ្លុះបញ្ចាំងយ៉ាងយុត្តិធម៌លើបុគ្គលិកលក្ខណៈរបស់រូប

មិនថាជាបុគ្គលណាមួយ ហើយយើងស្វែងយល់ថាបុគ្គលម្នាក់ ជាប់ពាក់ព័ន្ធទៅនឹងសកម្មភាពនិងការប្តេជ្ញារបស់គាត់នោះយ៉ាងម៉េច ដោយពុំគិតទៅលើកម្មភាពទាំងអស់នោះ ។ ហើយយើងបានពិចារណាទៅលើប្រវត្តិសាស្ត្រផ្សេងៗ និងពិនិត្យលើរបាយការណ៍និងព័ត៌មានវិជ្ជសាស្ត្រ ហើយយើងខ្ញុំនឹងឆ្លើយតបទៅនឹងសំណួរផ្សេងៗ ហើយយើងខ្ញុំនឹងធ្វើការវិភាគទៅលើជីវិតរបស់ជនជាប់ចោទ ។ សូមអភ័យទោស ប្រសិនបើខ្ញុំនិយាយលឿន ថាតើយើងបំពេញកោសល្យវិច័យនេះ តាមរបៀបណា? វិធីសាស្ត្រដែលយើងបានប្រើប្រាស់ គឺវាជាវិធីសាស្ត្រ ចិត្តសាស្ត្រ ភូមិសាស្ត្រ នយោបាយគ្លីនិក ។

ខ្ញុំបានអនុវត្តវិធីសាស្ត្រនេះ ក្នុងរយៈពេលជាងម្ភៃឆ្នាំហើយ ក្នុងនាមជាអ្នកមានបទពិសោធន៍ចំពោះជនរងគ្រោះដោយសារអំពើទារុណកម្មប្រល័យពូជសាសន៍ រំលោភផ្លូវភេទ សម្លាប់រង្គាល និងចារីនៃអំពើធំៗ ។ ហេតុការណ៍នៅក្នុងជីវិតដែលផ្សារជាប់ទៅនឹងកុមារភាព ការអប់រំគ្រួសារក៏ពុំមានលក្ខណៈគ្រប់គ្រាន់អំពីចារីដែលប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនេះផងដែរ ។ ចិត្តសាស្ត្រ ភូមិសាស្ត្រគ្លីនិក បានយកចំណុចទាក់ទងរវាងប្រវត្តិសាស្ត្ររួម និងប្រវត្តិផ្ទាល់របស់ខ្លួនយើង នៅក្នុងចំណោមយើងម្នាក់ៗមកធ្វើការពិចារណា ។ វិធីនេះសាស្ត្រពិចារណាលើកត្តានយោបាយ សេដ្ឋកិច្ច ប្រវត្តិសាស្ត្រ និងវប្បធម៌ និងផលប៉ះពាល់នៃកត្តាទាំងនេះលើបុគ្គលិកលក្ខណៈរបស់បុគ្គល រួមទាំងដំណើរជីវិតផ្ទាល់ចេញពីកុមារភាពនិងកើតចេញមកពីទំនាក់ទំនងនៅក្នុងគ្រួសារ ហើយជាពិសេសនៅក្នុងសង្គមកម្ពុជា ។ លោកសាស្ត្រាចារ្យ កាស៊ុន បូណាត ជាអ្នកជំនាញខាងវិកលចរិតវិទ្យា ហើយខ្ញុំសូមជម្រាប់ថាការវិភាគនេះការធ្វើកោសល្យវិច័យនេះ បានធ្វើៗឡើងអំពីការយល់ឃើញអំពីទំនាក់ទំនងរវាងទស្សនទានលោកខាងលិច និងវប្បធម៌ក្នុងស្រុក ។ ក្នុងពេលសម្ភាសន៍កោសល្យវិច័យ យើងមានបួនរូប លោក កាស៊ុនបូណាត, លោក អ៊ួច ចាន់ណាណូវ៉ា អ្នកបកប្រែនៅអ.វ.ត.ក ដែលបានស្បថរួចហើយ រូបខ្ញុំផ្ទាល់ និងជនជាប់ចោទ ។ អ្នកឯកទេស និងមន្ត្រីបកប្រែ គោរពលើគោលការណ៍រក្សាការសម្ងាត់ក្នុងអំឡុងពេលធ្វើកោសល្យវិច័យ ។ យើងបានធ្វើការសម្ភាសចំនួន១៣លើក ដែលមួយលើកៗមានការចំណាយពេលបីម៉ោង ជាមធ្យមក្នុងចន្លោះខែកុម្ភៈ មីនា ឆ្នាំ២០០៨ ។ របាយការណ៍កោសល្យវិច័យបានដាក់ជូនសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៨ ។ បន្ទាប់មក យើងបានធ្វើបច្ចុប្បន្នភាពលើរបាយការណ៍កោសល្យវិច័យចិត្តសាស្ត្រចំនួនបីលើក នៅថ្ងៃទី២៨ ២៩ ខែសីហា ឆ្នាំ២០០៩ ដើម្បីបំពេញការងារកោសល្យវិច័យឲ្យបានត្រឹមត្រូវ យើងបានសិក្សានិងវិភាគលើឯកសារទាំងឡាយដូចខាងក្រោម៖

[០៩:៥០:៣៤]

ការសម្ភាសន៍កោសល្យវិច័យចិត្តសាស្ត្រ គឺជាធាតុផ្សំសំខាន់នៅក្នុងការធ្វើកោសល្យវិច័យចិត្ត-សាស្ត្រ ។ យើងក៏បានមើលទៅលើកំណត់ហេតុសួរចម្លើយទាំងឡាយ គឺកំណត់ហេតុសួរចម្លើយជនជាប់ចោទទាំងអស់ និងការតទល់រវាងជនជាប់ឃុំ និងសាក្សីទាំងឡាយនៅថ្ងៃទី២៨, ២៩ ខែកុម្ភៈ ២០០៨ របាយការណ៍វិជ្ជសាស្ត្ររបស់ឌុច ចាប់តាំងពីពេលមកដល់ឃុំឃាំងសាលាក្តីអន្តរជាតិ ការថតខ្សែភាពយន្តអំពីការសួរចម្លើយនៅខែតុលា ឆ្នាំ២០០៧ ដែលពេលនោះជនជាប់ចោទបានប្រគល់លិខិតសុំខមាលទោសចំពោះអ្នកដែលនៅរស់រានមានជិវិត អ្នកដែលបានស្លាប់ទៅ និងគ្រួសារជនរងគ្រោះទាំងឡាយ ។

ការថតខ្សែភាពយន្តអំពីការសម្តែងឡើងវិញនៅស-២១ និងនៅជើងឯក ។ យើងខ្ញុំក៏-- ឯកសារទាំងអស់នេះ គឺជាមូលដ្ឋាននៃការវិភាគកោសល្យវិច័យ ។ នៅក្នុងពេលនោះ ឌុច បានចូលរួមសហការដោយយកចិត្តទុកដាក់ និងដោយរស់រាយនៅក្នុងអំឡុងពេលសម្ភាស យើងបានកត់សម្គាល់ឃើញមានគ្នាស្រឡះរវាងវគ្គសម្ភាសធ្វើកោសល្យវិច័យលើកទីមួយ ក្នុងខែកុម្ភៈ ឆ្នាំ២០០៨ និងលើកទីពីរ ខែមីនា ឆ្នាំ២០០៨ ដែលបានធ្វើឡើងបន្ទាប់ពីការសម្តែងឡើងវិញនៅស-២១ នៅជើងឯក ។

នៅក្នុងវគ្គសម្ភាសលើកទីមួយ ជនជាប់ចោទបានរៀបរាប់ពីខ្លួនគាត់ក្នុងនាមជាអ្នកសង្កេតពីទិដ្ឋ-ភាពខាងក្រៅ ហើយនៅក្នុងវគ្គលើកទីពីរ ដែលបានធ្វើឡើងមួយអាទិត្យ បន្ទាប់ពីការសម្តែងឡើងវិញគាត់ចាប់ផ្តើមបង្កើតការយល់ឃើញពីទិដ្ឋភាពខាងក្នុងដោយនិយាយផ្ទាល់ពីខ្លួនឯងច្រើនឡើងៗ ។

នៅក្នុងពេលសម្ភាស ដែលកាលពីអាទិត្យមុន គឺយើងក៏បានធ្វើឡើងផងដែរ ដែលវាជាការធ្វើឡើងម្តងទៀត បន្ទាប់ពីបួនប្រាំខែមកហើយ ។ ឌុច បានបង្ហាញនូវភាពហេវហត់ អស់កម្លាំងក្នុងពេលធ្វើកោសល្យវិច័យ ដោយគាត់ចាប់ផ្តើមឈឺក្បាល បន្ទាប់ពីការសម្តែងឡើងវិញ ហើយគាត់ពិបាកគេងនៅដើមសប្តាហ៍ ។ ប៉ុន្តែ ការពិបាកគេងនេះ បានធូរស្រាលឡើងវិញ បន្ទាប់មកគាត់ចាប់ផ្តើមយល់សប្តិនៅពេលយប់ គឺជាការយល់សប្តិដែលចម្លែកសម្រាប់គាត់ ។ ការពិនិត្យលើរបាយវេជ្ជសាស្ត្រ គឺវាបង្ហាញអំពីដំណើរការចិត្តសាស្ត្ររបស់គាត់ ។

[០៩:៥៣:៣៥]

ការពិនិត្យលើរបាយការណ៍វេជ្ជសាស្ត្រ ពុំបានបង្ហាញសញ្ញាប្រែប្រួលខ្លាំងណាមួយលើសរីរាង្គរបស់គាត់ឡើយ ។ ក្នុងអំឡុងពេលកិច្ចដំណើរការនីតិវិធី អំឡុងពេលធ្វើកោសល្យវិច័យចិត្តសាស្ត្រ លើកលែងតែការឈឺក្បាល និងការហេវហត់អស់កម្លាំងតែប៉ុណ្ណោះ ។ សាស្ត្រាចារ្យ កា ស៊ុនបូណាត ដែលគាត់ធ្វើកោសល្យវិច័យចិត្តសាស្ត្រនៅដើមសវនាការ ដើមដំណាក់កាលជំនុំជម្រះ គឺមិនឃើញមានការ

ផ្លាស់ប្តូរផ្នែកចិត្តសាស្រ្តទាក់ទងទៅនឹងសុខភាពស្មារតីរបស់ជនជាប់ចោទនោះទេ ។ នេះគឺជាការបង្ហាញបឋមដែលវាបានប៉ះពាល់ទៅដល់ជីវិតរបស់ជនជាប់ចោទ ។ ថាតើ ឌុច នេះ ជាមនុស្សយ៉ាងម៉េច? ចំណុចដំបូងគឺទាក់ទងទៅនឹងការប្តូរឈ្មោះ មុន និងក្រោយរបបខ្មែរក្រហមរបស់គាត់ ។ ទោះបីនៅក្នុងប្រទេសកម្ពុជា ឈ្មោះនិងថ្ងៃកំណើតអាចផ្លាស់ប្តូរងាយស្រួលជាងនៅក្នុងប្រទេសលោកខាងលិចក៏ដោយ។ ឈ្មោះ ការជ្រើសរើសឈ្មោះ និងអត្ថន័យនៃឈ្មោះដើរតួយ៉ាងសំខាន់នៅក្នុងការបង្កើតអត្តសញ្ញាណរបស់បុគ្គល កម្លាំងពលៈរបស់បុគ្គល និងជំនឿទុកចិត្តលើខ្លួនឯង ។

នៅពេលដែលយើងប្តូរឈ្មោះរបស់យើងច្រើនដងច្រើនសា មិនថាដោយសារគេប្តូរ ឬប្តូរដោយចិត្តឯង វាទំនងជាបង្ហាញថា យើងមានអត្តសញ្ញាណយ៉ាងច្រើននៅពេលដំណាលគ្នា ឬនៅពេលបន្តបន្ទាប់ ។ ឌុច បានដាក់ឈ្មោះ កាំង ជាវ នៅក្នុងឆ្នាំ១៩៤២ នៅការិយាល័យចុះអាត្រានុកូលដ្ឋានស្រុក ។ សូមអភ័ទោសបើសិនជាខ្ញុំនិយាយឈ្មោះខុស ។ នៅពេលគាត់បានពីរបីខែ គ្រូទាយបានជំរុញឲ្យឪពុកម្តាយឌុចប្តូរឈ្មោះគាត់ ដើម្បីឲ្យគាត់មានអនាគតល្អ បើមិនដូច្នោះទេ គាត់នឹងមានជំងឺ ។ ដូច្នេះ ឈ្មោះរបស់គាត់បានប្តូរមក យឹម ជាវ វិញ ។ ឌុច ពុំពេញចិត្តនឹងឈ្មោះនេះទេ ដោយឈ្មោះនេះមានន័យថាសម្តឹក ចាស់កំរិល ។ ហើយគាត់ពុំចង់ឲ្យបុគ្គលដែលគាត់ពុំគោរព ឲ្យតម្លៃដាក់ឈ្មោះឲ្យគាត់ឡើយតាមគាត់និយាយ ។ ការប្តូរឈ្មោះដោយបុគ្គលម្នាក់ដែលគាត់ពុំគោរព ឲ្យតម្លៃនៅពេលគាត់មានអាយុពីរបីខែនោះ វាគ្រប់គ្រាន់បញ្ជាក់ថា វាជាការបង្កើតអត្តសញ្ញាណ ដោយពុំដឹងខ្លួនពីបុគ្គលដទៃមួយរូប ។

នៅពេលដែលគាត់អាយុ១៥ឆ្នាំ ឌុច សុំការអនុញ្ញាតពីឪពុក ដើម្បីប្តូរឈ្មោះ និងសុំឪពុកបន្ថយអាយុគាត់ផងដែរ ។ គាត់ចូលរៀននៅពេលដែលមានអាយុច្រើនហើយ គឺនៅពេលគាត់មានអាយុប្រាំបួនឆ្នាំ ។ តាមការយល់ឃើញតាមការងាររដ្ឋបាល នៅពេលដែលគាត់បន្ថយអាយុ វាអនុញ្ញាតឲ្យគាត់ចូលប្រលងបាន ។ ដូច្នេះ គាត់បានប្តូរឈ្មោះ ហ្កេកអ៊ាវ ហៅ ឌុច វិញ ។ សូមអភ័យទោស បើសិនជាខ្ញុំប្រកបមិនច្បាស់ ។

[០៩:៥៧:០០]

ក្នុងអំឡុងពេលធ្វើកោសល្យវិច័យ ជនជាប់ចោទ គាត់ដាក់ដៃសណ្តូកដោយយកចិត្តទុកដាក់គាត់បានពន្យល់ជូនយើងខ្ញុំថា ឌុច គឺជាសិស្សដែលក្រោកឈរឡើង ដៃដាក់សណ្តូកត្រង់ ហើយ ឌុច នេះក៏សម្តៅទៅលើឈ្មោះពុទ្ធបដិមាករម្នាក់នៅភូមិពៅវើយផងដែរ ។ ឈ្មោះនេះក៏ជាឈ្មោះ ដែលគាត់ប្រើញឹកញាប់ជាងគេនៅក្នុងរបបខ្មែរក្រហមផងដែរ ។ នៅពេលដែលគាត់រស់នៅប្រទេសចិន នៅចុងឆ្នាំ

១៩៨៦ ដល់ខែកក្កដា ឆ្នាំ១៩៨៩ ជាគ្រូអក្សរសាស្ត្រខ្មែរ គាត់បានប្រើឈ្មោះ ហង់ ពិន ។ ជាថ្មីម្តងទៀត ទាក់ទងទៅនឹងសារសំខាន់នៃការដាក់ឈ្មោះគាត់ ។ ដូច្នេះ គាត់បានសម្រេចដាក់ឈ្មោះដើមកំណើតរបស់គាត់ កាំង យន់ជាវ ឲ្យចៅរបស់គាត់ ។ ដូច្នេះ យើងសង្កេតឃើញ យន់ ដែលជាឈ្មោះចិន របស់ឪពុកគាត់ ។ ឈ្មោះនេះពុំមានការលាក់លៀម ហើយវាបានលេចចេញយ៉ាងច្បាស់ជាឈ្មោះចៅរបស់គាត់ ។

នៅក្នុខ្សែស្រឡាយខ្សែត្រកូលរបស់គាត់ ការភ្ជាប់ខ្សែចិនមានសារសំខាន់ណាស់ ។ វាជាការឲ្យតម្លៃផ្នែកវប្បធម៌ឡើងវិញសម្រាប់គាត់ ។ តាមពិត ឌុច គាត់ជាកូនចៅចិន ហើយគាត់ចូលជាជាតិខ្មែរ ។ គាត់បានរៀបរាប់ គាត់បានប្រាប់យើងខ្ញុំថា នៅសម័យមុននោះ មុនពេលដែលម៉ៅសេងទុង កាន់កាប់អំណាចប្រជាជនចិនពុំសូវទទួលបានការគោរពឡើយនៅក្នុងប្រទេសកម្ពុជា ។ ប្រជាជនចិនទាំងអស់នោះពុំត្រូវបានគេឲ្យតម្លៃឡើយ ពេលខ្លះត្រូវទទួលរងនូវបានការស្អប់ខ្ពើម និងបន្ទោសបង្អាប់ ។

យើងនិយាយអំពីជីវិតកុមារភាពនិងគ្រួសារ ។ ឪពុកម្តាយ ឪពុកឌុច បានស្លាប់ចោលគាត់តាំងពីវ័យកុមារ ។ គាត់បានសិក្សារៀនសូត្រដោយខ្លួនឯង ដូចឌុចដែលបានអះអាងថា ខ្លួនទទួលគុណសម្បត្តិពីគាត់ ។ ជនជាប់ចោទនិយាយថា គាត់ពុំទទួលរងអំពីហិង្សាណាមួយឡើយនៅពេលក្មេង ។ ទោះបីគាត់ធ្លាប់ត្រូវរំពាត់ប៉ុន្មានដងក៏ដោយ ប៉ុន្តែវាជាការធម្មតានៅពេលសម័យនោះពុំហួសហេតុទេ ។ ម្តាយ ឌុច នៅរស់រាននៅឡើយទេសព្វថ្ងៃ ប៉ុន្តែពុំទទួលព័ត៌មានពីកូនប្រុសរបស់គាត់ទាល់តែសោះក្នុងរយៈពេលជាង១៥ឆ្នាំ បន្ទាប់ពីខ្មែរក្រហមបានដួលរលំ ។ គាត់បានលើកឡើងបញ្ហានេះ ដោយពុំសម្តែងនៅអារម្មណ៍ចំពោះម្តាយ និងឪពុកម្តាយរបស់គាត់ ដែលស្លាប់នៅក្នុងឆ្នាំ១៩៨០ ដោយពុំមានសម្តែងអារម្មណ៍ណាមួយឡើយ ។

[០៩:៥៩:៣៧]

គាត់និយាយថា គាត់ពុំអាចជាជនបដិវត្តន៍ ហើយមានអារម្មណ៍បែបនេះ នៅពេលជាមួយគ្នានោះឡើយ ។ គាត់បានគោរព និងកោតសរសើរចៅអធិការវត្តនៃពុទ្ធសាសនាមួយរូប ដែលគាត់បានរស់នៅជាមួយនៅក្នុងឆ្នាំ១៩៦២និង១៩៦៣ នៅក្នុងចន្លោះម្ភៃនិងម្ភៃបីឆ្នាំ ។ នៅពេលដែលគាត់រៀននៅឆ្ងាយពីភូមិរបស់គាត់ ។ គាត់ហ្នឹងហើយ ដែលខ្ញុំយល់សប្តិញឹកញាប់ មិនមែនឪពុករបស់ខ្ញុំទេ ខ្ញុំមិនដែលយល់សប្តិឃើញឪពុករបស់ខ្ញុំនោះទេ គាត់បានលើកឡើង ។ ឌុច ហាក់ដូចជាមានភាពជិតស្និទ្ធជាមួយម្តាយជាងឪពុករបស់គាត់ ។ គាត់ក៏បាននិយាយអំពីបង ប្អូនស្រីរបស់គាត់ផងដែរ ។ ឌុច ក៏កោតសរសើរចៅ

អធិការពីដើមនេះផងដែរ ដែលជាសង្ឃរាជនៅក្នុងភូមិរបស់គាត់ ។ ព្រះអង្គបានជួយស្រោចស្រង់ជីវិតគាត់ នៅពេលគាត់ធ្លាក់ខ្លួនឈឺ ។ ដូច្នេះ នៅក្នុងពេលកោសល្យវិច័យយើងអាចយល់អំពីបញ្ហានេះ តើមានអ្វីកើតឡើងនៅពេលដែលឌុចមានអាយុ១៥ឆ្នាំ?

វ័យ១៥ឆ្នាំ គឺជាវ័យសំខាន់មួយនៅក្នុងខ្សែជីវិតរបស់ ឌុច ដោយសារតែគាត់ចាប់ផ្ដើមដឹងអំពីស្ថានភាពគ្រួសាររបស់គាត់នៅក្នុងសង្គម និងស្ថានភាពដែលឪពុករបស់គាត់ជាប់ជំពាក់ជំពិនជាមួយឪពុកមារបស់គាត់ជាអ្នកចងការប្រាក់ ។ ជីវិតគ្រួសាររបស់គាត់ប្រឹងប្រែងដើម្បីដោះស្រាយទៅលើបញ្ហានេះ ហើយគាត់ក៏បានយល់អំពីស្ថានភាព ។ នៅពេលនោះហើយដែលគាត់បានរកឃើញនូវប្រព័ន្ធសេដ្ឋកិច្ច ដែលពុំមានការកេងប្រវ័ញ្ច និងពុំមានការចងការប្រាក់ ឲ្យគាត់យល់ឃើញថា វាជាប្រពន្ធគំរូមួយរារាំងការកេងប្រវ័ញ្ច គឺរបបកម្មុយនីស្ត ។ នៅក្នុងអាយុ១៥ឆ្នាំ ជនជាប់ចោទបានទទួលឥទ្ធិពលយ៉ាងខ្លាំងពីទស្សនកិច្ចផ្លូវការមួយរបស់មេដឹកនាំកុម្មុនីស្តកម្ពុជាចិន ។ នៅពេលនោះអត្តសញ្ញាណចិនរបស់គាត់ចាប់ផ្ដើមមានតម្លៃឡើងវិញ ក្រោយពីការបន្ទោសបង្អាប់ និងស្អប់ខ្ពើមពីសំណាក់ប្រជាជនខ្មែរ ។ គាត់បានលើកឡើងថា គាត់មានមោទនភាពជាជនជាតិចិន ។ នៅពេលជាមួយគ្នាផងដែរ គាត់ក៏ទទួលឥទ្ធិពលពីគ្រូរបស់គាត់ផងដែរ ដោយសារតែគ្រូនោះប៉ានធ្វើការរិះគន់អំពើពុករលួយ និងភាពអយុត្តិធម៌នៅក្នុងសង្គម ប៉ុន្តែក្រោយមកគ្រូរបស់គាត់ត្រូវបានគេសម្លាប់ចោលនៅស-២១ ដែលនៅពេលនោះ ឌុច ជាអ្នកគ្រប់គ្រង ។

[១០:០២:០៨]

នៅពេលដែលអ្នកទោសចូល ស-២១ អ្នកទាំងនោះជាខ្មាំងទាំងអស់ ដោយពុំចាំបាច់សួរមេរបស់គាត់ឡើយ គាត់បានលើកឡើង ។ នៅពេលដែលគាត់មានអាយុ១៥ឆ្នាំ គាត់បានយល់អំពីវិសាលភាព និងអត្ថន័យនៃការកេងប្រវ័ញ្ចតាមរយៈការចងការប្រាក់ ។ នៅក្នុងវ័យ២០ឆ្នាំនេះហើយ ដែលគាត់ជាសិស្សនៅវិទ្យាល័យព្រះស៊ីសុវត្ថិ ហើយគាត់បានចាប់ផ្ដើទាំងស្រុងអំពីគម្លាតធំធេងអំពីអ្នកជនបទ និងអ្នកក្រុង ។

[១០:០២:៣២]

នៅឆ្នាំ១៩៦៤ គាត់បានជួប សុន សេន ដែលជាបញ្ញាជនចេះភាសាបារាំង ហើយក្រោយមក ឌុច ហៅគាត់ថា លោកគ្រូ ។ ឌុចជាមនុស្សគួរឲ្យគោរព និងកោតសរសើរ ដោយសារចំណេះដឹងរបស់គាត់ពីគ្រូនិយាយភាសាបារាំងរបស់គាត់ គាត់ក្រេបជញ្ជក់ចំណេះដឹងទាំងអស់នោះ តាមរយៈការទទួលស្គាល់

គ្រូរបស់គាត់ ។ ពួកគាត់ជាគំរូរបស់ឌុច ទោះបីពួកគាត់វាយឌុចខ្លះក៏ដោយ ។ វាជាបញ្ហាសាមញ្ញ ជាសិស្សគាត់បានយល់ឃើញអំពីទ្រឹស្តីអត់ទ្រាំ គឺ *ស្តុកអ៊ីស៊ីហ្សឹម* តាមរយៈគ្រូរបស់គាត់មួយរូបដែលគាត់តែងតែសរសើរនៅពេលបច្ចុប្បន្ន គឺលោកគ្រូ ហ្វែស ។ ជនជាប់ចោទគាត់នៅរក្សាអាម្មរណ៍ពេញចិត្តនៅក្នុងការងារបង្រៀន និងការងារបណ្តុះបណ្តាលក្នុងដំណើរជីវិតរបស់គាត់តាំងពីដើមរហូតមក ជាដំបូងជាគ្រូបង្រៀន បន្ទាប់មកនៅស-២១ បន្ទាប់មកនៅប្រទេសចិន និងចុងក្រោយនៅជំរំភៀសខ្លួន ។

ដូច្នេះ ប្រវត្តិរូបផ្ទាល់ខ្លួនរបស់គាត់ បង្កើតឡើងតាមរយៈគោលការណ៍យកគំរូតាម ហើយអាចហៅតាមរយៈពាក្យចិត្តសាស្ត្រថា គឺសមាហរណកម្មវប្បធម៌ និងនីភេទនកម្មវប្បធម៌ ។

សមាហរណកម្ម សំដៅលើការជួបប្រទះដោយចៃដន្យណាមួយជាមួយនឹងវប្បធម៌មួយដែលខុសពីវប្បធម៌យើង ។ ការជួបប្រទេសតែងតែមានឥទ្ធិពល ទៅការបង្កើតអត្តសញ្ញាណរបស់យើង ហើយវាអាចធ្វើឲ្យយើងមានការតក់ស្លុតឬក៏អត់? ហើយវាអាចមានផលវិជ្ជមាន ឬក៏ផលអវិជ្ជមាន ។ វាអាចឲ្យយើងមានការភ័យខ្លាច ចង់បាន ហើយវាតែងតែបន្សល់ដាននិងឥទ្ធិពលចំពោះយើង ។

នីភេទនកម្មវប្បធម៌ គឺជាពាក្យប្រើប្រាស់សម្រាប់លទ្ធផលនៃសមាហរណកម្មវប្បធម៌ចូលគ្នា គឺវាជាការប៉ះទង្គិចរវាងវប្បធម៌ពីរ ។

[១០:០៥:០០]

វប្បធម៌គឺជាការគិតរបស់បុគ្គលម្នាក់ ហើយជំនឿវប្បធម៌ពីរនេះ គឺវាប៉ះពាល់គ្នា ។ ដូច្នេះហើយវាកើតឡើងទៅលើស្ថានភាពទាំងអស់នេះនៅក្នុងប្រវត្តិរបស់គាត់ ។

យើងផ្តោតលើមូលហេតុចម្បងនៃការប្តេជ្ញារបស់គាត់ចូលខ្លួនជាមួយនឹងបក្សកុម្មុយនីស្តកម្ពុជា គ្រូទាំងឡាយរបស់គាត់បានណែនាំគាត់ឲ្យស្គាល់ទ្រឹស្តីម៉ាក្ស ។ គាត់បានដកស្រង់ទ្រឹស្តីនេះថា "ពីម្នាក់តាមលទ្ធភាពទៅម្នាក់វិញតាមតម្រូវការ" ។ វាគឺជាទ្រឹស្តីមួយ ដែលមានភាពត្រឹមត្រូវសម្រាប់គាត់ ។ ហេតុការណ៍ចំនួនបីនឹងកើតឡើងនៅក្នុងខ្សែជីវិតរបស់គាត់ ដែលមានឥទ្ធិពលយ៉ាងខ្លាំងចំពោះគាត់ ហើយបានដឹកនាំគាត់ មិនថាដោយចេតនា ឬដោយពុំដឹងខ្លួនទៅរកទ្រឹស្តីម៉ាក ។ ហេតុការណ៍ទាំងនោះរួមមានស្នេហាបរាជ័យ ការបាត់បង់កង់ ការបាត់កង់ដែលធ្វើឲ្យគាត់លែងបានទៅរៀន ។ ហើយព្រឹត្តិការណ៍ទីបីគឺការចាប់ខ្លួនមិត្តភក្តិរបស់គាត់ចំនួនដប់រូប ។ ក្នុងនោះ គាត់ចាត់ទុកម្នាក់ជាបងរបស់គាត់ ។ ហេតុការណ៍ដ៏ធ្ងរមួយទៀតនៅក្នុងដំណើរជីវិតរបស់គាត់វាពាក់ព័ន្ធទៅនឹងដំណើរការចិត្តសាស្ត្ររបស់ជនជាប់ចោទគឺការជាប់គុកដោយខុសច្បាប់នៅក្នុងឆ្នាំ១៩៦៨ និងឆ្នាំ១៩៧០ ។ ការដោះលែងគាត់ចេញពីគុក

ដោយសារមានការជួយជ្រោមជ្រែងពីម្ដាយមីងបានដាក់ឲ្យគាត់ស្ថិតក្នុងស្ថានភាពមួយស្រពេចស្រពិល។ គាត់រួចខ្លួនចេញពីគុកមែន ប៉ុន្តែ គាត់ត្រូវលាក់អំពីការជួយនេះ ដោយសារការបក្សកុម្មុយនីស្តកម្ពុជាអាចចាត់ទុកគាត់ថាជាខ្មាំង ។

តួនាទីរបស់គាត់នៅម-១៣ និងស-២១ បានបង្ហាញអំពីទិដ្ឋភាពបុគ្គលិកលក្ខណៈរបស់គាត់ ជាពិសេសភាពចាំបាច់យ៉ាងខ្លាំងដើម្បីឲ្យមេរបស់គាត់ទទួលស្គាល់គាត់ ។ គាត់បានប្រាប់យើងថា មេរបស់គាត់ជាអ្នកផ្គងផ្គើមខ្ញុំ ហើយជំរុញខ្ញុំ ។

គ្រូ វន វ៉េត ត្រូវបានធ្វើទារុណកម្ម និងសម្លាប់នៅឆ្នាំ១៩៧៧ នៅស-២១ ។ រឿងរ៉ាវនេះបានបង្ហាញនូវភាពភ័យខ្លាច ហើយនិងភាពសង្ស័យ ដែលគាត់ត្រូវការគ្រប់គ្រងលើអ្វីៗទាំងអស់ ដែលគាត់ប្រឈមមុខ ដោយមិនមានលទ្ធភាពអ្វីដែលថាទៅតាមឆន្ទៈរបស់អង្គការនោះ ។ អ្វីដែលថាគាត់ធ្វើហ្នឹងគឺពោលពេញដោយការពេញចិត្ត និងចំណង់របស់គាត់ ។ ថាតើយើងអាចពន្យល់បញ្ហានេះដូចម្ដេច?

អ្វីដែលយើងហៅថាជាពីពាក្យខាងចិត្តសាស្ត្រនោះ គឺថា គឺប្រតិបត្តិ ការបង្កើតនូវប្រតិកម្មដើម្បីលាក់កំបាំងនូវភាពភ័យខ្លាច ហើយនិងភាពសង្ស័យ ឬក៏ត្រូវបញ្ចាក់ពីការគោរព ។

អ៊ីចឹងហើយគឺជាអ្វីដែលគោរពទៅតាមមេរបស់ខ្លួន បន្ទាប់មកគឺក្លាយទៅជាយន្តការមួយ គឺជាសម្របសម្រួលទៅតាមភាពភ័យខ្លាច ដែលគាត់ចូលរួមដោយខ្លួនគាត់ដោយមិនដឹងខ្លួន ឬក៏ដឹងខ្លួន ។ អ៊ីចឹងហើយគឺថាយន្តការសម្របសម្រួលខ្លួននេះ គឺគាត់ជួបជាប្រចាំថ្ងៃ ហើយគាត់និយាយអំពីការខកចិត្ត បាក់ទឹកចិត្តនៅក្នុងអារម្មណ៍របស់គាត់ជារៀងរហូត ។

[១០:០៨:៤៩]

ដូច្នេះនៅក្នុងឆ្នាំ១៩៧៩ មុនពេលដែលវៀតណាមចូលមកដល់ ពេលដែលគាត់នៅស-២១ ហើយការបាក់ទឹកចិត្តមួយទៀតនៅក្នុងឆ្នាំ១៩៨១ និង៨២ ។ អ៊ីចឹងហើយ គឺមានហេតុការណ៍ដែលបង្ហាញឲ្យឃើញ គឺពីភាពបាក់ទឹកចិត្តនៅក្នុងចំណុចមួយចំនួនដែលថា យើងឃើញគាត់និយាយបានល្អ គឺឃើញគាត់មានការសញ្ជឹងគិតជាញឹកញាប់ គាត់បានគិតហើយគិតទៀត គាត់មានការសង្ស័យ ហើយពេលខ្លះធ្វើឲ្យគាត់មានការយឺតយ៉ាវនៅក្នុងចិត្តសាស្ត្ររបស់គាត់ ។ តែគាត់មានការសញ្ជឹងគិតដោយហេតុថាគាត់មិនបានដឹងថា តើជាបងប្រុស ហើយនិង-- ថាតើអាចនឹងប្រាប់ឪពុកម្ដាយដូចម្ដេចកើតដែលថាមានប្អូនស្រីពីរនាក់ ហើយនិងបងប្អូនប្រុសស្លាប់ដោយសារអត់ឃ្លាននោះ ហើយនិងក្មួយ១៦នាក់ទៀតនោះ? តើអាចនឹងធ្វើដូចម្ដេចកើត?

អ៊ីចឹងគឺថាបើនិយាយចំណុចចុងក្រោយអំពីភាពមួយចំនួន គឺថាគាត់អាយុ២០ឆ្នាំ គាត់បានបរាជ័យក្នុងស្នេហារបស់គាត់ ហើយបន្ទាប់ពីគាត់បានស្នើសុំលោក សុន សេន ដែលគាត់បានផ្តល់ការអនុញ្ញាតឲ្យគាត់នោះ គាត់ក៏បានមានកូនចំនួន៤រូប ហើយគាត់បាន-- បន្ទាប់មកគឺគាត់ចូលមកធ្វើការនៅស-២១ ហើយទោះបីគាត់គិតថាកូនក្មេងនៅមន្ទីរស-២១ នឹងត្រូវស្លាប់ក៏ដោយនោះ ។

ក្នុងឋានៈជាប្រធាននៃស-២១ គាត់ក៏ជាឪពុកល្អនោះដែរ ។ យន្តការចិត្តសាស្ត្រនៃការប្រទូស-រ៉ាយរវាងការទទួលការពិត ហើយនិងការបដិសេធការពិតនោះ គឺថាគាត់អាចនឹងបែងចែកតាមរបៀបមួយអំពីជីវិតរបស់គាត់ ហើយមានគំនិតមួយចំនួនច្រើនដែរ ។ ហើយជនជាប់ចោទបានមិនសម្តែងអំពីការសោកស្តាយទេនៅក្នុងឆ្នាំ២០០៨ ដែលយើងបានជួបគាត់នោះទាក់ទងនឹងអង្គហេតុដែលគាត់ថា គាត់មិនដែលបានជួបកូនរបស់គាត់ ។ ហើយឃាតកម្មលើប្រពន្ធរបស់គាត់ក្នុងឆ្នាំ១៩៩៩ នៅពេលដែលគេប្លន់ផ្ទះរបស់គាត់នោះ គឺគាត់បានសម្តែងអារម្មណ៍បន្តិចអំពីរឿង។ ប៉ុន្តែពីសប្តាហ៍ទៅនេះ គឺគាត់បានបញ្ជាក់ពីអារម្មណ៍របស់គាត់ក្នុងក្រុមគ្រួសាររបស់គាត់ហ្នឹងខុសពីមុនឆ្ងាយ ។ គាត់ពិនិត្យឃើញគំនិត--អ៊ីចឹងហើយគឺការយល់អំពីក្រុមគ្រួសារហ្នឹងខុស ។ នៅក្នុងឆ្នាំ១៩៩៦ គាត់បានគោរពសាសនាគ្រិស្តក្រោយពីគាត់បានទទួលឥទ្ធិពលពីបុព្វជិកម្នាក់ឈ្មោះ គ្រីស្តូហ្វ័រ ឡាពែល គាត់ថា ព្រះយាស៊ូ គឺជាតំណាងគំនិតថ្មី ជាគ្រូថ្មី ហើយគាត់មានចេតនា និងចំណង់ទៅតាម ចូលទៅគំនិតនេះ ថាហេតុអ្វីបានគាត់ចូលយកសាសនានេះ?

[១០:១១:៤៤]

សាសនានេះហើយដែលផ្តល់លទ្ធភាពឲ្យគាត់អាចនឹងចាប់កំណើតជាថ្មី ឬក៏អាចនឹងជាសាសនាមួយដែលរឹងមាំងពូកែផងដែរ ដែលគាត់បានប្រាប់យើងក្នុងឆ្នាំ២០០៨ ។ គឺសាសនាគ្រិស្តនេះហើយដែលធ្វើឲ្យកុម្មុយនីស្តនៅប៉ូឡូញ ទទួលបរាជ័យ ។ ដូច្នេះហើយដែលអនុញ្ញាតឲ្យគាត់ទទួលអត្តសញ្ញាណផ្ទាល់ខ្លួនរបស់គាត់ មិនមែនជាអត្តសញ្ញាណរួមដូចនៅពេលកុម្មុយនីស្តទៀតទេ ហើយតម្រូវការនៃការជឿនោះគឺថាអាចនឹងមានផលប៉ះពាល់ទៅនឹងអត្តចរិតរបស់គាត់ ។

អ៊ីចឹងចំណុចទាំងនេះ ខ្ញុំនឹងនិយាយអំពីក្នុងសន្ទនាលើកទី៥ នៃខែមីនា ឆ្នាំ២០០៨ ហើយគាត់និយាយថា ពីមុនគាត់គិតថាកុម្មុយនីស្តអាចនឹងជួយប្រទេសរបស់ខ្ញុំ ប៉ុន្តែឥឡូវនេះមិនមែនទេ ។ ថាតើឌុច ទទួលរងនូវការប៉ះទង្គិចផ្នែកស្មារតីដែរឬទេ? មិនមែនទេ ។ អ្នកជំនាញរកពុំឃើញថាមានការប៉ះទង្គិចផ្នែកស្មារតីរបស់ ឌុច ឡើយ ។

គាត់មិនទទួលរងពីជំងឺវិលកចរិត មិនមានជំងឺសឹកសង្គម ជំងឺផ្លូវចិត្ត ជំងឺខួលក្បាលអាការៈឡើយ ។ ចំពោះអត្ថន័យទាក់ទងនឹងផ្លូវភេទនេះវិញ ទាក់ទងនឹងការប៉ះទង្គិចផ្លូវស្មារតីនេះ ប៉ុន្តែការបែងចែងតាមប្រព័ន្ធបស្ចិមប្រទេសនេះ នៅក្នុងបញ្ហានេះ គឺថាអាចលើកឡើងពិភាក្សាយ៉ាងល្អិតល្អន់ទៅតាមការគិតគូរខាងបស្ចិមប្រទេសនោះ គឺជាការត្រួតត្រាទៅលើអ្នកផ្សេងទៀត គឺជាផ្នែកមួយនៃអំពើគ្រប់គ្រងផ្លូវចិត្ត ដែលការខូចខាតអាការៈនេះ ដែលក្នុងសម័យខ្មែរក្រហមយើងអាចពិនិត្យឃើញនៅក្នុងផលវិបាកមួយចំនួនដែលថាហើយអាចនឹងសម្តែងនៅក្នុងអាការៈរបស់គាត់រហូតដល់ពេលថ្ងៃនេះ ។

ថាតើកាយវិការខាងចិត្តសាស្ត្ររបស់គាត់នេះយ៉ាងដូចម្តេចនៅក្នុងខ្មែរក្រហម ដើម្បីធ្វើដូច្នេះបានយើងនឹងមើលប្រវត្តិសាស្ត្ររួមហើយនិងប្រវត្តិផ្ទាល់របស់បុគ្គល ឌុច នេះខ្លួនឯង ។ សញ្ញាណនៃការប៉ះទង្គិចផ្លូវ គឺជាទស្សនៈទានចម្លែកដែលបង្កើតឡើងដោយវិកលចរិត ជាជាតិពិន្ទុ ហើយពាក្យនេះឯងគឺកំណត់នូវនៃការប៉ះទង្គិចផ្លូវចិត្តទាំងមូល ដោយសារប្រភពចិត្តសាស្ត្រ និងសង្គមនយោបាយ ដែលជាលក្ខណៈរបស់សង្គមដែលជាអ្នកបង្កើតឡើងនោះ ។ ដំណើរការចិត្តសាស្ត្ររបស់បុគ្គលលក្ខណៈស្រដៀងគ្នានេះដែរ គឺឆ្លើយតបនឹងដំណើរការរួមរបស់សង្គមទាំងមូលនៃភាពជាក់លាក់របស់សង្គមទាំងមូលនៅក្នុងដំណាក់កាលណាមួយ ។ នេះជាអ្វីដែលយើងកំណត់ថាជាការប៉ះទង្គិចផ្លូវចិត្តនោះ ។

[១០:១៤:៥៧]

ការប្រៀបធៀបរវាងប្រវត្តិសាស្ត្ររួមរបស់ប្រទេសកម្ពុជានិងប្រវត្តិសាស្ត្រផ្ទាល់ខ្លួនរបស់ ឌុច គឺពាក់ព័ន្ធទៅនឹងករណីដែលប្រទេស និងបុគ្គលម្នាក់បានឆ្លងកាត់សមាហរណកម្មវប្បធម៌ជាបន្តបន្ទាប់ និងក្នុងទម្រង់ទ្រង់ទ្រាយធំ ដែលមានន័យថាការឆ្លងកាត់ប្រព័ន្ធវប្បធម៌ខុសគ្នា ហើយក្រោយមកឆ្លងកាត់វិច្ឆេទកម្មវប្បធម៌ចាក់ឫសគុល និងកម្រោលដែលបង្កឡើងដោយរបបខ្មែរក្រហម ។ បន្ទាប់មកគឺយើងមានការ មានអង្គការគួរឲ្យភ័យខ្លាចទូទាំងប្រទេសទាំងមូល និងចំពោះបុគ្គល ហើយត្រូវសម្របខ្លួនតាមបើពុំដូច្នោះទេនឹងត្រូវក្ស័យជីវិត លែងទុកចិត្ត ការភ័យខ្លាចជាទូទៅ ការញុះញង់ឲ្យលុបបំបាត់ចោល ឬគាបសង្កត់ផ្លូវអារម្មណ៍ និងការគិតពិចារណារបស់បុគ្គលនីមួយៗដើម្បីជាប្រយោជន៍អត្តសញ្ញាណរបស់សមូហភាពថ្មី ។

ការវិភាគចិត្តសាស្ត្រនយោបាយបែបនេះ ការប៉ះទង្គិចវិសាមញ្ញពុំអាចសម្រាលការទទួលខុសត្រូវរបស់ជនជាប់ចោទចំពោះអំពើទាំងឡាយរបស់គាត់ឡើយ ។ សតិអារម្មណ៍នយោបាយ គឺជាសតិអារម្មណ៍បង្កើងឡើងតាមរយៈសង្គម វប្បធម៌ នយោបាយ សង្គម ចិត្តសាស្ត្រ ជាសតិអារម្មណ៍បុគ្គល ឬសង្គម

ឯកជន ដែលនឹងរកដំណោះស្រាយនៅក្នុងបរិបទរួម ដែលនឹងត្រូវរកដំណោះស្រាយក្នុងបរិបទធម្មតាមួយ ជាពិសេសនូវការចូលរួមនៅក្នុងបរិបទនយោបាយ ។

អ៊ីចឹងគឺថា អារម្មណ៍ដែលបង្កើតនូវអារម្មណ៍នយោបាយ គឺជាហេតុការណ៍ដូចគ្នាទាំងនេះ គឺជាបទពិសោធនៃការភាពអាម៉ាស់មុខ ។ អំពើអាម៉ាស់នៃវប្បធម៌ ការបន្ទោសបង្អាប់ កំហឹង ទុក្ខព្រួយ ឬក៏ការស្អប់ខ្ពើម ។ ពាក់ព័ន្ធទៅនឹងបញ្ហានេះ ខ្ញុំនឹងត្រឡប់ទៅជីវប្រវត្តិរបស់គាត់ដែលថា យើងបានបញ្ជាក់បន្តិចហើយ គឺការខកចិត្ត គឺជាអ្វីដែលកើតមាននៅក្នុងជីវិតរបស់ ឌុច ដែលថាការខកចិត្ត និងការគោរពខ្លួនឯង ពីព្រោះថាគាត់បានជាប់ឌុបហើយ គឺគាត់មានការខកចិត្ត គឺថាមានការខកចិត្តនៅក្នុងមនោគមន៍វិជ្ជា ក្នុងជីវិតរបស់គាត់ផងដែរ ។

ការបញ្ហារបស់គាត់គឺនៅល្អ គាត់មានសមត្ថភាពបញ្ញា គឺគាត់មានគំនិតតែមួយក្នុងពេលតែមួយ។ អ៊ីចឹងពាក់ព័ន្ធទៅនឹងសំណួររបស់សហចៅក្រមស៊ើបអង្កេត "ថាតើ ឌុច ងាយទទួលឥទ្ធិពល ឬងាយរងផលប៉ះពាល់ដែរឬទេ?" ចម្លើយគឺថា "មែន" ។ គេបានបញ្ជាក់ជាញឹកញាប់ថា ក្នុងដំណាក់នៃការធ្វើកោសល្យវិច័យចិត្តសាស្ត្ររបស់គាត់ហ្នឹង តើអ្វីជាបុគ្គលិកលក្ខណៈចម្បងៗនៃដំណើរការចិត្តសាស្ត្ររបស់ឌុច?

នៅក្នុងដំណាក់កាលដែលយើងបាន វាយតម្លៃ គឺថាការក្នុងវ័យក្មេងរបស់គាត់ គឺថាគាត់បានទទួលការភាពលំបាក ហើយគាត់សិក្សាយ៉ាងក្លៀវក្លា ហើយគាត់ត្រូវការគំរូមួយដែលស្របទៅតាមឧត្តមគតិរបស់គាត់ ដែលគាត់ស្វែងរកឲ្យមានការទទួលស្គាល់ចំពោះគាត់ ។

[១០:១៨:៤៤]

ការទទួលស្គាល់ គឺថាអាចបង្ហាញពីអារម្មណ៍ អំពីវេទនាអារម្មណ៍ ដើម្បីឲ្យគាត់បញ្ជាក់ថាគោរពទៅតាមអត្តសញ្ញាណរបស់គាត់ ហើយលោក កា ស៊ុនបូណាត ហ្នឹង អាចនឹងមានលទ្ធភាព និងពន្យល់អំពីតួនាទី អំពីគ្រូនៅក្នុងសង្គមខ្មែរ ។

អ៊ីចឹងគឺគាត់អាចត្រួតត្រាលើខ្លួនរបស់គាត់ គឺថាអាចនឹងត្រួតត្រាលើអ្វីៗបាន ។ អ៊ីចឹងគឺ ហើយអំពីភាពងប់ងល់នៅក្នុងចិត្តរបស់គាត់ហ្នឹង គឺការប្រុងប្រយ័ត្នអំពីសេចក្តីលម្អិត ហើយនិងការត្រួតត្រាលើអ្វីៗទាំងអស់ ។ ឌុច ងាកទៅរកការទាញហេតុផលតក្កវិជ្ជា ការគណនាតាមគណិតវិទ្យា ដើម្បីអាចឲ្យគាត់យល់បាន គិតឃើញ និងគ្រប់គ្រងបាន ។

អ៊ីចឹងខ្ញុំអាចនិយាយថា អត្តសញ្ញាណផ្ទាល់របស់គាត់ត្រូវបានបំភ្លេចចោល ដើម្បីជាប្រយោជន៍

ក្នុងការបង្កើតនូវអត្តសញ្ញាណមួយទៀតដែលមានតម្លៃនៅក្នុងក្រសែភ្នែករបស់គាត់ គឺអត្តសញ្ញាណសមូហភាព ។ ការដឹងដោយចេតនា និងដោយពុំដឹងខ្លួនពុំមានឡើយ ។ ហ្វ្រៃន នោះ ធាតុភាវៈនោះ និងការសញ្ជឹងគិតបានរុញច្រានចេញពីមនសិការរបស់គាត់ ។ នេះហើយយើងហៅថា ការប៉ះទង្គិចរវាងការទទួលស្គាល់ និងបដិសេធការពិត ។

[១០:២០:00]

ហើយដំណើរការចិត្តសាស្ត្ររបស់គាត់ គឺមានការបែកបាក់និងធ្លាក់ចុះ ។ ហើយពិភពលោករបស់គាត់ខាងក្នុងបានបែងចែកចេញជា តម្រងការពារដែលពុំអាចឲ្យធាតុ ឬព័ត៌មានណាមួយច្រោះចូលបាន ។ ដើម្បីភាពប្រទូស្តរាយរវាងធាតុ ទាំងអស់នេះមានភាពគ្រោះថ្នាក់ណាស់ ។ ហើយគាត់បានងាកទៅរកយន្តការការពារចំពោះគាត់គឺការបដិសេធ ឬក៏ការប៉ះទង្គិចរវាងការទទួលស្គាល់ការពិត ។ ហើយគាត់បាននិយាយថាគាត់ពុំមានជម្រើស ។ ភាពឯកោនិងការងាកឲ្យឆ្ងាយពីការពិត ហើយធាតុមួយទៀតដែលជាយន្តការការពារគឺការ ចៀសវាង ។ គាត់បាននិយាយថា គាត់ពុំចង់ឃើញឡើយ ។ គាត់ពុំឆ្លើយសំណួរទាំងឡាយដែលធ្វើឲ្យគាត់តប់ប្រមល់ ហើយគាត់មានភាពច្របូកច្របល់លើសនិទានកម្មនៅពេលដែលគាត់ជួបប្រទះទៅនឹងអ្វីដែលគាត់ពុំចង់ទទួលយកសម្រាប់រូបគាត់ ។ នេះជាអ្វីដែលយើងបានកត់សម្គាល់ឃើញក្នុងពេលធ្វើកោសល្យវិច័យ ។ លក្ខណៈពិសេសមួយទៀតនៃទិដ្ឋភាពបុគ្គលិកលក្ខណៈរបស់គាត់យើងហៅពាក្យនេះថា *អាឡិចស៊ីធីមៀ* (alexithymia) គឺជាទស្សនទានក្រេនិចដែលសំដៅនៅពេលដែលជនជាប់ចោទ ពុំមានលទ្ធភាពយល់ដឹងអំពីអារម្មណ៍ ហើយរៀបរាប់ចេញមកក្រៅ ។ ធាតុនេះវាមិនមែនជាការទទួលខុសត្រូវវប្បធម៌ របស់កូនខ្មែរជាកូនចៅចិននោះទេ ។ ហើយយើងនឹងឃើញ លោក កា ស៊ុនបូណាត នឹងនិយាយទៅលើ ចំណុចនេះឡើងវិញ ។ ការគិតពិចារណារបស់គាត់មានភាពជាក់ស្តែងទៅតាមស្ថានភាព ។ គាត់គិតថា តើអ្វីដែលអាចអនុវត្តបានភាវៈអាចកើតមានឡើងនៅក្នុងករណីដែលយើងអាចពន្យល់បានតែប៉ុណ្ណោះ ។

[១០:២២:០៥]

តាមប្រព័ន្ធគិតគូរបែបតក្កវិជ្ជារបស់ជនជាប់ចោទថា ត្រឹមត្រូវ បើពុំដូច្នោះទេ អ្វីទាំងអស់ពុំមានភាពជាក់ស្តែងឡើយនៅក្នុងក្រសែភ្នែករបស់គាត់ ។ យើងបានកត់សម្គាល់ឃើញកាលពីសប្តាហ៍មុនមានភាពផ្លាស់ប្តូរទៅលើចំណុចនេះ ។ ការផ្លាស់ប្តូរទាក់ទងទៅនឹងការប៉ះទង្គិចរយៈពេលបួន-ប្រាំខែនៃការធ្វើសវនាការ ។

លក្ខណៈពិសេសមួយទៀត ដែលមានកំណត់លក្ខណៈដំណើរការចិត្តសាស្ត្ររបស់ជនជាប់ចោទ គឺភាពគ្មានមនោសញ្ចេតនា ។ ភាពគ្មានមនោសញ្ចេតនា គឺកាលដែលពុំមានលទ្ធភាពយល់ ការគិតគូររបស់បុគ្គលដទៃ ។ ការពុំមានលទ្ធភាពយល់អារម្មណ៍របស់អ្នកដទៃ ភាពគ្មានមនោសញ្ចេតនាគឺពុំ មានលទ្ធភាពគិតថា បុគ្គលផ្សេងខុសពីខ្លួន ។ បញ្ហានេះកើតឡើងនៅពេលដែលបុគ្គលម្នាក់ពុំបានដឹងខ្លួនថាមានអត្តសញ្ញាណផ្ទាល់របស់ខ្លួនឡើយ។ ដោយសារតែឧទាហរណ៍ការបង្កើតអត្តសញ្ញាណសមូហភាពដែលធ្វើឡើងដោយខ្មែរក្រហម ។ ភាពគ្មានមនោសញ្ចេតនាកើតមាននៅក្នុងខ្លួន ឌុច ដែលគាត់បានលុបបំបាត់ចោលរាល់ទម្រង់ណាមួយនៃអត្តសញ្ញាណបុគ្គល ដើម្បីឲ្យគាត់អាចធ្វើអត្តសញ្ញាណកម្មជាមួយនឹងអត្តសញ្ញាណសមូហភាព ។ កាលពីម្សិលមិញកុម្មុយនីស្តថ្ងៃនេះជាគ្រិស្តសាសនិកជន ។ ប៉ុន្តែ យើងគួរកត់សម្គាល់ឃើញថា ភាពគ្មានមនោសញ្ចេតនា វាមានភាពផ្លាស់ប្តូរ ។ ទាក់ទងទៅនឹងទិដ្ឋ ភាពមួយនេះដែលវាមាននៅក្នុងដើមពេលដែលយើងធ្វើកោសល្យវិច័យ ។ ហើយយើងបានដាក់បញ្ចូលទៅលើស្ថានភាពជាច្រើនទាក់ទងទៅនឹងភាពគ្មានមនោសញ្ចេតនា ដោយយើងពិនិត្យទៅលើការលើកឡើងរបស់ ឌុច នៅក្នុងពេលធ្វើកោសល្យវិច័យ ។ ខ្ញុំសូមផ្តល់ជាឧទាហរណ៍តូចៗមួយចំនួននៅពេលដែលគាត់និយាយថា គាត់បន់ស្រន់ថាឲ្យអ្នកផ្សេងយល់គាត់ ។ គាត់មិនមែនបន់ស្រន់ឲ្យគេនោះទេ គឺគាត់បន់ស្រន់ដើម្បីចិត្តសាស្ត្ររបស់គាត់ ។ វាគឺជាការកើតឡើងដែលធ្វើឡើងដោយខ្មែរក្រហមចំពោះ បញ្ហាទាំងអស់នេះ ។ កុម្មុយនីស្តគឺជាឧបករណ៍មួយរបស់អង្គការ ។ ឌុច បានប្តេជ្ញាចំពោះអង្គការ ដូច្នេះហើយភាពគ្មានមនោសញ្ចេតនាវាកើតឡើងដោយសារបញ្ហាទាំងអស់នេះ ។ ហើយគាត់ត្រូវរក្សាតម្លៃរបស់ឪពុករបស់គាត់វិញ ។ ហើយគាត់បានទទួលនូវយន្តការ ឬក៏គោលការណ៍*ស្ទួស៊ីហ្សឹម* ។ យើងឃើញថា មិនមានភាពការបាក់ទឹកចិត្តណាមួយទេនៅពេលបច្ចុប្បន្នដែលវាបង្ហាញអំពីការដែលគាត់មានការសោកស្តាយ។ យើងឃើញមានគាត់សម្តែងនូវការសោកស្តាយ ហើយយើងអាចនិយាយថា ការសោកស្តាយនោះ គឺមិនអាចទទួលយកបានទេចំពោះគាត់នៅពេលបច្ចុប្បន្ន ដោយសារតែគាត់ពុំមានលទ្ធភាព ឬដោយសារតែគាត់កើតមានអំពីភាពប្រទូស្តរាយរវាងការទទួលស្គាល់ និងការបដិសេធការពិត និងអត្តសញ្ញាណរបស់គាត់ ។ ដូច្នេះហើយ យើងកំណត់ថាវាជាការផ្លាស់ប្តូរមួយនៅក្នុងខ្សែចិត្តសាស្ត្ររបស់គាត់ ។ ចំណុចចុងក្រោយថាតើយើងអាចពន្យល់ដំណើរការចិត្តសាស្ត្ររបស់ ឌុច យ៉ាងម៉េច? មនុស្សយើងពុំអាចកើតមកជាអ្នកធ្វើទារុណកម្មឡើយ សូម្បីជាអ្នកបញ្ជាគេ ឬធ្វើផ្ទាល់ក៏ដោយ ។ មនុស្សអាចក្លាយជាអ្នកធ្វើទារុណកម្ម មុនពេលដែលក្លាយជាអ្នកធ្វើទារុណកម្ម អ្នកអាចឲ្យយើងដកហូតនូវភាពមនុស្សធម៌ពីជន

រងគ្រោះដែលអាចឲ្យយើងគាបសង្កត់គេបាន ទារុណកម្មនោះជានិច្ចកាលមានភាពអមនុស្សធម៌ជាមុន។ នេះពុំមែនជាលេសទេ ប៉ុន្តែវាជាគន្លឹះ ស្វែងយល់អំពីដំណើរការចិត្តសាស្ត្ររបស់ចារីនៃអំពើប្រឆាំងមនុស្សជាតិ ។ វាក៏ជាការបង្ហាញផងដែរ នៅក្នុងការសិក្សាស្រាវជ្រាវជាច្រើន ដែលបានធ្វើឡើងចំពោះចារីនៃអំពើប្រឆាំងមនុស្សជាតិ ។ ដូច្នេះ បញ្ហានេះគឺវាទាក់ទង ហើយនិងបង្ហាញនៅក្នុងការសិក្សាស្រាវជ្រាវនៅក្នុងចិត្តសាស្ត្រគ្លីនិកតាំងពីដែល មានតុលាការ នូរីមប៊ឺក នៅក្នុងឆ្នាំ១៩៤៥ ។

[១០:២៧:០៤]

ដូច្នេះយើងឃើញអំពីវប្បធម៌នៃភាពអាម៉ាស់ដែលកើតមានឡើង មានការស្រង៉ាកចិត្ត ហើយមានការប៉ះទង្គិចកើតឡើងតាំងពីដំបូងនៅក្នុងកុមារភាព ឬក៏វ័យជំទង់ ។ ហើយបុគ្គលនេះគាត់អាចដឹង ប៉ុន្តែគាត់មិនអាចមើលឃើញទៅលើរូបភាពនិងទិដ្ឋភាពប៉ះពាល់ចំពោះគាត់ ។ វាមានភាពងាយស្រួលក្នុងការធ្វើឡើងជាជាងការបង្ហាញអំពីការផ្តល់នូវការប៉ះប៉ូវ ចំពោះបញ្ហាទាំងអស់នេះ ។ ដូច្នេះហើយយើងអាចថាគាត់អាចទទួលខុសត្រូវទៅលើបញ្ហាទាំងអស់នេះ ។ ហើយគាត់ធ្វើការកត់សម្គាល់ទៅលើខ្លួនគាត់ជាជាងការដែលគាត់សង្កត់ទៅលើគេ ។ ឌុច ទទួលខុសត្រូវចំពោះរាល់ទង្វើទាំងអស់របស់គាត់ ក្នុងន័យសីលធម៌ ។ យើងពុំឃើញថាគាត់មានបញ្ហាជំងឺខួរក្បាលឡើយ ។ គាត់ជ្រើសរើសជំរើសដែលគាត់គិតថាត្រឹមត្រូវនៅពេលនោះ ហើយក៏គាត់ប្រព្រឹត្តនូវអំពើទាំងអស់នោះ ។ គាត់ទទួលនិងជឿតាមទស្សនវិជ្ជាកុម្មុយនីស្ត ។ ក្នុងអំឡុងពេលដែលគាត់ធ្វើការនៅស-២១ គាត់យល់ស្របទៅលើចំណុចនេះ ។ គាត់ជឿស៊ុបទៅលើជំនឿរួមនៅក្នុងកុម្មុយនីស្តវិជ្ជា ។ នៅក្នុងចំណុចចុងក្រោយចំពោះសំណួរ ថាតើ ឌុច អាចកែប្រែវិញ ឬអាចចូលរួមនៅក្នុងសង្គមបានដែរឬទេ? គាត់អាច ទោះក្នុងករណីណាក៏ដោយ ។ នៅក្នុងជីវិតរបស់គាត់ គាត់អាចសម្របសម្រួលរបស់គាត់នៅក្នុងខ្សែជីវិតរបស់គាត់ដែលកើត មានជាហូរហែ ។ ទាំងអស់នេះគឺជារបាយការណ៍របស់យើងខ្ញុំ ។ ហើយខ្ញុំជឿថា ដោយសុំការអនុញ្ញាតពីលោកប្រធាន លោក កា ស៊ុនបូណាត អាចបន្ថែមទៅលើធាតុផ្សំផ្សេងៗដែលទាក់ទងទៅនឹងរបាយការណ៍ ហើយទាំងអស់នេះគឺជាមូលដ្ឋានដែលយើងអាចយកមកពិភាក្សាដេញដោលនៅពេលនេះបាន ។

សូមអរគុណ ។

**សួរដោយប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក កា ស៊ុនបូណាត ។

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** សូមអរគុណលោកនាយក ។ ក្នុងវប្បធម៌ខ្មែរយើង យើងតែងតែ

យកកូនទៅឲ្យសិក្សាជាមួយនឹងគ្រូដែលពីដើមឡើយជាព្រះសង្ឃ ហើយក៏ស្នាក់នៅជាមួយព្រះសង្ឃ ។ ទំនៀមទម្លាប់នេះក៏មានបន្តមក ជាហេតុធ្វើឲ្យយើងគោរពគ្រូដែលមាតាបិតា ដែលបានយកកូនទៅឲ្យសិក្សាជាមួយគ្រូតែងតែនិយាយថា ជូនប្រគល់ទៅឲ្យគ្រូ ធ្វើម៉េចធ្វើចុះឲ្យតែប្រដៅកូនគាត់ បង្រៀនកូនគាត់បានល្អ ទុកតែភ្នែក ។ ហើយទំនៀមទម្លាប់នេះក៏មានការប្រែប្រួលខ្លះៗ ដែលជាហេតុធ្វើឲ្យយើងជាសិស្សគោរពគ្រូយ៉ាងខ្លាំង ។

ហេតុដូច្នេះ ឃើញថានៅក្នុងប្រវត្តិតស៊ូរបស់លោក ឌុច គាត់មានការគោរពគ្រូយ៉ាងខ្លាំងក្លាដែលជាមនុស្សគំរូដល់គាត់ ហើយដែលជាមនុស្សបង្ហាញផ្លូវដល់គាត់ ។ ហេតុដូច្នេះបានជាគាត់មានការស្រលាញ់គោរពនិងការស្មោះត្រង់ជាមួយនឹងមេរបស់គាត់ដែលឈ្មោះ ថា សុន សេន ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងត្រូវសម្រាក អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីរហូតដល់ម៉ោងដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញដើម្បីបន្តដំណើរការសវនាការ ។ មន្ត្រីតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យជូនដល់អ្នកជំនាញទាំងពីររូបនេះក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់មកកាន់ទីកន្លែងសម្រាប់ទុកសម្រាប់អ្នកជំនាញឲ្យបានមុនម៉ោងដែលបានកំណត់ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១០:៣១នាទី ដល់ម៉ោង ១០:៥៦នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។

ជាកិច្ចបន្តនេះ តើអស់លោក លោកស្រីចៅក្រម មានសំណួរអ្វីត្រូវសួរដល់អ្នកជំនាញទាំងពីររូបនេះដែរឬទេ? ប្រសិនបើមានសូមអញ្ជើញបាទ ។

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមជម្រាបសួរលោកសាស្ត្រាចារ្យហើយលោកស្រីអ្នកជំនាញ ។ សូមអរគុណដែលអ្នកជំនាញ

បានអញ្ជើញមកពីចម្ងាយ ហើយបានមកធ្វើរបាយការណ៍អំពីការវាយតម្លៃអំពីចិត្តសាស្ត្រទៅលើជនជាប់ចោទ ។ ខ្ញុំសូមត្រឡប់ទៅរកគោលបំណងនៃការកោសល្យវិច័យនេះ លោកបាន លោកស្រីបានបញ្ជាក់នៅក្នុងរបាយការណ៍ថា បានពន្យល់ដល់ជនជាប់ចោទអំពីអត្ថន័យនៃវិធសាស្ត្រដែលបានប្រើនោះ បើមិនខុសទេនោះ គឺថាគេត្រូវធ្វើការវាយតម្លៃអំពីខ្សែជីវិតរបស់បុគ្គល ហើយដើម្បីឲ្យស្គាល់អំពីអត្តចរិតគាត់ឲ្យបានច្បាស់ ហើយដើម្បីយល់អំពីទំនាក់ទំនងដែលអាចនឹងកើតមានរវាងគាត់ ជាបុគ្គលហ្នឹង ហើយនិងអំពើដែលបានប្រព្រឹត្តទៅ ហើយនឹងបទល្មើសមួយចំនួនដែលចោទប្រឆាំងនឹងគាត់នោះផង ។

[១០:៥៨:១៣]

អ៊ីចឹងអំពីក្របខ័ណ្ឌជាក់លាក់ដែលបានប្រើដូចជា នៅក្នុងករណីអំពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ហើយលោកស្រីបានបញ្ជាក់ថា ជាវិធីសាស្ត្រមួយដែលៗអាចនឹងពិនិត្យមើលខ្សែជីវិតរបស់បុគ្គល ជាលក្ខណៈសាកលទៅតាមប្រវត្តិសាស្ត្រ ហើយនិងសង្គមដែលគាត់បានរស់នៅកន្លងមក ។ វាជាលក្ខណៈធម្មតាដែលថានៅក្នុងរដ្ឋបស្ចិមប្រទេសមួយចំនួនដែលថា គេត្រូវធ្វើការវាយតម្លៃកោសល្យវិច័យ ហើយនៅកម្ពុជាក៏យើងមិនមានចម្ងល់អ្វីដែរ គឺថាគេអាចតែងតែធ្វើនៅក្នុងយុត្តាធិការផ្សេងៗនោះផងដែរ ។

**ស៖** តើលោកអ្នកជំនាញអាចជម្រាបប្រាប់យើងបានទេ? ថាតើអ្វីជាសារសំខាន់អ្វីៗផ្សេងទៀតដែលក្រៅពីនៅក្នុងសេចក្តីពន្យល់នៅក្នុងរបាយការណ៍ និងការបំភ្លឺដើម្បីជាអត្ថប្រយោជន៍ក្នុងការស្វែងរកយុត្តិធម៌ក្នុងរឿងក្តីនេះ?

[១០:៥៩:២៩]

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលប្ញ)** លោក លោកស្រីចៅក្រម យើងបានឆ្លើយទៅនឹងសំណួរនានាដែលត្រូវបានស្នើសុំដោយសហចៅក្រមស៊ើបអង្កេតដែលជាអ្នកដែលតែងតាំងឲ្យយើងធ្វើនូវការវាយតម្លៃនេះ ដែលគាត់បានកំណត់សំណួរមួយចំនួនឲ្យយើងអនុវត្ត ។

ដោយយើងបានស្តាប់លោកប្រធានមានប្រសាសន៍ហើយ គឺថាការវាយតម្លៃខាងចិត្តសាស្ត្រនេះ គឺថា គឺដើម្បីជួយបំភ្លឺជាអត្ថប្រយោជន៍ស្វែងរកយុត្តិធម៌ ហើយយើងត្រូវសួរសំណួរជាក់លាក់ដើម្បីឲ្យយើង-- អំពីភាពវៃឆ្លាត ហើយនិងសហចៅក្រមស៊ើបអង្កេតយល់ថាវាមានការចាំបាច់ ដើម្បីនឹងធ្វើការវាយតម្លៃ និងកោសល្យវិច័យបែបនេះ ។

សារសំខាន់នៃការវាយតម្លៃខាងចិត្តសាស្ត្រនេះ គឺដើម្បីពិនិត្យមើលប្រវត្តិរបស់បុគ្គល ហើយនិងប្រវត្តិរូបរបស់គាត់ ដើម្បីជាវាងនូវភាពលម្អៀងនៅក្នុងការវាយតម្លៃខាងចិត្តសាស្ត្រ ។ ដើម្បីពន្យល់អំពី

ខ្សែជីវិតរបស់បុគ្គលម្នាក់ដែលៗផ្អែកលើធាតុផ្សំមួយចំនួនដែលថា ទាក់ទងទៅនឹងកុមារភាព វ័យកុមារភាព ហើយនិងផ្អែកនឹងចិត្តសាស្ត្ររបស់គាត់ ហើយជាញឹកញាប់កាលណាយើងមិនពិចារណាកត្តាខាងក្រៅផ្សេងៗ ។ ហើយខ្ញុំគិតថា តាមពិតវាជាសំខាន់ដែលអ្នកជំនាញត្រូវតែពិនិត្យមើលកត្តាប្រវត្តិសាស្ត្រ ហើយនិងកត្តាបុគ្គលពាក់ព័ន្ធនៅក្នុងសង្គមនោះផង ។ ប្រហែលជាសហសេវិករបស់ខ្ញុំអាចនឹងបន្ថែមនូវមតិមួយចំនួនទៀត លោក កា ស៊ុនបូណាត ។

[១១:០១:៤៦]

**ស៖** ការវាយតម្លៃលើផ្លូវចិត្តនេះ មិនមានការយោងទៅរកជាស្ថានភាពខាងជាអ្នកចិត្តសាស្ត្រជាពេទ្យចិត្តសាស្ត្រ ។ អ៊ីចឹងហើយថា តើវាមានតម្លៃយ៉ាងដូចម្តេច? មិនមែនជាកត្តាកំណត់ចុងក្រោយទេ ប៉ុន្តែដូចដែលលោកស្រីបានលើកឡើង គឺថាយើងមានការសម្ភាសន៍ជាច្រើន ហើយបានកត់សម្គាល់ការវិវឌ្ឍន៍មួយចំនួន ។ ប្រហែលជាចំឡែកបន្តិច យើងនឹងចាប់ផ្តើមចំណុចនេះ ប៉ុន្តែតើលោកស្រីយល់ទេថា ការវាយតម្លៃនេះវាមានផលប៉ះពាល់អ្វីទៅដល់ជនជាប់ចោទ ប្រសិនបើវាមានផលប៉ះពាល់នោះថាតើផលនោះអ្វីខ្លះ?

**ផ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្មៀលបូ)** ប្រហែលជាមានចម្លើយពីរឬបីទៅនឹងសំណួរនេះ ប៉ុន្តែខ្ញុំនឹងចាប់ផ្តើមសួរខ្លួនយើងអំពីសំណួរដូចតទៅនេះ៖

ប្រហែលជាថា មានការលំបាកសម្រាប់យើងដើម្បីធ្វើការបែងចែករវាងផលប៉ះពាល់ខាងការវាយតម្លៃខាងចិត្តសាស្ត្រដែលយើងបានធ្វើនេះ ហើយនិងផលប៉ះពាល់អំពីនីតិវិធីតុលាការ ពីព្រោះថាគាត់បានចូលរួមក្នុងសវនាការតុលាការជារៀងរាល់ថ្ងៃ ហើយគាត់ប្រឈមមុខនូវការឆ្លើយនៅសំណួរជាច្រើន ហើយវាអាចនឹងមានផលប៉ះពាល់ពីនីតិវិធីទាំងស្រុងទៅលើផ្លូវចិត្តរបស់គាត់ ។ ដូច្នេះ ថាតើអ្វីតែងតែកើតឡើងទាក់ទងទៅនឹងការវាយតម្លៃចិត្តសាស្ត្របែបនេះ ។ យើងបានពិនិត្យមើលបញ្ហានេះ ដោយប្រុងប្រយ័ត្នជនជាប់ចោទមិនបានដឹងថា ចៅក្រមស៊ើបអង្កេតឲ្យយើងសួរគាត់ពីរឿងអ្វីខ្លះនោះទេ ។ ប៉ុន្តែដើម្បីធ្វើឲ្យប្រាកដថាជនជាប់ចោទមិនមានលទ្ធភាពទាក់ទងទៅនឹងមុខងារ ថាតើអ្វីដែលគាត់ឆ្លើយជាចម្លើយត្រូវឬមិនត្រូវដែលទាក់ទងទៅនឹងស្ថានភាពដែលយើងធ្វើការវាយតម្លៃគឺថា ជនជាប់ចោទ ហើយគាត់ជាបុគ្គលដែលមានយុត្តិសាស្ត្រក្នុងការចូលរួមស្វែងរកការពិត និងយុត្តិធម៌ផងដែរ ។ ដូច្នេះការវាយតម្លៃចិត្តសាស្ត្រនេះ វាជាកត្តារួមមួយបែបនេះ ។

អ៊ីចឹងត្រឡប់ទៅនឹងសំណួររបស់លោកចៅក្រមវិញ ការវាយតម្លៃនេះគឺមិនមានគោលបំណង

សម្រាប់ជាកត្តាដែលថា ត្រូវតែទទួលយកជាកត្តាកំណត់នោះទេ ។

[១១:០៥:១៣]

**ឆ៖(វេជ្ជ. កា ស៊ុនបូណាត)** ខ្ញុំសូមបន្ថែមថាអំពីការសម្ភាសន៍ ដែលយើងធ្វើជាមួយជនជាប់ចោទ ហើយនិងការវាយតម្លៃអំពីអាកប្បកិរិយារបស់គាត់ យើងមិនពិនិត្យឃើញថា ប៉ះពាល់ជាអវិជ្ជមានទៅលើជនជាប់ចោទទេ ។ ប៉ុន្តែផ្ទុយទៅវិញ គាត់បង្ហាញឲ្យយើងឃើញថា បើខ្ញុំអាចនិយាយឲ្យត្រឹមត្រូវនោះ គឺគាត់មានអាកប្បកិរិយាស្វាគមន៍គ្រប់ពេលដែលយើងបានជួបគាត់នោះឯង ។

**ស៖** នៅពេលចាប់ផ្តើមដំបូងក្នុងការវាយតម្លៃនោះ អ្នកជំនាញពន្យល់ថាជនជាប់ចោទគាត់បានសហការយ៉ាងច្រើន ដូច្នេះវាមានសារសំខាន់ណាស់ ។ អ៊ីចឹងហើយគាត់បានទទួលព័ត៌មានយ៉ាងច្បាស់អំពីការ ការអនុវត្តនៅការវាយតម្លៃចិត្តសាស្ត្រ ហើយថារបាយការណ៍នឹងត្រូវប្រគល់ទៅឲ្យសហចៅក្រមស៊ើបអង្កេត ហើយថារបាយការណ៍នឹងជាលទ្ធផលនឹងបញ្ជូនទៅភាគី តើមានបានពន្យល់គាត់ពីដំបូងបែបនេះដែរឬទេ?

ខ្ញុំចង់និយាយថា ពីដំបូងហ្នឹងគឺថាមិនមានការយោងទៅរកទស្សនៈរបស់ពេទ្យចិត្តសាស្ត្រ ហើយអ្នកជំនាញនិយាយថា ក្នុងដំណាក់កាលនៃការរៀបចំរបាយការណ៍និងសម្ភាសន៍នោះគឺថា ជនជាប់ចោទមិនមានបញ្ហាជំងឺវិកលចរិតនោះទេ ។ ប៉ុន្តែ ពេទ្យវិកលចរិតហ្នឹង គឺថាអ្នកបញ្ជាក់ថាតើគាត់មិនមានជំងឺហ្នឹង ឬក៏ថាការគ្មានជំងឺបែបនោះ គឺវាមិនមានប៉ះពាល់ទៅលើសម្បជញ្ញៈនៃការគិតគូររបស់នៃជនជាប់ចោទហ្នឹងទេ ឬក៏ដូចម្តេច? អ៊ីចឹងប្រហែលជាស្រួលដើម្បីឲ្យលោកមានប្រសាសន៍ជាភាសាខ្មែរ ដើម្បីជាអត្ថប្រយោជន៍នៃការកត់ត្រានោះផងដែរ ។

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** ខ្ញុំសូមជម្រាបថា ក្នុងពេលដែលយើងបានធ្វើការសម្ភាសន៍ជាមួយលោក ឌុច ក្នុងគ្រាដំបូងយើងមានការឆ្ងល់ ដោយសារក្នុងប្រវត្តិរបស់គាត់តាំងពីដើមរហូតគាត់បានជួបប្រទះនឹងសភាពការណ៍ភ័យខ្លាច សភាពការណ៍ដែលអាចយាយីដល់អាយុជីវិតរបស់គាត់ច្រើនលើកច្រើនសា ។ ប៉ុន្តែលោក ឌុច បានដោះស្រាយដោយស្រួល ដោយមិនមានការប៉ះពាល់ណាមួយ។ ជាពិសេសទៅទៀត នៅពេលដែលលោកបានមកនៅទីកន្លែងឃុំឃាំងនេះ បានបង្ហាញនូវឥរិយាបថ និងអាកប្បកិរិយាដែលបង្ហាញថាមានការភ័យខ្លាច ឬក៏ការធ្លាក់ទឹកចិត្ត ឬក៏បញ្ហាជំងឺផ្លូវចិត្តណាមួយ ។ ដោយចង់ដឹងច្បាស់លាស់ ដោយចង់ដឹងអំពីការពិតខ្លាចក្រែងលោលោក ឌុច គាត់អាចនិយាយកុហក ខ្ញុំបាននៅពេលដែលធ្វើការស្រាវជ្រាវលើកទីមួយជាមួយលោកស្រី ស៊ីរ៉ូនី បានពិនិត្យមើលនៅក្នុងឯកសារពិនិត្យសុខភាព

ឃើញថា មិនមានរោគសញ្ញាណាមួយដែលឆ្លុះបញ្ចាំងថា-- មិនមានសញ្ញាណាមួយដែលបញ្ជាក់ថាលោក ឌុច មានប៉ះពាល់ដល់បញ្ហាផ្លូវចិត្ត ដែលអាចទៅជាជំងឺផ្លូវចិត្តណាមួយនោះឡើយទេ ។ ដូច្នេះ ជាការមួយដែលកាលនោះ ខ្ញុំបានផ្ទៀងផ្ទាត់ទៅតាមលទ្ធភាពដែលមានដើម្បីបញ្ជាក់ថា គាត់ពិតជាគ្មានការប៉ះពាល់ទៅលើសុខភាពផ្លូវចិត្តរបស់គាត់ ។

[១១:១០:៤៨]

**ស៖** ដូច្នេះ លោកអាចបញ្ជាក់ប្រាប់អង្គជំនុំជម្រះថា មកដល់ថ្ងៃនេះគាត់មិនមានបញ្ហាជំងឺផ្លូវចិត្តអ្វីទេ ។ អ៊ីចឹងហើយ នេះហើយជាកត្តាដែលថាបញ្ជាក់ការពិត គាត់ដឹងពីអ្វីៗដែលនៅជុំវិញគាត់ ហើយគាត់ស្គាល់ពីការពិត ហើយគាត់មិនមានបញ្ហាទាក់ទងទៅនឹងការសម្តែង ឬក៏បញ្ហាការគិតគូររបស់គាត់ទេ តើអ៊ីចឹងមែនឬទេ?

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** ដោយសារសង្កេតឃើញថាអ្វីដែលលោក ឌុច បានរៀបរាប់តាំងពីប្រវត្តិនៅរៀន រហូតទៅដល់គាត់បានបង្រៀន ហើយគាត់បានយក-- រកហេតុផលដែលបញ្ជាក់ថាហេតុអ្វីបានជាគាត់ជ្រើសរើសរកមនោគមវិជ្ជាកុម្មុយនីស្ត ដើម្បីជាមាគ៌ាដើរទៅមុខ? ហើយដែលរូបខ្ញុំក៏បានធ្លាប់ដឹងអំពីសភាពការណ៍សង្គមនាពេលនោះដែរ បញ្ជាក់ថាគាត់និយាយមានការសមហេតុសមផល ដែលយើងមិនអាចចាត់ទុកគាត់ថាជាៗ *អាល់លុយសិនណាសស៊ីង* ជាគំនិតដែលរវើរវាយទេ ។

**ស៖** ខ្ញុំមិនត្រឡប់ទៅរករបាយការណ៍ទាំងស្រុងនោះទេ ប៉ុន្តែខ្ញុំនឹងចុចបញ្ហាមួយចំនួនដើម្បីឲ្យអ្នកជំនាញបំភ្លឺ ពីព្រោះថាខ្ញុំឃើញចំណុចរបាយការណ៍ហ្នឹងច្បាស់ហើយ ។ គឺចំណុចមួយលោកបានចំនួយមួយគឺពាក្យថា *អាឡិចស៊ីធីមៀ* អំពីការដែលមិនចេះសម្តែងអារម្មណ៍ទៅឲ្យអ្នកដទៃដឹង ។ អ៊ីចឹងហើយ គឺជាខ្ញុំជឿថាខ្ញុំយល់ច្បាស់ គឺថាអលទ្ធភាពក្នុងដឹងអំពីអារម្មណ៍ពីអ្នកដទៃហ្នឹង ហើយក៏មិនចេះសម្តែងពីអារម្មណ៍របស់ខ្លួននោះ ។ ប្រហែលជាលោកអាចពន្យល់ឲ្យបានច្បាស់ជាងហ្នឹងបន្តិច ថាតើអារម្មណ៍ដូចម្តេច?ឬវេទនាអារម្មណ៍ដូចម្តេច? ដែលថាគាត់អាចមិនសម្តែងចេញបាននោះ។ ជាពិសេសគឺជាអារម្មណ៍ខាងនយោបាយរបស់គាត់ ដែលអ្នកជំនាញនិយាយអំពីអារម្មណ៍ខាងនយោបាយដែលអាចនឹងកើតឡើង ជំរុញឡើងដោយអំពើគេមាក់ងាយ ហើយនិងកំហឹង ហើយជំរុញឲ្យគាត់មានចេតនានឹងសងសឹកអំពីអំពើទាំងអម្បាលម៉ាននោះ ។ ថាតើអ្វីជាអារម្មណ៍ដែលអ្វីខ្លះ ដែលលោកនិយាយថាគាត់មិនមានសមត្ថភាពនឹងសម្តែងពីអារម្មណ៍របស់គាត់ឲ្យគេដឹង ឬក៏យល់អារម្មណ៍របស់គេបាននោះ តើយ៉ាងដូចម្តេច?

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលបូ)** អារម្មណ៍នេះ គឺយើងនិយាយថាគឺជាអារម្មណ៍ ពាក់ព័ន្ធទៅនឹងអំពីអារម្មណ៍ផ្ទាល់ខ្លួនរបស់គាត់ជា-- ដូចជាអារម្មណ៍អំពីមេត្តាធម៌ ដូចជាអារម្មណ៍អំពីការឈឺចាប់របស់អ្នកដទៃ ហើយខ្លួនហ្នឹងគាត់ផងដែរ ។ នៅក្នុងគំនិតដែរថាវេទនារម្មណ៍ ឬអារម្មណ៍ គឺអារម្មណ៍ភ័យខ្លាចគឺអារម្មណ៍ដែលសំដៅនៃការឈឺចាប់ ឬទុក្ខសោក ឬក៏ថាយើងនឹងយល់ថា ការឈឺចាប់ក៏មិនមែនជាអារម្មណ៍ ប៉ុន្តែនេះជាហេតុដែលថាគាត់មិនមានលទ្ធភាពនឹងទទួលបាន ឬក៏មិនអាចនឹងប្រើបាននូវអារម្មណ៍ផ្ទាល់ខ្លួនផ្ទៃក្នុងរបស់ខ្លួន ដូចថាជាការសម្តែងការសប្បាយ ដែលថាអាចអំពីកត្តាមួយចំនួនដែលថា ជាពិសេសគឺថាវាមានភាពផុយស្រួយ ក៏មានភាពទន់ខ្សោយផ្ទៃក្នុងរបស់គាត់ ។ អ៊ីចឹងគឺថាការខ្វះសម្តែងអារម្មណ៍នេះ គឺថាវាមានច្រើនការ វាអាចទាក់ទងទៅនឹងអារម្មណ៍មួយចំនួនដើម្បីបញ្ជាក់នោះថាតើអារម្មណ៍ដូចម្តេចខ្លះ ដែលយើងនិយាយ? ពីព្រោះថាអារម្មណ៍ខ្លះ ដូចជា កំហឹងគឺអាចជាមិន-- ខ្ញុំមិនបញ្ជាក់ថាគាត់មានកំហឹងនៅក្នុងពេលសម្ភាសន៍នោះទេ។ ប៉ុន្តែ ជាអារម្មណ៍មួយចំនួនដែលបង្ហាញពីគំនិតថា ជននោះគឺមានអត្តចរិត ឬក៏បុគ្គលិកលក្ខណៈមួយក្នុងកម្រិតមួយ ហើយយើងបានសិក្សាពីកត្តាមួយចំនួនអំពីបុគ្គលដែលបានឆ្លងកាត់ក្នុងរបបខ្មែរក្រហម ហើយយើងក៏បានសួរអំពីអតីតកាលមុននឹងទៅទៀតដើម្បីធ្វើកត្តាកំណត់ គឺថាវ័យ យុវ័យរបស់គាត់ ហើយនិង ហើយគាត់ក៏បានចាប់អារម្មណ៍ទៅនឹងទ្រឹស្តីអំណាត់អត់ធន់និយមហៅថា *ស្តូអ៊ីហ្សឹម* ហើយនៅក្នុងដំណាក់កាលនៃការរៀនសូត្ររបស់គាត់គឺជាស្ថានផ្លូវចិត្តមួយដែលមិនចេះសម្តែងអារម្មណ៍របស់ខ្លួនឲ្យអ្នកដទៃដឹង ។ អ្វីដែលជាមូលដ្ឋាននោះ គឺគ្រប់ប្រតិកម្មដែលឆ្លើយតបទៅនឹងការឈឺចាប់ ហើយនិងការឈឺចិត្តដែលដោយចុកចាប់ដោយខ្លាំងនោះ ។ អ៊ីចឹងហើយ ប៉ុន្តែគាត់បានសម្របសម្រួលទៅតាមអារម្មណ៍ហ្នឹង ដោយប្រើមនោគមវិជ្ជា ឬក៏គំនិតដោយរក្សាអារម្មណ៍ដ៏ស្ងប់ស្ងាត់គ្រប់គ្រង់អារម្មណ៍បាន ដោយមិនប្រតិកម្ម ។

[១១:១៧:៤៩]

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** ខ្ញុំបាទសូមបន្ថែមបន្តិចអំពីករណីដែលយើងនិយាយថា *អាឡិចស៊ីធីមៀ* នេះ ដោយសារមានលក្ខណៈវាផ្សារភ្ជាប់ទៅនឹងប្រពៃណីខ្មែរយើង ។ ដោយសារថា ជាទូទៅយើងបានអប់រំកូនចៅ មិនឲ្យត្អូញត្អែរការលំបាកទេ ពីព្រោះត្អូញត្អែរការលំបាកប្រាប់អ្នកដទៃ វាជាការបង្ហាញនូវភាពទន់ខ្សោយ ហើយជាការគួរឲ្យខ្មាស់អៀន ។ ម្យ៉ាងទៀត នៅក្នុងករណីដែលយើងប្រឈមនឹងបញ្ហាមួយចំនួន យើងតែងតែលើកពាក្យស្លោកថា “ស្ងៀមជាជាងស្រដី” ពីព្រោះនៅស្ងៀមវាមិនបង្កទំនាស់ ហើយនៅស្ងៀមក៏មិនមានន័យយើងថាយើងចាញ់គេដែរ ហើយមិនឲ្យសភាពការណ៍កាន់តែ

លំបាក ។ ក្នុងនាមជាកូនប្រុសក្នុងប្រទេសខ្មែរយើង ក្នុងប្រពៃណីខ្មែរ ត្រូវតែមានជំហររឹងមាំ មិនត្រូវត្អូញត្អែរទេ ។

ចំពោះលោក ឌុច ដែលលោកប្រកាន់យកទស្សនៈ *ស្តូអ៊ីហ្សុីស* ដែលនៅក្នុងសិក្សារបស់គាត់ គាត់នៅក្នុងអត្ថបទមួយដែលនិយាយពី *ឡាម័រឌុយលូ* (La mort du loup) ដែលអត្ថបទមួយធ្វើឱ្យគាត់យកចិត្តទុកខ្លាំងហើយប្រកាន់យកឥរិយាបថនេះ ។ ម្យ៉ាងទៀត នៅក្នុងជំហរនៃជនកុម្មុយនីស្តគេតែងតែនិយាយថា ជនកុម្មុយនីស្តជាឧបករណ៍ដាច់ខាត់របស់បក្ស ឬរបស់អង្គការ ។ ដូច្នេះ បើសិនជាទទួលភារកិច្ចធ្វើលំបាកយ៉ាងណាក៏ដោយ រហូតទៅដល់អាចស្លាប់ខ្លួនមិនត្រូវត្អូញត្អែរទេ ។ ហាក់ដូចខ្លួនឯងហ្នឹង វាជាឧបករណ៍មួយ ជាម៉ាស៊ីនដែលត្រូវតែទទួលអនុវត្តនូវអ្វីដែលជាបទបញ្ជា ។

ប្រការនេះ ខ្ញុំបានសង្កេតឃើញជាច្រើននៅក្នុងសម័យខ្មែរក្រហមក្តី និងក្រោយមកទៀត ដោយ-សារខ្លួនបានព្យាបាលអ្នកជំងឺដែលជាខ្មែរក្រហមនោះ សួរអំពីការលំបាកគេសុខចិត្តនៅស្ងៀម ហើយមិនឆ្លើយ ។ ហេតុដូច្នេះហើយបានជាខ្ញុំយល់ថា *អាឡិចស៊ីធីមៀ* នេះ វាមានផ្សារភ្ជាប់ទៅនឹងវប្បធម៌របស់ខ្មែរផង និងប្រវត្តិសាស្ត្ររបស់ខ្មែរផង ។

**ស៖** និយាយជាសង្ខេប តើយើងអាចនិយាយបានទេ ទាក់ទងទៅនឹងជនជាប់ចោទ គឺប្រវត្តិក្រុមគ្រួសារវប្បធម៌របស់គាត់ ការអប់រំរបស់គាត់ ហើយនិងការជួប ឬក៏ប្រឈម ឬក៏ប្រាស័យជាមួយនឹងលទ្ធិកុម្មុយនីស្ត? ហើយយើងមិនអនុញ្ញាតឱ្យធ្វើអ្វីបានក្រៅពីហ្នឹង ហើយអារម្មណ៍នោះហើយ ដែលគាត់ទទួលបានទៅអ្វីដែលគាត់ជួបនោះ វាឆ្លុះបញ្ចាំងអំពីមនោគមវិជ្ជាកុម្មុយនីស្តដែលធ្វើឱ្យគាត់យល់ថាសង្គមចង់ឱ្យគាត់ធ្វើអ៊ីចឹង ដើម្បីជាប្រយោជន៍របស់សង្គម តើអ្នកជំនាញអាចមានមតិដូចម្តេចត្រង់បញ្ហានេះ?

[១១:២៣:២៩]

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលបូ)** តាមពិត គឺអាចសម្តែងគំនិតតាមរបៀបនោះ ខ្ញុំសូមជម្រាបជូនលោក លោកស្រីចៅក្រមថា ការវាយតម្លៃអំពីកោសល្យវិច័យនេះ យើងមានបទសម្ភាសន៍ជាច្រើនជាមួយជនជាប់ចោទ ប៉ុន្តែសំខាន់ផងដែរ ដើម្បីយើងកំណត់អំពីការវាយតម្លៃអំពីជីវប្រវត្តិរបស់គាត់អំពីធាតុផ្សំផ្សេងៗ ប៉ុន្តែខ្ញុំសូមជម្រាបថានៅក្នុងការវាយតម្លៃទាំងអស់ ដែលទាក់ទងទៅដល់ឫសគល់នៃការវាយតម្លៃដែលយើងនឹងជម្រាបជូនថាតើកត្តាអ្វីមួយៗ ដែលកើតពេលណានោះ លម្អិតជូនតុលាការ ថាពួកយើងនឹងលំបាកក្នុងនោះបាននិយាយលម្អិតនោះ ។ ប៉ុន្តែ ការនិយាយពន្យល់នោះ គឺថាយើងអាចធ្វើបាន

តែលក្ខណៈមានភាពប្រាកដប្រជា ប៉ុន្តែយើងចាត់ទុកគាត់ថា គាត់ស្ថិតនៅក្នុងការវាយតម្លៃកោសល្យវិច័យចិត្តសាស្ត្រ គឺយើងមិនចាត់ទុកគាត់ថាជាជនមួយដែលស្ថិតនៅក្នុងស្ថានភាពខុសពីហ្នឹងទេ ។

**ស៖** សំណួររបស់ខ្ញុំ គឺខ្ញុំចង់ដឹងថាជាបុគ្គលដែលគាត់បញ្ចេញនូវអត្តចរិតមួយ តើគាត់អាច ឬក៏មិនអាចទទួលអារម្មណ៍ ឬក៏យល់ពីអារម្មណ៍ការឈឺចាប់របស់អ្នកដទៃ ដែលថាការឈឺចាប់នោះ ដែលអាចនឹងមានលក្ខណៈជាក់ស្តែង ហើយជាពិសេសអំពីលក្ខណៈការឈឺចាប់ផ្លូវចិត្តហើយនិងផ្លូវកាយរបស់អ្នកដទៃ ថាតើគាត់ដឹងបាន ឬក៏មិនដឹងបាន?

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលប្វ)** ដោយមិនមានចម្ងល់អ្វីទេ នេះមិនមែនទាក់ទងតែទៅនឹងការសម្តែងអារម្មណ៍នោះទេ ប៉ុន្តែវាមានកត្តាផ្សេងទៀត ដែលយើងបាននិយាយ គឺការប្រទូសសារាយរវាងការទទួលយក និងការបដិសេធការពិត គឺថាវាមានយុទ្ធសាស្ត្រ យន្តការមួយចំនួន ការសមស្របសម្រួលទៅតាមអំពីគួរឲ្យព្រួយខ្លាចនោះ ។ ខ្ញុំសូមជម្រាបថា នៅពេលដែលយើងមិនមែនជាអ្នកធ្វើទារុណកម្ម ហើយយើងមិនទទួលអារម្មណ៍ជា *អាឡិចស៊ីធីមៀ* នេះទេ គឺថាអាចនឹងគឺគាត់បានជួបនូវស្ថានភាពមួយនៅខាងក្រៅ ប៉ុន្តែនេះ ហើយគេអាចដឹងថា គេឲ្យតម្លៃទៅលើស្ថានភាពផ្លូវចិត្តបែបនេះ ។

**ស៖** បាទ តាមពិត នោះគឺថាគំនិតរបស់ខ្ញុំហ្នឹង គឺខ្ញុំនឹងសួរទៅអ្នកជំនាញនៅពេលនេះ ថាតើជនជាប់ចោទបានទទួលផលពីអ្វីខ្លះអំពីការសមស្របខ្លួនទៅតាមដំណើរជីវិត ដែលគាត់បានយល់ព្រមធ្វើ ថាតើគាត់មិនបានចូលរួមយ៉ាងសកម្ម នៅក្នុងអ្វីដែលគាត់បានក្លាយទៅជាមនុស្សហ្នឹងដែរឬទេ ទៅតាមលក្ខខណ្ឌផ្លូវចិត្តរបស់គាត់នោះ?

[១១:២៧:០៧]

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលប្វ)** ខ្ញុំអាចនឹងឆ្លើយលោកបាន អំពីអត្តចរិតនៃជនជាប់ចោទ ។ យើងសង្កេតឃើញមានអំពីធាតុផ្សំខាងសម្បជញ្ញៈ ដែលថាជាកត្តាសំខាន់ដែលលោកនិយាយអំពីអត្ថប្រយោជន៍ ឬក៏ផល ឬក៏ការពេញចិត្តដែលក្លាយ ដែលនាំឲ្យមានការក្លាហាន ដូចជាថា អត្តចរិតមួយចំនួនដែលយើងបានពិព៌ណនានៅក្នុងប្រព័ន្ធមួយចំនួន ឬក៏ជាគំនិតមួយដែលគាត់ថាតាំងខ្លួនជាបុរសនោះ គឺថាតាមទស្សនៈនៃបុគ្គលិកលក្ខណៈរបស់គាត់ គឺសម្តែងបែបនេះ ។ តាមពិតនោះ គឺមានចេតនារបស់គាត់ បំណងរបស់គាត់ដើម្បីក្លាយទៅជាបុរសម្នាក់ដែលខ្លួនបានក្លាយទៅនោះ ។ គាត់បានចូលរួមនៅខាងការសមស្របសម្រួល គាត់មិនបានឃ្លាតឆ្ងាយអំពីអត្តចរិតរបស់គាត់នោះទេ ។

**ស៖** តើនៅក្នុងជនជាប់ចោទហ្នឹង គឺការដឹងរបស់គាត់ គាត់ជាសមាជិកសកម្ម ហើយជាអ្នកចូលរួមយ៉ាងសកម្មនៅក្នុងនៅដំណើរការនៃការកំណត់អារម្មណ៍ ឬក៏ទទួលស្គាល់អារម្មណ៍ដែលយើងនិយាយអំពីថា ការអប់រំរបស់គាត់ ការបណ្តុះបណ្តាលរបស់គាត់ទៅលើអ្នកក្រោមបង្គាប់នោះ គឺថាគឺជនជាប់ចោទដែលចូលចិត្តការបង្រៀនបណ្តុះបណ្តាល ។ ប៉ុន្តែអតីតកាលរបស់គាត់ជាអ្នកបង្រៀន ប៉ុន្តែតើគាត់បានធ្វើការជ្រើសរើសជាក់លាក់សម្រេចជាក់លាក់ទេ ចំពោះមុខគាត់ដែលថាអ្នកណាដែលត្រូវធ្វើជាអ្នកសួរចម្លើយល្អបំផុត ។ គាត់បានបញ្ជាក់ថា គាត់បានព្យាយាមជ្រើសរើសក្មេងប្រុសតូចៗ ដែលអាយុរវាងពី១៥ឆ្នាំ ហើយនិងពួកយុវជនដែលតាមសម្តីរបស់គាត់នោះ គឺដូចជាក្រដាសសមួយសន្លឹក ដែលយើងអាចសរសេរអ្វីក៏បាន អប់រំអ្វីក៏បាន ។ នៅក្នុងន័យនេះ តើការយល់ដឹងរបស់គាត់ ទម្លាប់នៃការពេញចិត្តរបស់គាត់ ថាតើអ្នកជំនាញអាចពន្យល់ដូចម្តេចបានអំពីចំណងគោលគំនិតរបស់ជនជាប់ចោទបែបនេះ?

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្គៀលបូ)** ខ្ញុំមិនជឿថា យើងអាចបែងចែកអំពីការដឹងនិងការប្រើប្រាប់បែបនោះទៅលើធាតុទាំងនោះទេ ។ ខ្ញុំគ្រាន់តែអាចនៅទីនេះ សូមលើកឡើងពីសម្មតិកម្ម ហើយផ្តល់ជាសម្មតិកម្មកម្មជូនលោកចៅក្រមវិញ ។ សំណួរនេះ គឺមិនបានសួរ ឬក៏ធ្វើកោសល្យវិច័យនៅក្នុងពេលសម្ភាសនោះទេ ។

បុគ្គលដែលគាត់ចូលចិត្តបង្រៀន ហើយគាត់មានគំនិតនៅក្នុងការកសាង ហើយក៏គាត់មានមន្ទិលសង្ស័យ យើងក៏និយាយអំពីចំណុចនេះផងដែរ ។ គឺវាជាជំហរទាក់ទងទៅនឹងការបណ្តុះបណ្តាលជាការពិតទៅលើចំណុចហ្នឹង ។ គាត់បាននិយាយអំពីតួនាទីរបស់គាត់ជាអ្នកបណ្តុះបណ្តាលគេ ហើយខ្ញុំជឿថា គឺទេពកោសល្យបង្រៀនរបស់គាត់វាមានមែន ហើយគាត់ប្រើទេពកោសល្យនៅក្នុងការបង្រៀននិងបណ្តុះបណ្តាល ។ ហើយប្រហែលគាត់ប្រើទេពកោសល្យ និងសមត្ថភាពនេះនៅក្នុងមុខនាទីផ្សេងទៀត ដែលគាត់ធ្វើការបញ្ជូនចំណេះដឹង ហើយគឺគាត់បង្រៀនដោយ សុន សេន ។ ដូច្នេះហើយ តាមរយៈការអប់រំនោះហើយ ដែលគាត់បានសិក្សាស្វែងយល់ពី សុន សេន ។ នេះគឺជាអ្វីដែលខ្ញុំជម្រាបបានចំពោះចំណុចហ្នឹង ។

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** សូមអនុញ្ញាតបន្ថែលខ្លះដែរថា ក្នុងនាមលោក ឌុច ដែលពីដើមជាគ្រូបង្រៀនគណិតវិទ្យា ។ មុននឹងបានចេញធ្វើជាសាស្ត្រាចារ្យ តែងតែបានទទួលនូវការបណ្តុះបណ្តាលអំពីចិត្តគរុវិជ្ជា ហើយដែលក្នុងនោះហើយ ដែលអាចធ្វើឲ្យគាត់យល់មួយចំណែកដែរ អំពីបញ្ហាចិត្តសាស្ត្ររបស់កុមារ និងកុមារវ័យជំទង់ និងមនុស្សពេញវ័យ ។

[១១:៣២:៥៦]

**ស៖** មុនហ្នឹង នៅពេលដែលលោកស្រីធ្វើបទបង្ហាញ លោកស្រីបានជម្រាបថា ជនជាប់ចោទគាត់មិនបានបង្ហាញសញ្ញានៃការខូចអាការ:ណាមួយនោះទេ ហើយលោកស្រីបានពន្យល់អំពីបញ្ហាខូចអាការ:នេះ ហើយលោកស្រីអាចជួយពន្យល់បង្ហាញនេះបន្ថែមទៀតបាន ប្រសិនបើនៅខ្វះចន្លោះ ។

ខ្ញុំតាមការខ្ញុំយល់នោះ វាទាក់ទងទៅនឹងបញ្ហាខូចអាការ: ខ្ញុំបានសួរខ្លួនឯង នៅពេលដែលខ្ញុំអានរបាយការណ៍របស់លោកស្រី ជាពិសេសនៅក្នុងទំព័រទី៦០ លោកស្រីបានលើកឡើងថា ឌុច បានចូលរួមយ៉ាងសកម្មនៅក្នុងសហកម្ម ឬក៏ស្ថាប័នកសាងនោះ។ នៅស-២១ ជនរងគ្រោះត្រូវឲ្យសរសេរចម្លើយសារភាពរបស់ខ្លួន ដែលពេលខ្លះយើងមិនគួរឲ្យជឿទាល់តែសោះចម្លើយសារភាពនោះ ហើយ ឌុច មិនបានដឹងទៅលើបញ្ហានេះ ដោយមិនមានការផ្ទៀតផ្ទាត់ ដើម្បីធ្វើការបន្ទុះបន្ទាប់ជនរងគ្រោះ ហើយដកចេញនូវអត្តសញ្ញាណរបស់ពួកគេ ជំនួសនូវអត្តសញ្ញាណថ្មី គឺវាជាចំណុចមួយចំបាច់ ហើយឲ្យយើងចង់បានទៅលើចំណុចដូច្នេះ ។ ដូច្នេះ អ៊ីចឹងគឺថាវាជាវិធីសាស្ត្រមួយដែលគេអនុវត្តទៅលើករណីនេះ ឬក៏យ៉ាងម៉េច ហើយវាជាបញ្ហាទាក់ទងទៅនឹងការខូចអាការ: ជាពិសេសចំពោះបុគ្គលដែលគាត់ទទួលរងហើយបានន័យថា ពួកគេត្រូវតែឆ្លើយសារភាពទោះបីពួកគេមិនជាអ្នកដែលប្រព្រឹត្តក៏ដោយ តើវាទាក់ទងយ៉ាងម៉េចទៅនឹងបញ្ហាខូចអាការ:នេះ?

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្គៀលបូ)** ជាការពិត ខ្ញុំយល់សំណួររបស់លោកចៅក្រមយ៉ាងច្បាស់ វាជាការពិតបង្ហាញនៃចំណុចនេះ គឺវាកើតមានមែន ខ្ញុំសូមនិយាយឡើងវិញនៅទីនេះ យើងមិនមែនមកបញ្ជាក់ថាអ្វីដែលគាត់បានធ្វើនោះទេ។ ខ្ញុំសូមបញ្ជាក់សាជាថ្មី ក្នុងនាមជាអ្នកឯកទេស មិនមែនតួនាទីរបស់យើងក្នុងការបញ្ជាក់អំពីភាពត្រឹមត្រូវនៃអំពើរបស់គាត់នោះទេ ហើយបញ្ហាខូចអាការ:នេះ យើងអាចយល់តាមរយ:អត្ថន័យភេទ ។ យើងអាចនិយាយអំពីបញ្ហាខូចអាការ: វាមានទ្រឹស្តីនេះកើតឡើង វាមិនមែនកើតចេញពីលទ្ធផលនៃការវិភាគរោគសាស្ត្រនោះទេ វាមានការខូចអាការ:នៅពេល ដែលវាមានធាតុផ្សំមួយចំនួនកើតឡើងនៅក្នុងអារម្មណ៍របស់បុគ្គល ។ បានន័យថា ការបដិសេធ ការប្រទូសរ៉ាយរវាងការទទួល និងការបដិសេធការពិត ការចង់ឲ្យអ្នកផ្សេងគេ ជាការចង់ឲ្យគាប់ចិត្តទៅលើបុគ្គលផ្សេង ហើយព្យាយាមធ្វើអ្វីៗដើម្បីប្រយោជន៍របស់ខ្លួន និងសហគ្រាសក្រុមរបស់ខ្លួន ។ ទាំងអស់នេះហើយ ដូចអ្វីដែលខ្ញុំបានលើកឡើងពីមុន ។ ធាតុផ្សំទាំងអស់នេះ យើងអាចយល់ឃើញអំពីខូចអាការ: ប៉ុន្តែនៅពេលដែល ទាក់ទងទៅនឹងបញ្ហាចិត្តសាស្ត្រ បញ្ហាទាក់ទងទៅនឹងការបង្កើតទៅនឹងអត្តសញ្ញាណ គឺការខូច

អាការៈ គឺជាការសង្កេតមួយដែលយើងត្រូវធ្វើ ហើយយើងមិនដឹងថា តើវាកើតចេញពីណា ហើយការខូចអាការៈនោះ គឺវាមិនកើតឡើងចេញពីចំណុច ការបង្កើតអត្តសញ្ញាណនោះទេ ។ ហើយយើងត្រូវព្យាយាមថា តើបញ្ហាខូចអាការៈនេះ វានាំឲ្យបុគ្គលសម្តែងអាកប្បកិរិយាបែបនោះយ៉ាងដូចម្តេច? ដូច្នេះហើយទើបខ្ញុំបានរៀបរាប់បង្ហាញហ្នឹងនៅក្នុងរបាយការណ៍របស់ខ្ញុំ។

[១១:៣៧:៥៣]

យើងអាចលើកទស្សនទានខូចអាការៈនេះ ដែលវាជាវិធីប្រតិបត្តិការមួយនៅស-២១ ។ ខ្ញុំមិនមែនជាអ្នកប្រវត្តិវិទូនោះទេ ហើយខ្ញុំក៏មិនមែនអ្នកជំនាញក្នុងបរិបទខ្មែរក្រហមផងដែរ ហើយខ្ញុំមិនអាចពន្យល់ទៅលើករណីហ្នឹងទេ ។ ប៉ុន្តែ វានៅតែដូចទៅអ្វីដែលខ្ញុំបានពន្យល់ទៅនឹងការខូចអាការៈនោះអ៊ីចឹង។

**ស៖** ដូច្នេះនៅក្នុងចំណុចនេះម្តងទៀត ទាក់ទងទៅនឹងយន្តការការពារដែលលោកស្រីបានលើកឡើងទាក់ទងទៅនឹងភាពបដិសេធ ភាពចៀសវាងនោះ ហើយនិងការប្រទូសរ៉ាយរវាងការទទួល និងការបដិសេធការពិត ។ អ៊ីចឹងវាជាការបែងចែកដែលការដកខ្លួនចេញពីសកម្មភាពមួយចំនួន ឬក៏យ៉ាងម៉េច? ឧទាហរណ៍នៅក្នុងជំនុះជម្រះលើជនជាប់ចោទ គាត់បានលើកឡើងថា គាត់មិនបានចូលរួមដោយផ្ទាល់នៅក្នុងអំពើទារុណកម្មទាំងឡាយ ហើយគាត់បានលើកឡើងថា គាត់មិនបានសម្លាប់នរណាម្នាក់ដោយផ្ទាល់នោះទេ ។ គាត់បានលើកឡើងនូវឧទាហរណ៍មួយចំនួន ដែលវាជាចំណុចសំខាន់ដែលយើងត្រូវនិយាយឡើងវិញ គាត់បាននិយាយថា នៅថ្ងៃមួយនោះ នួន ជា បានសុំគាត់ឲ្យផឹកថ្នាំ ហើយនិងការសាកល្បងថ្នាំ ឲ្យយកថ្នាំឲ្យជនរងគ្រោះសាកល្បង ហើយថ្នាំដែលយកឲ្យទៅជនរងគ្រោះសាកល្បងនោះគឺវាជាថ្នាំពុល ដើម្បីជាការវាយប្រហារមួយ ហើយគាត់បានពន្យល់ថាគាត់បានលេបថ្នាំនោះវាជាថ្នាំគ្រាប់ ហើយថ្នាំគឺនោះត្រូវបានដកម្សៅពុលចេញ ហើយដាក់ម្សៅធម្មតាចូលទៅវិញ ។

ហើយគាត់ត្រូវបានគេផ្តល់ថ្នាំនោះដោយចេតនា ហើយគាត់ធ្វើការញ៉ាំថ្នាំ ហើយគាត់មានការរីករាយដែលជម្រាបប្រាប់អង្គសវនាការថា មនុស្សដែលទទួលថ្នាំនោះ គឺមិនមានការពុលនោះទេ ដោយសារគាត់បានចាត់ចែងដូរធាតុផ្សំនៅក្នុងថ្នាំនោះ ។ ដូច្នេះហើយ បុគ្គលទាំងអស់នោះ គឺនៅរស់រានមានជីវិតដោយសារការជួយនោះ ។ ដូច្នេះហើយគាត់បានពន្យល់ថា បុគ្គលដែលឃុំនៅស-២១ តាមការពន្យល់របស់គាត់មួយចំនួន គាត់ថាអ្នកទាំងអស់នោះត្រូវតែគេសម្លាប់ចោល ។ ដូច្នេះចំណុចនេះ វាមានភាពផ្ទុយគ្នា ។

ដូច្នេះយើងត្រូវលើកឡើងយ៉ាងម៉េច អំពីទិដ្ឋភាពខុសគ្នារវាងការដែលបដិសេធការពិតនោះ បានន័យថា វាជាការដកខ្លួនគាត់ពីសេចក្ដីពិត ឬក៏លាក់កំបាំងពីសេចក្ដីពិត ឬយ៉ាងម៉េច? ថាតើយើងអាចវិភាគយ៉ាងម៉េចតាមលក្ខណៈចិត្តសាស្ត្រ?

[១១:៤១:១៤]

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលប្ញ)** ជាការពិតយើងអាចធ្វើការពន្យល់បាន ។ ខ្ញុំមិនចង់លើកឡើងទស្សនទានច្រើននោះទេ ។ ប៉ុន្តែ ខ្ញុំសូមលើកឡើងអំពីទស្សនទានការបដិសេធ គឺការមិនទទួលយកនៅសកម្មភាពណាមួយ ។ ការបដិសេធនេះ គឺការមិនទទួលយកការចូលរួមនៅក្នុងសកម្មភាពណាមួយដើម្បីបញ្ជាក់ភាពត្រឹមត្រូវចំពោះខ្លួន នេះជាការទទួលយកអង្គហេតុតែមួយផ្នែកប៉ុណ្ណោះ ។ ឧទាហរណ៍ដែលលោកចៅក្រមបានលើកឡើងអម្បាញ់មិញនេះ ។ ខ្ញុំអាចធ្វើការប្រៀបធៀបឧទាហរណ៍នោះ ថាតើវាមានអ្វីអាចកើតឡើងនៅក្នុងករណីមួយចំនួនផ្សេង នៅពេលដំបូងប្រហែលជាគាត់អាចស្ថិតនៅក្នុងស្ថានភាពបដិសេធមួយ ។ ហើយនៅពេលដែលមានភស្តុតាងលើកជូនគាត់នោះ គាត់ចូលទៅដល់ដំណាក់កាលមួយទៀតដែលយើងហៅថា *ឌីនីហ្គេសិន* គឺការបដិសេធមួយកម្រិតទៀត ។

ដូច្នេះ ដំណុចទាំងអស់នេះ គឺជាធាតុដែលយើងយល់បានក្នុងអំឡុងពេលដែលមានការសម្ដែងឡើងវិញ ។ ដោយសារតែយើងមានវគ្គសម្ភាសច្រើននោះ គឺយើងបានដឹង ហើយបានឃើញពីដំណើរការសវនាការ ហើយខ្ញុំបានយល់ដំណាក់កាលបីនៅក្នុងជនជាប់ចោទ ។ នៅក្នុងដំណាក់កាលចំនួនបី ទី១ គឺការបដិសេធ យើងហៅថា *ឌីណាយអល* ទី២ គឺការបដិសេធ *ឌីនីហ្គេសិន* ទី៣ គឺការទទួលខុសត្រូវដោយខ្លួនឯង ។

ដូច្នេះហើយ វាជាវិធីមួយដែលដំណាក់កាលដំបូងមិនទទួលស្គាល់ទាំងស្រុងទៅលើភាពពិតប្រាកដជាក់ស្ដែង ហើយវាជាចំណុចយន្តការចិត្តសាស្ត្រ ហើយវាជាវិធីលាក់កំបាំងនូវការពិតមួយចំនួនចំពោះខ្លួនឯង ។

[១១:៤៣:៥៨]

**ស៖** នៅក្នុងចំណុចមួយគួរឲ្យចាប់អារម្មណ៍ នៅពេលដើមធ្វើកោសល្យវិច័យ លោកស្រីបានសួរជនជាប់ចោទឲ្យរៀបរាប់អំពីឈ្មោះបុគ្គលដែលត្រូវបានសម្លាប់នៅស-២១ ហើយលោកស្រីបានលើកឡើងថា ឌុច មានការពិបាកក្នុងការរៀបរាប់ឈ្មោះទាំងអស់នោះ ។ ហើយវាជាលក្ខណៈមួយចម្លែកចំពោះបុគ្គលដែលគាត់មានគំនិតបញ្ញា ហើយគាត់មានការចងចាំបានល្អ ប៉ុន្តែគាត់បានលើកឡើងថា អ្នក

ស្លាប់នៅស-២១ មានតែ២០០នាក់ទេ ។ ដូច្នេះហើយវាចំណុចមួយដែលមានលក្ខណៈចម្លែក ។ តើវាចំណុចនេះវាបានបង្ហាញអំពីសញ្ញា *ឌីណាយអល* គឺការបដិសេធដំណាក់ដំបូង បន្ទាប់មក *ឌីនីហ្គេសិន* បដិសេធទីពីរ ហើយនិងដំណាក់កាលមួយទៀតដែរឬទេ ទាក់ទងទៅនឹងការចងចាំរបស់គាត់លើអង្គហេតុទាំងអស់នោះ?

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលបូ)** ជាការពិត វាជាដំណើរការ ដំណើរការនោះមែន ។ នៅពេលដែលយើងធ្វើកោសល្យវិច័យនោះ នៅពេលដែលយើងឃើញ និងជួបជនជាប់ចោទ យើងឃើញមានភាពមិនទុកចិត្តមួយចំនួន ហើយអាចនិយាយដូច្នេះ ។ ហើយយើងបានលើកឡើងអំពីបរិបទនៃការស្វែងរកយុត្តិធម៌ ហើយគាត់នៅមុនដំបូង គាត់មានលក្ខណៈមិនទុកចិត្ត ហើយគាត់ចាប់ផ្តើមបន្ថយទៅលើភាពមិនទុកចិត្តនេះបន្តិចម្តងៗ ហើយចំនួននោះប្រហែលជាគាត់អាចដឹង ។

ដូច្នេះអ្វីដែលចង់លើកឡើងនៅទីនេះ គឺដំណើរការវាមានការផ្លាស់ប្តូរ ហើយសហសេវិករបស់ខ្ញុំនេះ គឺគាត់យល់ស្របទៅលើចំណុចហ្នឹងដែរ ហើយយើងអាចឃើញអំពីយន្តការ *ឌីណាយអល ឌីនីហ្គេសិន* ហើយនិងការចោទប្រកាន់លើខ្លួនឯង ។ ដូច្នេះដំណើរការនេះ វាវិវឌ្ឍន៍នៅក្នុងដំណើរការកោសល្យវិច័យរបស់យើង ។

នៅពេលថ្មីៗនេះ ហើយគាត់ហាក់ដូចជាបន្ថយនូវការបដិសេធរបស់គាត់ ហើយគាត់មានភាពទុកចិត្ត នៅលើកធាតុផ្សំអង្គហេតុមួយចំនួនផ្សារភ្ជាប់ទៅនឹងជីវិតរបស់គាត់ដោយបញ្ជាក់អំពីវិប្បដិសារីរបស់គាត់ផងដែរ ប៉ុន្តែចំណុចទាំងអស់នេះ គាត់មិនបានលើកឡើងទេតាំងពីយើងធ្វើដំណើរការដំបូងទៅលើការកោសល្យវិច័យរបស់យើង ។

[១១:៤៦:៤៤]

**ស៖** វាហាក់ដូចជាមានការពិបាកក្នុងការយល់អំពីបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ ។ ខ្ញុំមិនដឹងថា តើលោកស្រីប្រើពាក្យនេះត្រឹមត្រូវដែរឬទេ? វាមានលក្ខណៈមិនច្បាស់លាស់ ចំពោះខ្ញុំ យើងកំពុងតែសិក្សាទៅលើបុគ្គលដែលគាត់អាចនៅពេលជាមួយគ្នា អាចបង្ហាញអំពីភាពស្អប់ខ្ពើម ភាពអាម៉ាស់នូវអ្វីដែលគាត់បានធ្វើ ហើយគាត់បានលើកឡើងថា គាត់គឺជាបុគ្គលដែលមានភាពក្តៀវក្លា ហើយគាត់អាចសម្តែងសកម្មភាពហួសពីការរំពឹងទុករបស់បុគ្គលដទៃ ។ ដូច្នេះ ថាតើវាការវិភាគទៅលើបដិភាពយ៉ាងម៉េចដែរទៅលើពាក្យថា *អែមប៊ីវ៉ាលែនស៍* (ambivalence) នេះ?

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលបូ)** បដិភាពគឺ *អែមប៊ីវ៉ាលែនស៍* គឺជាភាពផ្ទុយគ្នារវៀងចំណុចពីរនៅក្នុងខ្លួនបុគ្គល ។ វាជាការកើតឡើងទៅលើធាតុផ្សំពីរ ហើយវាមានភាពផ្ទុយគ្នា ។ យើងអាចធ្វើការពន្យល់ទៅលើធាតុមួយនេះ ជាដំបូងដោយយើងត្រូវពិនិត្យអំពីការចងសម្ព័ន្ធភាពនៅក្នុងខ្លួនរបស់ជនជាប់ចោទ យើងឃើញមានការគោរពឱវាទពីដំបូង ហើយគាត់បានបំពេញតួនាទីរបស់គាត់ ហើយគាត់មិនចោទសួរទៅលើសកម្មភាពនិងតួនាទីរបស់គាត់ នេះជាផ្នែកមួយនៃការគោរពឱវាទ ។ ការគោរពទៅលើបញ្ហា ហើយនិងភាពដែលវាជាសម្ព័ន្ធភាពនៅក្នុងក្រុម ។ ហើយគាត់មិនអាចធ្វើឲ្យភាពសង្ស័យរបស់គាត់នៅស្ងៀម ។

ដូច្នេះ ធាតុទាំងពីរនោះគឺវាមាននៅក្នុងខ្លួនគាត់ ។ ដូច្នេះ វាអាចកើតមាននៅក្នុងចិត្តសាស្ត្ររបស់បុគ្គល ។ ដូច្នេះយើងអាចមានភាពស្អប់ស្ពើម ហើយនៅពេលជាមួយគ្នាក៏មានភាពក្តៀវក្តាហួសហេតុ ។ នៅទីនេះយើងព្យាយាមបង្ហាញអំពីភាពស្មោះស្ម័គ្រចំពោះបក្ស ឬក៏ចំពោះគំនិត ឬក៏ចំពោះមេរបស់ខ្លួនដែលខ្លួនគោរពនងឲ្យតម្លៃ ។ ឧទាហរណ៍ថា មេ សុន សេន និងមេផ្សេងៗទៀតអ៊ីចឹង ។ ខ្ញុំមិនដឹងថាខ្ញុំឆ្លើយតបទៅនឹងសំណួររបស់លោកចៅក្រម ឬក៏យ៉ាងម៉េចទេ ។ តើលោកអ្នកជំនាញចង់បន្ថែមទៀតដែរឬទេ?

អាចបន្ថែមលើធាតុទាំងពីរ គឺការក្តៀវក្តា និងមនោគមវិជ្ជា គឺជាអ្វីដែលដែលវាជាធ្វើឲ្យភាពសង្ស័យរបស់យើងនៅស្ងៀម ។ ជាទូទៅ នៅពេលដែលយើងមានបដិភាព តើមានអ្វីកើតឡើង? យើងមិនអាចសន្ថិដ្ឋានស្ថិតនៅក្នុងស្ថានភាពបដិភាពនេះយូរទេ ។ ដូច្នេះ យើងត្រូវតែជ្រើសរើសរកយន្តការការពារ និងរកដំណោះស្រាយ ។ ដូច្នេះយើងនឹងដាកទៅរកធាតុមួយទៀត ឬក៏ធាតុណាផ្សេង ។ ដូច្នេះហើយទើបដំណើរការបដិសេធ យើងហៅថា *ឌីណាយអល* នោះវាចាប់ផ្តើមមាននៅពេលនោះ ។

[១១:៥០:៤៨]

ដូច្នេះហើយ វាទាក់ទងទៅនឹងការមិនលើកឡើងអំពីការដែលខ្លួនសង្ស័យ ហើយវានាំទៅដល់ការបញ្ជាក់អំពីភាពត្រឹមត្រូវរបស់ខ្លួនទៅលើភាពសង្ស័យរបស់ខ្លួន ហើយអ្វីដែលយើងមិនទទួលស្គាល់ ។ ប្រសិនបើយើងមិនអាចដាកចេញឲ្យផុតពីធាតុបដិភាពនោះទេ វានឹងបង្កឲ្យមានអាការៈឈឺទៅលើរូបរាងកាយ ឬក៏វាបណ្តាលឲ្យមានការបាក់ផ្លូវចិត្ត ឬក៏ធ្លាក់ផ្លូវចិត្ត និងការខូចខាតផ្នែកស្មារតី ។ ប៉ុន្តែ នៅក្នុងករណីនេះ វាមិនកើតឡើងនោះទេ ។

ខ្ញុំគិតថា ឌុច គាត់ព្យាយាមកសាងទៅលើធាតុបដិសេធទៅលើការពិត ហើយចៀសវាងអំពីភាព

សង្ស័យរបស់គាត់ ។ ដូច្នេះ គឺធាតុទាំងឡាយដែលគាត់បានប្រឹងប្រែងធ្វើ ។

**សៈ** ខ្ញុំមានសំណួរមួយទៀត ដែលខ្ញុំចង់សួរទៅលើលោកជំនាញ កា ស៊ុនបូណាត ហើយយើងឃើញប្រើ ការប្រើពាក្យជាញឹកញាប់នៅក្នុងរបាយការណ៍របស់លោក ហើយក៏ឮនៅក្នុងការថ្លែងសេចក្តីសក្ខីកម្មនេះផងដែរ គឺទាក់ទងទៅនឹងការលះបង់ ។ គឺខ្ញុំចង់សួរអំពីការលះបង់នៅក្នុងខ្លួនរបស់ជនជាប់ចោទនៅពេលដែលគាត់និយាយថា នៅពេលដែលខ្ញុំចូលបដិវត្តន៍ ខ្ញុំត្រៀមខ្លួនលះបង់សម្រាប់មូលហេតុនិងបុព្វហេតុជាតិ ហើយយើងក៏ឃើញមានបញ្ហាទាក់ទងទៅនឹងការលះបង់ចំពោះដំណើរការនៅស-២១ ផងដែរ វាទាក់ទងទៅនឹងការលះបង់របស់បុគ្គល ដើម្បីកសាងគ្រឹះសង្គមថ្មីមួយ ។ ហើយខ្ញុំឆ្ងល់ទៅលើបញ្ហាលះបង់នេះ ដោយសារជនជាប់គាត់មិនបានបញ្ជាក់ទៅលើចំណុចនេះឲ្យបានច្បាស់លាស់ ឬក៏វាជាការបកស្រាយរបស់ខ្ញុំតែប៉ុណ្ណោះ ។ គាត់បង្ហាញថា គាត់មានការជាប់ពាក់ព័ន្ធទៅនឹងធាតុលះបង់ចំពោះសង្គម ។ ការលះបង់ចំពោះការទិតៀន ហើយគាត់មានភាព ហើយមានឆន្ទៈទទួលយកទៅលើការដាក់ទោសគាត់ ទទួលខុសត្រូវតែម្នាក់ឯង ។

ដូច្នេះហើយយើងឃើញថា វាលើក មានការលើកឡើងនៅក្នុងស្ថានភាពផ្សេងៗគ្នា ។ យើងឃើញយន្តការទាំងអស់នេះ ។ ដូច្នេះ តើធាតុលះបង់នេះ វាមានសារសំខាន់នៅក្នុងបញ្ហាវប្បធម៌ដែរឬទេ ហើយវាមានការពាក់ព័ន្ធណាមួយ ឬឥទ្ធិពលណាមួយចំពោះជនជាប់ចោទដែរឬទេ?

**ឆៈ (វេជ្ជ. កា ស៊ុនបូណាត)** ខ្ញុំសូមឆ្លើយបំភ្លឺទៅនឹងសំណួររបស់លោកដែលបានសួរថា ការលះបង់ *សាគ្រីហ្វីស៊ីស (Sacrifice)* ។ នៅក្នុងប្រពៃណីខ្មែរយើង យើងទទួលការអប់រំពីឪពុកម្តាយពីសង្គម ពីសាលារៀន ពីព្រះពុទ្ធសាសនា ឲ្យមានការចែករំលែកជាមួយអ្នកជុំវិញយើង ហើយមិនត្រឹមតែចែករំលែកទេ គឺយើងត្រូវលះបង់ ដើម្បីជួយដល់អ្នកដែលក្រខ្សត់ អ្នកដែលទុរគត ដូចពាក្យស្លោកថា "អ្នកប្រាជ្ញរក្សាខ្លៅ ដូចសំពៅនៅសំប៉ាន" ទាំងនេះ គឺជាការអប់រំមួយឲ្យយើងចេះធ្វើការលះបង់ ដើម្បីជួយអ្នកក្រខ្សត់ ហើយកុំគិតតែខ្លួនឯង ។ ប៉ុន្តែ នៅក្នុងចលនាកុម្មុយនីស្តពាក្យថា "លះបង់" នេះមានន័យធ្ងន់ជាងនេះ ព្រោះថាដើម្បីនឹងឲ្យចលនាកុម្មុយនីស្តឈ្នះ អ្នកកាន់អំណាចក្នុងប្រទេសគេត្រូវធ្វើការប្រយុទ្ធការតតាំង ហើយដែលជាការមួយប្រឈមនឹងការប្តូរអាយុជីវិត ។ ហេតុដូច្នេះហើយបានជារាល់ករណីដែលគេបានចូលរួមនៅក្នុងចលនាកុម្មុយនីស្តគេដឹងជាមុនស្រេច គឺគេត្រូវតែបូជាជីវិត ។ គឺបានសេចក្តីថា លះបង់អាយុជីវិត លះបង់ផលប្រយោជន៍ខ្លួនឯង ដើម្បីឆ្លងកាត់រាល់ការលំបាកទោះជាត្រូវស្លាប់ក៏ដោយ ដែលក្នុងពាក្យសម័យនោះគេនិយាយថា "ពលីជីវិត" ហើយទាំងនេះដើម្បីផលប្រយោជន៍រួមផល

ប្រយោជន៍របស់ប្រជាពលរដ្ឋដែលជាអ្នករងទុក្ខវេទនានិងអ្នកក្រីក្រ ។

[១១:៥៧:៥៧]

នេះជាន័យទូទៅដែលពាក្យថា "បូជាជីវិតនៅក្នុងការងាររបស់ចលនាកុម្មុយនីស្ត" ប៉ុន្តែត្រង់ន័យថា ក្នុងន័យថា បូជាជីវិត ឬក៏លះបង់អាយុជីវិតនៅក្នុងការងាររបស់ស-២១ ក្នុងនេះខ្លួនខ្ញុំក៏មិនបានយល់ច្បាស់ដែរ ពីព្រោះសភាពការណ៍ក្នុងស-២១ នេះវាមានការពិបាកយល់ ។ ហើយមិនបានយល់ទៀតថា តើន័យដែលបានបញ្ជាក់ថា ធ្វើការបូជាក្នុងបំណងអី ក្នុងរូបភាពជាអីទេ ។

**ស៖** ខ្ញុំជឿថា ការលះបង់នេះធ្វើឡើងដោយស្ម័គ្រចិត្តនោះ គឺថាដោយសារតែមានគោលដៅច្បាស់លាស់ ។ អ៊ីចឹងហើយដោយសារតែការលះបង់នេះ គឺដាក់បន្ទុកមួយធ្ងន់ទៅលើជនរងគ្រោះដែលជាទិសដៅហ្នឹង ។ អ៊ីចឹងថា ការលះបង់នេះបែបនេះក៏មានទេនៅក្នុងទំនៀមទម្លាប់វប្បធម៌ខ្មែរដែលនិយាយអំពីការលះបង់ ឬក៏ពលីកម្មជាមនុស្ស ជាសាច់ឈាមដើម្បីបុព្វហេតុអ្វីមួយនោះ?

**ឆ៖ (វេជ្ជ.កា ស៊ុនបូណាត)** ខ្ញុំមិនយល់ច្បាស់អំពីសំណួររបស់លោក ដែលនិយាយថា ការបូជាជីវិតដែលត្រូវបានគេបង្ខំទៅលើអ្នកជនរងគ្រោះ ។ តើលោកអាចបញ្ជាក់ឡើងវិញឲ្យបានច្បាស់ជាងនេះបន្តិចទេ?

**ស៖** ខ្ញុំគិតថា លោកបានពន្យល់ពីចំណុចមួយគួរឲ្យចាប់អារម្មណ៍ ដែលថាយើងថាអាចលះបង់ដោយខ្លួនឯង ថាតើមានន័យដូចម្តេចនៅពេលដែលយើងចូលរួមបក្សកុម្មុនីយស្ត ហើយនៅពេលដែលយើងនិយាយអំពីស-២១ ក៏មានហេតុការណ៍ដែលថា គឺជាម៉ាស៊ីនមួយដែលថានៅក្នុងនោះមានមនុស្សដែលលះបង់ដើម្បីធ្វើការងារនោះ ។ សំណួររបស់ខ្ញុំៗចង់ដឹងថាតើការទម្លាប់ការអនុវត្តការលះបង់ហ្នឹងធ្វើឡើងដោយស្ម័គ្រចិត្ត ឬមិនស្ម័គ្រចិត្តដែលថា ដាក់ទម្ងន់ ឬក៏ដោយមានគោលបំណងមួយដែលថាបង្កើតនូវសង្គមថ្មីមួយថាតើដំណើរការក្នុងាការគិតគូរ ហើយបែបហ្នឹងមានទេនៅក្នុងវប្បធម៌ខ្មែរ ឬក៏ទំនៀមទម្លាប់ខ្មែរនោះ?

[១២:០១:៣៣]

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** រូបភាពនៃការលះបង់នៅក្នុងមន្ទីរស-២១ ដែលលោកលើកឡើងនេះ ដែលថាជាការលះបង់ក្រោមការគាបសង្កត់ ឬដោយស្ម័គ្រចិត្តនោះ ជាទូទៅសភាពការណ៍បែបនេះនៅក្នុងប្រទេសកម្ពុជាពីមុនមកមិនដែលមានទេ ។ យើងមានតែការលះបង់ដែលស្ថិតនៅក្នុងរូបភាពមនុស្សធម៌ ការលះបង់ដើម្បីជួយអាយុជីវិតគេ ការលះបង់ដើម្បីជួយស្រោចស្រង់អ្នកដែលរងគ្រោះ អ្នក

ក្រលំបាក ឬក៏អ្នកទទួលការឃាយឃីពីអ្នកដទៃ។ តែការលះបង់ក្នុងរូបភាពដែលអនុវត្តនៅក្នុងមន្ទីរស-២១ កន្លងមកដូចជាមិនដែលបានឃើញទេ ហើយជាពិសេសគោលការណ៍នៃការលះបង់យើងច្រើនតែធ្វើទៅតាម ដែលហៅថា សីលធម៌ និងតាមគន្លងព្រះពុទ្ធសាសនា ។

**សៈ** យើងមានសំណួរមួយទៀតទាក់ទងទៅនឹងចំណុចនេះ ។ ចំពោះជនរងគ្រោះ ចំណុចនេះទាក់ទងទឹងការសោកស្តាយដែលសម្តែងឡើងដោយជនជាប់ចោទ គឺថាពេលមួយចំនួនច្រើនគាត់បានសម្តែងពីវិប្បដិសារីរបស់គាត់ ហើយលោកនិយាយបញ្ហានៃភាពស្មិទ្ធស្នាលរបស់គាត់នោះ គឺមិនពិនិត្យឃើញមាននៅក្នុងជនជាប់ចោទទេ ពីព្រោះថាជាកត្តាមួយដែលវាកើតឡើងរកឃើញថា វាឆ្ងាយពីអ្វីនៃពីការសម្តែងនូវការសោកស្តាយហ្នឹង គឺថាជនជាប់ចោទគឺការជ្រើសរើសរបស់ជនជាប់ចោទក្នុងការៗចងសម្ព័ន្ធទៅនឹងសហគមន៍មនុស្សដែលខ្លាំង ឬក្រុមដែលខ្លាំង ដែលជាក្រុមដែលគាត់ជឿទុកចិត្ត ។ ហើយរបាយការណ៍នោះបញ្ជាក់ថា ជាឧទាហរណ៍ ជានជាប់ចោទនោះគឺក្រុមដែលមានអំណាច គឺអាចមានតែជាក្រុមសហគមន៍សាសនាគ្រិស្ត ឬក៏នៅបស្ចឹមប្រទេស ឬយុត្តិធម៌-- ប្រព័ន្ធយុត្តិធម៌អន្តរជាតិ ។

ដូច្នេះ សំណួរខ្ញុំទៅលោក ថាតើមានន័យសម្រាប់ជនជាប់ចោទវិញ ថាតើៗគាត់អាច មិនអាចធ្វើអ្វីបានទេ បើមិនផ្សារភ្ជាប់ទៅនឹងសហគមន៍នោះ? តើគាត់មិនអាចធ្វើអ្វីបានដោយខ្លួនឯងទេ គឺថាតើតាមរយៈការសម្តែងវិប្បដិសារីនេះ តើគាត់អាចនឹងធ្វើចិត្តរបស់គាត់នឹងផ្សារភ្ជាប់ទៅនឹងសង្គមដូចដែលខ្ញុំលើកឡើងខាងដើមហ្នឹងដែរឬទេ?

[១២:០៥:០៨]

**ឆៈ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលបូ)** ហើយតាមការនិយាយទូទៅ គឺថាយើងមានសហគមន៍មួយចំនួនគឺទាក់ទងថា យើងចង់ផ្សារភ្ជាប់ថា យើងត្រូវចង់នៅក្រុមណា ឬសហគមន៍ណា ។ យើងអាចជឿជាថាយើងជាម្នាក់ឯង យើងមិនស្ថិតនៅក្នុងសហគមន៍ណា អានេះជាគំនិតនៅក្នុងបស្ចិមប្រទេស ប៉ុន្តែនៅក្នុងបរិបទសង្គមកម្ពុជាវិញ គឺថាម្នាក់ត្រូវតែជាផ្នែកសង្គមគ្រួសារ ។ ប៉ុន្តែចំពោះ ឌុច វិញ គាត់មិនបាន--មិនអាចរស់បានដោយមិនមានមនោគមវិជ្ជា ឧត្តមគិតឬក៏ជំនឿទេ ។ ខ្ញុំសូមបញ្ជាក់ម្តងទៀត ហើយមិនមែនជាអ្វីគ្រប់គ្រាន់ដែលថា យើងយល់ពីការនេះ ទៅតាមការវិភាគទៅលើការវាយតម្លៃពីប្រវត្តិរូបរបស់គាត់ ។ ប៉ុន្តែមានចំណុចពីរ ។ ទីមួយ គឺត្រូវតែមានជំនឿទៅលើអ្វីដែលជាក់លាក់នោះ ។ ប៉ុន្តែទីពីរ នេះជាចំណុចមួយដែលមានសារសំខាន់ បន្ទាប់មកការស្ថិតនៅក្នុងសហគមន៍ណាមួយ មិនថាតើវាទាក់ទងទៅនឹងបញ្ហាមួយនោះ គឺថាដោយប្រាកដនោះ គឺថាគាត់បានប្តូរពីការសម្ព័ន្ធទៅជាមួយលទ្ធិកុម្មុយនីស្ត

គឺថាគេបានបំភ្លេចចោលនូវគំនិតជាបុគ្គលនិយមនោះរួចទៅហើយ ។ អ៊ីចឹងហើយបន្ទាប់មកគាត់បានប្តូរទៅជាក្រុមនៅក្នុងក្រុមមួយទៀត ហើយជាជម្រើសរបស់គាត់ ដែលគិតថាមានបញ្ហាប្រឈមមួយចំនួនដែលនាំឲ្យគាត់គិតដូចជា មានក្រុមខាងនីកាយសាសនាគ្រិស្តហ្នឹងមានច្រើន ។

[១២:០៧:១៩]

អ៊ីចឹងហើយខ្ញុំបានដកស្រង់សម្តីគាត់ គាត់និយាយថា "អ្នកដែលបានឆ្លងកាត់ខាងលទ្ធិកុម្មុយនីស្តមួយចំនួន ចំពោះគាត់ការជ្រើសរើសយកក្រុមមួយដែលថា មានជ័យជម្នះលើលទ្ធិកុម្មុយនីស្តបាន ហើយគាត់ជ្រើសរើសយកក្រុមសាសនាមួយហ្នឹង ។" អ៊ីចឹងហើយនៅក្នុងដំណើរការគិតគូររបស់គាត់ដែលទាក់ទងនឹងការជ្រើសរើសក្រុមនោះ គឺគាត់យកក្រុមណាដែលបុគ្គលម្នាក់ៗដែលត្រូវតែមានដូចជានៅក្នុងគ្រិស្តសាសនាអ៊ីចឹង មិនមែនជាក្រុមជាសហគមន៍គ្រិស្តសាសនាទេ ប៉ុន្តែ បុគ្គលម្នាក់ៗមានទំនាក់ទំនងជាមួយនឹងព្រះជាម្ចាស់ ។ ដូច្នោះហើយដែលថា វាមានការកែប្រែប្រព័ន្ធទាំងស្រុងអំពីសង្គមកុម្មុយនីយស្តទៅជាសង្គមអ្នកគ្រិស្តសាសនាវិញ ដែលថានៅក្នុងក្រុមនោះគឺវាជាប្រធានបទមួយដែលស្ថិតនៅក្នុងការផ្សារភ្ជាប់ខ្លួនរបស់គាត់ជាមួយនឹងព្រះ ។ អ៊ីចឹងគឺថា វានាំឲ្យមានចំណុចមួយទៀត ទាក់ទងទៅនឹងការព្យាបាលជំងឺផ្លូវចិត្ត អ៊ីចឹងហើយយើងអាចនឹងពិនិត្យមើលទៅតាមលក្ខខណ្ឌមួយចំនួននោះ ។

[១២:០៨:៤១]

**ស៖** ខ្ញុំមានសំណួរចុងក្រោយមួយនៅក្នុងរបាយការណ៍របស់អ្នកជំនាញនោះ គឺថាយើងសង្ឃឹមថាការវាយតម្លៃចិត្តសាស្ត្រនេះ ដែលទាក់ទងទៅនឹងបទឧក្រិដ្ឋនយោបាយ និងជួយពន្យល់អំពីដំណើរជីវិតរបស់ជនជាប់ចោទ ដែលថានេះគឺវប្បធម៌មួយការគោរពការសម្រេចធ្វើតាម ហើយការទទួលសម្តែងឬក៏ការកាន់កាប់នូវអំណាច ហើយនិងការភ័យខ្លាច ហើយនិងតម្រូវការនៃការផ្សារភ្ជាប់ទៅនឹងក្រុមនោះ។ តើអ្នកជំនាញអាចប្រាប់យើងបាន ថាតើយល់ដូចម្តេចថាតើការបាត់បង់នៃការយល់ដឹង ឬក៏សម្បជញ្ញៈយល់ដឹងអំពីអំពើដែលខ្លួនបានសម្រេច តើវាមានន័យដូចម្តេចតាមផ្លូវចិត្តសាស្ត្រ?

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលបូ)** គឺថាការបាត់បង់នូវការយល់ដឹងពីសម្បជញ្ញៈនោះ គឺអ្វីៗដែលយើងបញ្ជាក់អំពីការលះបង់គឺថាការបាត់បង់សម្បជញ្ញៈនោះ គឺថាគេទទួលស្គាល់ថាវាស្ថិតនៅក្នុងចិត្តសាស្ត្ររបស់មនុស្ស។ កាលណាមនុស្សម្នាក់មិនអាចធ្វើអ្វីបានដោយខ្លួនឯង ត្រូវតែធ្វើក្នុងលក្ខណៈសមូហភាពនោះ ។ ប៉ុន្តែវាមានការពិភាក្សាលើបញ្ហានេះ ប៉ុន្តែយើងពិនិត្យមើលកត្តាយុត្តិធម៌ វប្បធម៌ ។ ក្នុងវប្បធម៌មួយចំនួននោះ ការពិភាក្សានេះ គឺមានលក្ខណៈចម្លែកទៅវិញ ។ សេចក្តីសន្និដ្ឋាននោះ គឺថាអាចនឹងជា

ប្រភេទមួយគួរឲ្យងាយយល់នឹងគឺ ចំពោះវប្បធម៌បស្ចិមប្រទេស ពីព្រោះថាសញ្ញាណអំពីជនជាប់ចោទនេះ គឺទាក់ទង់ទៅនឹងកត្តាមួយចំនួនក្នុងវប្បធម៌ ដែលគាត់ផ្សារភ្ជាប់ទៅពិភពខាងក្រៅកុម្មុយនីស្តជាដើមនោះ ។

[១២:១១:០២]

ខ្ញុំមិនបានបញ្ជាក់នៅក្នុងរបាយការណ៍ទេ ពីអង្គហេតុមួយដែលថា ជាអ្នកឃ្លាំមើល ហើយនិងការលះបង់ពីភាពជាបុគ្គល ហើយការមិនដឹងពីខ្លួនឯង ការគោរពខ្លួនឯងហ្នឹង គឺយើង-- ហើយយើងថា យើងស្ថិតនៅក្នុងសហគមន៍ក្រុមមួយជាជាងថា យើងជាខ្លួនឯង យើងគិតថាអាចជាអ្នកចៅក្រម ជាអ្នកបាល់ទាត់ ប៉ុន្តែយើងភ្លេចគិតថាយើងខ្លួន ។ ប៉ុន្តែ គឺទស្សនៈវិស័យដែលថា យើងជាសមាជិកនៃក្រុម ប៉ុន្តែទស្សនៈផ្លូវចិត្តវិញ គឺថាវាត្រូវមានការផ្សារភ្ជាប់ពីបុគ្គលម្នាក់ៗទៅនឹងក្រុមនោះ ដោយសារតែមិនបានដឹងអំពីចំណុចនេះ ជាការមួយដែលថាវាមានគ្រោះថ្នាក់ ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណចំពោះការពន្យល់នេះ ខ្ញុំមិនមានសំណួរអ្វីទៀតទេ ចំពោះអ្នកជំនាញ ហើយនិងលោកសាស្ត្រាចារ្យនោះ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងត្រូវពិសាអាហារថ្ងៃត្រង់ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាអាហារថ្ងៃត្រង់ ។ អង្គជំនុំជម្រះនឹងលើកទៅបន្តនៅរសៀលនេះ ចាប់ពីម៉ោងមួយ សាមសិបនាទី ។

អនុរក្សមន្ទីរឃុំឃាំងនាំជនជាប់ចោទ ទៅកាន់បន្ទប់រងចាំ ហើយឲ្យនាំជនជាប់ចោទមកកាន់សាលសវនាការវិញឲ្យបានមុនម៉ោងមួយ សាមសិបនាទីរសៀលនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១២:១២នាទី ដល់ម៉ោង ១៣:៣០នាទី]*

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសាវនាការ ។

អញ្ជើញ តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**លោក អានីស អះមេដ៖**

លោកចៅក្រមខ្ញុំស្នើថា នៅក្នុងថ្ងៃនេះសូមផ្តល់ឲ្យយើងប្រាំទៅប្រាំពីរនាទី ដើម្បីឆ្លើយតបទៅនឹងសំណើរបស់មេធាវីការពារក្តីដែលបានលើកឡើងនៅព្រឹកមិញនេះ មុនពេលដែលអ្នកជំនាញចូលមកដល់ ដូច្នេះខ្ញុំស្នើសុំរយៈពេលប្រាំទៅប្រាំពីរនាទី ដើម្បីឆ្លើយតបនៅក្នុងដំណាក់កាលណាមួយពេលហ្នឹង ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះនឹងរៀបចំជូនដល់សហព្រះរាជអាជ្ញា ដើម្បីឆ្លើយតបទៅនឹងការលើកឡើងរបស់មេធាវីការពារក្តីដែលបានលើកឡើងពីព្រឹកមិញ ប៉ុន្តែអង្គជំនុំជម្រះកំពុងតែពិចារណាថាតើពេលវេលាណាមួយសមស្របសម្រាប់ព្រះរាជអាជ្ញានោះ ។

ជាកិច្ចបន្តថាតើអស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីត្រូវសួរដល់អ្នកជំនាញទាំងពីររូបនេះដែរឬទេ? បើមានសូមអញ្ជើញបាទ ។

សូមអញ្ជើញលោកស្រីចៅក្រម ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

**ស៖** សូមអរគុណលោកប្រធាន ។ ខ្ញុំមានសំណួរមួយចំនួនតូចតែប៉ុណ្ណោះក្រោយពីការពន្យល់យ៉ាងក្បោះក្បាយកាលពីព្រឹកមិញរបស់អ្នកជំនាញ ហើយនិងក្រោយពីបានស្តាប់ចម្លើយឆ្លើយតបទៅនឹងលោកចៅក្រម ។ លោក លោកស្រីបានលើកឡើងនៅព្រឹកមិញពេលដែលផ្តល់សក្ខីកម្មថា មេរបស់ជនជាប់ចោទ សុន សេន បានបណ្តុះបណ្តាលគាត់ផ្នែកគរុវិទ្យា អ៊ីចឹងតើសុំឲ្យលោកជួយពន្យល់ពង្រីកបន្ថែមទៅលើចំណុចហ្នឹងបានដែរឬទេ? ថាតើវិធីសាស្ត្រគរុវិទ្យានោះបានបង្រៀនឲ្យគាត់ធ្វើការងារ យ៉ាងម៉េចនៅក្នុងកន្លែងរបស់គាត់? ឬក៏វាជាវិធីសាស្ត្រដឹកនាំយ៉ាងម៉េចដើម្បីឲ្យជនជាប់ចោទអាចយកទៅប្រើប្រាស់នៅក្នុងការងារ និងមុខនាទីរបស់គាត់?

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** ខ្ញុំសូមឆ្លើយទៅនឹងសំណួររបស់លោកស្រី។ កាលពីព្រឹកមិញខ្ញុំបាននិយាយថាលោក ឌុច មុននឹងលោកបានទៅធ្វើជាសាស្ត្រាចារ្យ ផ្នែកខាងគណិតវិទ្យា លោកបានឆ្លងកាត់ការបណ្តុះបណ្តាលផ្នែកខាងគរុវិទ្យាដែលក្នុងនោះគេមានបញ្ចូល អំពីចិត្តគរុកោសល្យ ។ តែខ្លួនខ្ញុំមិនបានបញ្ជាក់ថា លោក សុន សេន ជាអ្នកបង្រៀនទេ ។ ហើយការដែលគេបង្រៀនអំពីគរុកោសល្យ គឺជាការធ្វើឲ្យគ្រូយល់អំពីចិត្តសាស្ត្រក្មេង វ័យជំទង់ ។ល។ ដើម្បីធ្វើការបង្រៀនឲ្យសមទៅតាមនឹងចិត្តសាស្ត្រចរិតរបស់ក្មេងនីមួយៗ

[១៣:៣៤:០០]

**ស៖** សូមអរគុណ ។ ខ្ញុំបានយល់ច្រឡំទៅលើបរិបទ និងយោបល់ដែលលោកបានផ្ដល់ជូនតែប៉ុណ្ណោះ ។ ព្រឹកមិញលោកបានរៀបរាប់ថា ជនជាប់ចោទទទួលរងគ្រោះពីបញ្ហាចិត្តសាស្ត្រជាច្រើន ទោះបីជាលោកបានបញ្ជាក់យ៉ាងច្បាស់ថា គាត់មិនមានជំងឺវិកលចរិតក៏ដោយនៅពេលនោះ និងនាពេលបច្ចុប្បន្ន ។ បញ្ហាចិត្តសាស្ត្រ ឧទាហរណ៍ ទាក់ទងទៅនឹងការគ្មានមនោសញ្ចេតនា ការប្រទូស្តរ៉ាយរវាងការទទួលយកការពិត និងបដិសេធការពិត និង *អាឡិចស៊ីធីមៀ* ថាតើយើងឃើញបញ្ហានេះកើតឡើងនៅក្នុងប្រជាជនទូទៅ ឬក៏វាកើតឡើងតែចំពោះករណីជនជាប់ចោទតែប៉ុណ្ណោះដូចដែលលោកបានបញ្ជាក់?

**ឆ៖ (វេជ្ជ. កា ស៊ុនប៉ូណាត)** ខ្ញុំសូមឆ្លើយជូនលោកស្រីថា ដោយសារខ្លួនខ្ញុំបានប្រាស្រ័យទាក់ទងជាមួយនឹងមេដឹកនាំខ្មែរក្រហម និងខ្មែរក្រហមជាច្រើន ខ្ញុំបានសង្កេតឃើញថា អ្នកទាំងនោះមានឥរិយាបថមានអាកប្បកិរិយាប្រហាក់ប្រហែលគ្នា មិនសូវដែលមានឃើញសម្ដែងនូវអាកប្បកិរិយាសោកស្ដាយ ហើយបើសិនជាយើងសួរនូវអ្វីមួយដែលជ្រាលជ្រៅ អ្វីដែលទាក់ទងនឹងការងារបដិវត្តន៍អ្វីដែលទាក់ទងនឹងអង្គការគឺគេ អត់ឆ្លើយ ។ ភាគច្រើននៃអ្នកដឹកនាំនោះតាំងពីថ្នាក់ភូមិ ឃុំ ស្រុក រហូតទៅដល់ឋានៈជាឧត្ដមសេនីយ៍ ដែលរូបខ្ញុំបានជួបប្រទះគេមិនដែលបានឆ្លើយទេ ។

ដូច្នេះ ខ្ញុំអាចសន្និដ្ឋានបានដែរថា ចំពោះជនកុម្មុយនីស្តក្នុងរបបខ្មែរក្រហម ដោយសារតែមនោគមវិជ្ជា ដោយសារតែវិន័យ និងដោយសារតែរបៀបរបបរស់នៅឃើញថា អ្នកដឹកនាំខ្មែរក្រហមមួយចំនួនដែលខ្ញុំបានជួបប្រទះសម្ដែងនូវឥរិយាបថបែបនេះ ។ សូមអរគុណ ។

**ស៖** ថាតើកត្តាចិត្តសាស្ត្រទាំងអស់នេះ បានបង្ហាញហួសហេតុនៅក្នុងខ្លួនជនជាប់ចោទដែរឬទេ ហើយវាបណ្ដាលឲ្យគាត់ពុំមានលទ្ធភាពក្នុងការប្រតិកម្មក្នុងលក្ខណៈសាមញ្ញចំពោះអ្វីដែលកើតឡើងជុំវិញខ្លួនគាត់ ។ ឧទាហរណ៍ទាក់ទងទៅនឹងលក្ខខណ្ឌដែលគាត់បានរៀបរាប់នៅស-២១ នោះដែរឬទេ?

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** ខ្ញុំបាទមិនបានយល់ច្បាស់អំពីលក្ខខណ្ឌក្នុងស-២១ តើលោកស្រីអាចរៀបរាប់ឲ្យខ្ញុំបានដឹង ច្បាស់ទេ?

[១៣:៣៨:០៣]

**ស៖** ឧទាហរណ៍ក្នុងអំឡុងពេលផ្ដល់សក្ខីកម្មដែលយើងបានឮនោះ សាក្សីមួយចំនួនច្រើនបាននិយាយអំពីសំឡេងសម្រែករបស់អ្នកដែលត្រូវបានគេធ្វើទារុណកម្ម ហើយបានឃើញអំពីគ្រោះថ្នាក់ និងរបួសផ្សេងៗ និងបញ្ហាខ្វះអាហារកើតឡើងចំពោះជនរងគ្រោះ ជនជាប់ឃុំ ។ តាំងពីមុនមកជនជាប់

ចោទគាត់បានលើកឡើងថា ដោយគាត់បានផ្ដល់ហេតុផលថាគាត់មិននៅកៀក នៅជិតអ្នកជាប់ឃុំនោះទេ ហើយគាត់មិនបានឮសំឡេងស្រែកទាំងអស់នោះទេ នេះជាឧទាហរណ៍ ។ ដូច្នេះ អ្វីដែលខ្ញុំចង់សួរនោះ ថាតើបញ្ហាកត្តាចិត្តសាស្ត្ររួមផ្សំគ្នាទាំងអស់នោះអាចរារាំងបុគ្គលម្នាក់ ដូចជាជនជាប់ចោទពីការកត់សម្គាល់ឃើញទៅលើស្ថានភាពដែលកើតឡើងបែបនោះដែរឬទេ នៅមន្ទីរស-២១នោះ?

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** ចំពោះសំណួររបស់លោកស្រី ខ្ញុំមានការពិបាកនឹងឆ្លើយជូនពីព្រោះថា ដោយហេតុថាលោក ឌុច បានឆ្លើយថា គាត់មិនបាននៅកៀកជាមួយហ្នឹងអ្នកទោសទាំងនោះ ដូច្នេះគាត់មិនបានដឹង ។ ក្នុងនេះទៀតក៏មិនបានច្បាស់ដែរ ថាតើកាលដែលគាត់មិនបាននៅកៀកនឹងអ្នកទាំងនោះ តើគាត់នៅចម្ងាយប៉ុន្មាន? ហើយនៅក្នុងអគារនោះមានបើកបង្អួចបើកអីដែរអត់ទេ ដើម្បីអាចគាត់ឮនូវសម្រែកទាំងឡាយដែលអ្នកទោសនៅក្នុងស-២១ នោះស្រែក ឬក៏បន្លឺឡើង ។ ដូច្នេះឃើញថាបើសិនជាលោក ឌុច គាត់ធ្វើ ការនៅមិនជិតអ្នករងគ្រោះទាំងនោះនៅក្នុងមន្ទីរឃុំឃាំងស-២១ តែគាត់ស្ថិតនៅក្នុងអគារដែលបើកចំហ ប្រហែលជាអាចឮខ្លះ និងមួយទៀតបើសិនជាចម្ងាយនោះវាឆ្ងាយពេកដែលមិនអាចឱ្យសំឡេង នោះឮដល់ ឬក៏ពេលដែលគេធ្វើទារុណកម្ម គេធ្វើនៅក្នុងបន្ទប់មួយដែលបិទជិតនោះក៏មិនអាចឮដែរ ។ ដូច្នេះឃើញថា កាលដែលខ្ញុំឆ្លើយទៅបានលុះត្រាតែដឹងអំពីសភាពការណ៍ពិតហើយច្បាស់លាស់ និងលម្អិតដូចដែលខ្ញុំលើកជូននេះ ។

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលបូ)** លោកស្រីចៅក្រម! ប្រសិនបើអនុញ្ញាតឆ្លើយតបទៅនឹងសំណួររបស់លោកស្រី ថាតើមានទាក់ទងទៅនឹងបញ្ហាចិត្តសាស្ត្រដែរឬទេ? ខ្ញុំសូមជម្រាបថា នៅក្នុងបញ្ហាចិត្តសាស្ត្រស្ថានភាពតឹងរ៉ឹង ឬក៏តឹងតែងបំផុតនោះ គឺវាកើតចេញពីចារីដែលគាត់មានយន្តការបដិសេធចំពោះអ្វីដែលខ្ញុំដឹង យើងបានជួបប្រឈមនឹងការបដិសេធគឺ *ឌីណាយអល* ដែលមិនមានការលើកឡើងហើយយើងបានលើកឡើងអំពីភាពងងឹត ទាក់ទងទៅនឹងភាពល្ងិតល្ងង់ ទាក់ទងទៅនឹងបញ្ហាចិត្តសាស្ត្រ។

[១៣:៤២:៣០]

**ស៖** សំណួរចុងក្រោយមួយទៀត លោក លោកស្រីបាននិយាយអំពីបំណង ចិត្តសាស្ត្រ ហើយបានយកទៅពិចារណាជាមួយនឹងកត្តាវប្បធម៌ គឺទាក់ទងទៅនឹងការដែលគាត់ផ្គាប់ចិត្តមេរបស់គាត់ ។ ហើយលោក លោកស្រីបានបង្ហាញថា វាជាកត្តាមួយដែលកើតមាននៅក្នុងខ្លួនគាត់ដែលគាត់ចង់ឱ្យការងារដែលគាត់ធ្វើនោះល្អ ថាតើបញ្ហានេះវាជានិន្នាការស៊ីគ្នាទៅនឹងស្ថានភាពដែលជនជាប់ចោទគាត់ជាប់ ខ្លួនគាត់ទៅក្នុងនោះដែរឬទេ? បានន័យថា នៅក្នុងការងាររបស់គាត់ប្រចាំថ្ងៃដែលថាជាបុគ្គលិក

ខ្លាចបាត់បង់ការងាររបស់គាត់ ហើយគាត់ចង់ធ្វើអ្វីៗទាំងអស់ដើម្បីផ្គាប់របស់គាត់ដើម្បីចៀសវាងបញ្ហាទាំង អស់នោះ ។

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្គៀលបូ)** ជាការពិត យើងបានពិចារណាទៅលើស្ថានភាពមួយប្រភេទទៀតដែលការភ័យខ្លាចនឹងការស្លាប់មាន ជាពិសេសចំពោះជនជាប់ចោទ ដែលទាក់ទងទៅនឹង វន វ៉េត គាត់ភ័យខ្លាចដែលថាមេរបស់ គាត់នោះត្រូវបានគេសម្លាប់ហើយគាត់ខ្លាចគេសម្លាប់ខ្លួនគាត់ផងដែរ ។ ជាពិសេសនៅជិតចុងបញ្ចប់នៃរបបនេះ ។ នៅក្នុងឆ្នាំ១៩៧៧ គាត់ស្ថិតក្នុងស្ថានភាពដែលគាត់គិតអំពីការស្លាប់របស់គាត់ និងជោគវាសនារបស់គាត់ដែលអាចស្លាប់ ។ ហើយទាក់ទងទៅនឹងបញ្ហាគោរពឱវាទ *(អបប៊ីឌៀន)* គឺអត្តចរិតទាក់ទងទៅនឹងឋានានុក្រមមេរបស់គាត់ ។ ខ្ញុំសូមជម្រាបថា ខ្ញុំអាចឲ្យសហសេវិករបស់ខ្ញុំពន្យល់អំពីបរិបទវប្បធម៌ ។ ស្ថានភាពគោរពឱវាទត្រូវបានរៀបរាប់ និងសំដៅទៅលើ-- នៅក្នុងហួសពីបរិបទប្រទេសកម្ពុជា ។ ជាពិសេសនៅក្នុងការសិក្សាអំពីឧក្រិដ្ឋកម្មទាក់ទងទៅនឹងឧក្រិដ្ឋកម្មមួយចំនួន ។ ឌុច យើងបានរកឃើញឥរិយាបថបែបនោះ គឺការគោរពឱវាទ ការភ័យខ្លាច ការដែលគាត់ចង់ធ្វើការផ្គាប់ចិត្ត ។ ហើយដែលប្រភពរបស់គាត់មានលក្ខណៈច្រើន ទាក់ទងទៅនឹងបញ្ហាទាំងអស់នេះហើយ ឌុច បានលើកសម្មតិកម្មជូនសហសេវិករបស់ខ្ញុំ ទាក់ទងទៅនឹងការស្តារឡើងវិញនៃការទទួលស្គាល់ឪពុករបស់គាត់ ។ ហើយកាលពីឆ្នាំមុន គាត់បានលើកឡើងទៅលើចំណុចនេះ គាត់ត្រូវសម្តែងនូវកតញ្ញូតាធម៌ចំពោះឪពុករបស់គាត់ ប៉ុន្តែគាត់ហាក់ដូចជាមិនចាំនៅក្នុងសប្តាហ៍ដែលយើងជួបគាត់នេះ ។ ហើយគាត់បានលើកឡើងអំពីឪពុករបស់គាត់ និងការដែលគាត់មានទំនាក់ទំនងជាមួយនឹងឪពុករបស់គាត់ដែលគាត់បានពន្យល់នៅក្នុងបាតុភូតនៃរបាយការណ៍របស់ខ្ញុំ ។

ខ្ញុំសូមបន្ថែមថា ទាក់ទងទៅនឹងបញ្ហាមេដែលយើងនិយាយអំពីព្រឹកមិញនេះ គឺទាក់ទងទៅនឹងមេរបស់គាត់ ។ នៅក្នុងចម្លើយរបស់ខ្ញុំ គឺវាទាក់ទងទៅនឹងគោលគំនិតដែលចង់ស្តាររូបភាពឪពុករបស់គាត់ឡើងវិញ ដែលគាត់ធ្វើការចង់បាននូវគោលគំនិតជាមេ ហើយវាជាគំរូដែលវាកើតចេញអំពីគោលគំនិតចង់បង្កើតទៅលើការស្តារលទ្ធភាពនេះឡើងវិញ ។

ខ្ញុំសូមអនុញ្ញាតឲ្យសហសេវិករបស់ខ្ញុំពន្យល់បន្ថែមទៅលើចំណុចនេះ ។

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** ខ្ញុំសូមជម្រាបបន្ថែមចំពោះលោកស្រីថា នៅក្នុងវប្បធម៌ខ្មែរប្រពៃណីខ្មែរ ការគោរពគ្រូជាធំមានពិតប្រាកដ ហើយដែលយើងអាចសន្និដ្ឋានបានថា ឪពុកទីពីររបស់យើងទាំងអស់គ្នា គឺជាគ្រូ ។ ហើយដែលជាទូទៅ គ្រូតែងតែមានការសន្តោសការអប់រំ ឲ្យចេះទាំង

វប្បធម៌ ឲ្យចេះទាំងរបៀបរបបរស់នៅសព្វយ៉ាងទាំងអស់ ។ ដោយផ្អែកទៅលើស្ថានភាពបែបនេះ បានជាយើងមានប្រពៃណីមួយ គោរពគ្រូណាស់ ទោះជាយើងចាស់ណាស់ក៏ដោយ យើងអត់អាចភ្លេចគ្រូទេ យូរៗយើងទៅលេងសួរសុខទុក្ខគ្រូ មានអ្វីជូនគាត់ ហើយមានដែលរហូតទៅដល់ចាស់ៗជំនាន់ឪពុកខ្ញុំហ្នឹង ពេលដែលទៅជួបគ្រូតែកាលនោះគ្រូវិស័យមិនដូចគ្រូសព្វថ្ងៃទេ តែគាត់នៅគោរពគ្រូ ជួបគ្រូគាត់លុតជង្គង់ថ្វាយបង្គំ ។ នេះឃើញថា ការឲ្យតម្លៃទៅលើគ្រូនៅវប្បធម៌ខ្មែរយើងបែបនេះ ប៉ុន្តែ ក្នុងករណីរបស់ជនជាប់ចោទ ថ្វីដ្បិតតែមេកើយរបស់គាត់ ជាអតីតគ្រូមែន ប៉ុន្តែលើសអំពីនេះជាមេកើយដែលមានឋានៈខ្ពស់ជាង ហើយដែលក្នុងរបៀបរបបកុម្មុយនីស្ត គេអាចសឹងតែហៅថាជាអង្គការមួយដែរ មនុស្សម្នាក់នេះអាចតំណាងទៅអង្គការ ។ ដូច្នេះ ស្ថិតក្នុងសភាពមួយដែលគេតម្រូវឲ្យគាត់សម្លាប់គ្នាគាត់ឈ្មោះ វន វ៉េត គាត់មានជម្រើសតែពីរទេ សម្លាប់គេ ឬក៏គេសម្លាប់គាត់ ដើម្បីខ្លួនគាត់រស់ គាត់ត្រូវតែសម្លាប់គេ ។ នេះជារឿងមួយ ។

[១៣:៤៨:៥៧]

រឿងមួយទៀត តួនាទីរបស់គាត់ក៏ជាសមាជិករបស់គណបក្សដែរមជ្ឈិមបក្ស។ អ៊ីចឹងជាមនុស្សមួយគំរូ ជាមនុស្សមួយដែលមានចរិតដាច់ខាត មានន័យថា ខ្លួនគាត់ជាឧបករណ៍ដាច់ថ្លៃ ឬក៏ជាឧបករណ៍ដាច់ខាត ផ្តាច់ការរបស់បក្ស ។ ពេលនោះហើយក្នុងនាមខ្លួនជា ឧបករណ៍ដាច់ខាត ឬក៏ផ្តាច់ការរបស់បក្ស មានលក្ខណៈហាក់ដូចជាម៉ាស៊ីនមួយ មិនចេះតវ៉ា ឲ្យធ្វើអីត្រូវតែធ្វើនោះ ។ អ៊ីចឹងឃើញថា បន្ទុកពីលើមានពីរ មួយជាភារកិច្ចដែលមិនអាចប្រកែកបាន ។ ពីរ គឺជាស្ថានភាពមួយដែលត្រូវពិចារណាថា សុខចិត្តសម្លាប់គេ ឬក៏សុខចិត្តឲ្យគេសម្លាប់ខ្លួនឯង ។ សូមអរគុណ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយធ៍៖**

សូមអរគុណលោកសាស្ត្រាចារ្យ កា ស៊ុនបូណាត និងលោកស្រី ស៊ីរ៉ូនី ។

លោកប្រធាន ខ្ញុំពុំមានសំណួរទៀតទេ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត អង្គជំនុំជម្រះផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការតាំងសំណួរចំពោះអ្នកជំនាញទាំងពីររូបនេះ ។ ហើយអង្គជំនុំជម្រះសូមជម្រាបថា តំណាងសហព្រះរាជអាជ្ញា មានពេលវេលាមួយម៉ោងនិងដប់ប្រាំនាទី ក្នុងការសួរនេះ ។ សូមអញ្ជើញ ។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយ លោក តាន់ សេណារ៉ុង៖**

អរគុណលោកប្រធានអង្គជំនុំជម្រះ និងសូមស្វាគមន៍លោកសាស្ត្រាចារ្យ និងលោកស្រី ។

**ស៖** សំណួរទីមួយរបស់ខ្ញុំជូនលោកសាស្ត្រាចារ្យ និងលោកស្រីមានដូចខាងក្រោម៖

នៅក្នុងទំព័រទី១៥នៃរបាយការណ៍ចិត្តសាស្ត្ររបស់លោកទាំងពីរ វាមានការឲ្យដាក់អ្នកទោសពីរនាក់វាយគ្នាទៅវិញទៅមក ។

នៅក្នុងនោះនៅពេលដែលលោកទាំងពីរ បានសាកសួរទៅជនជាប់ចោទ ឌុច គាត់មិនបានឆ្លើយជាមួយនឹងសំណួរហ្នឹងទេ ។ គាត់បានឆ្លើយថា “ចាំជួបបុព្វជិតសាសនារបស់គាត់សិន” នៅក្នុងន័យនេះ តើលោកទាំងពីរ ដែលជាអ្នកវិភាគនុ៎ងបានបង្ហាញថា “ជាធម្មតាទេ នៅមន្ទីរឃុំឃាំងផ្សេងៗនៅលើពិភពលោកគឺមាន កុំឲ្យជនជាប់ឃុំឃាំងទាំងពីរនេះត្រូវរ៉ូវគ្នា” ។

[១៣:៥១:៥៧]

នៅក្នុងចំណុចនេះ តើលោកទាំងពីរអាចពន្យល់អង្គជំនុំជម្រះឡើងវិញបានទេ ថានៅក្នុងតុលាការដែលនៅក្នុងពេលនេះនៅអតីតមន្ទីរស-២១ ក្តី និងមន្ទីរឃុំឃាំងដទៃទៀតក្តី វាមានប្រធានមន្ទីរឃុំឃាំងនីមួយៗហ្នឹង បានឲ្យអ្នកទោសហ្នឹងវាយគ្នាអ៊ីចឹង បានជាអ្នកវិភាគហ្នឹងប៉ានវិភាគដូច្នេះ ។ ក្នុងន័យនេះ សូមលោកទាំងពីរហ្នឹង អាចពន្យល់ឡើងវិញបានទេ នូវចំណុចនេះ ថាមូលហេតុអ្វីបានជាលោកទាំងពីរហ្នឹង ប៉ានអះអាងដូច្នេះ? ហើយនិងមូលហេតុអ្វីបានជា ឌុច នៅពេលនោះគាត់មិនប៉ានឆ្លើយនឹងសំណួររបស់លោកទាំងពីរ ចាំជួបបុព្វជិតសាសនារបស់គាត់សិន?

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្មៀលបូ)** សូមអរគុណលោកសហព្រះរាជអាជ្ញា ។ នេះជាសំណួរមួយដ៏សំខាន់ ដោយសារតែមកទល់សព្វថ្ងៃនេះវានៅតែមិនអាចរកដំណោះស្រាយបាន ។ យើងមិនបានសួរសំណួរនេះទៅកាន់គាត់កាលពីសប្តាហ៍នោះទេ យើងមានបំណងចង់សំណួរនេះឡើងវិញ ហើយចង់សួរគាត់ទៅលើសំណួរហ្នឹង គាត់ចង់ជួបគ្រូបុព្វជិតរបស់គាត់។ ដូច្នេះហើយវានឹងអាចចំណាយពេលច្រើនជាងនេះ ។ ដូច្នេះហើយខ្ញុំមិនអាចជម្រាបលោក ហេតុអ្វីបានជាជនជាប់ចោទឆ្លើយដូច្នេះ ខ្ញុំគ្រាន់តែអាចនិយាយថា វាជាចំណុចមួយធ្វើឲ្យយើងភ្ញាក់ផ្អើល ហើយយើងទទួលបានព័ត៌មាននេះថា គាត់មានសិទ្ធិមិនឆ្លើយតបទៅនឹងសំណួរដែលគាត់មិនចង់ ។ ដូច្នេះហើយសំណួរមួយនេះ គឺជាសំណួរមួយដែលគាត់បានសម្រេចថា មិនឆ្លើយតបទៅនឹងសំណួររបស់យើង ។

ដូច្នេះ ក្នុងនាមជាអ្នកជំនាញគឺខ្ញុំមិនយល់យ៉ាងម៉េចដែលថា គាត់ចង់និយាយជាមួយនឹងបុព្វជិតគ្រីស្តសាសនារបស់គាត់ ។ ហើយខ្ញុំហាក់ដូចជាគាត់គិតទៅលើបញ្ហាសាសនា ហើយគាត់មិនបានពន្យល់បន្ថែមទៅលើចំណុចនេះ ។ ហើយខ្ញុំសូមអភ័យទោសដែរ ដែលទាក់ទងទៅនឹងសំណួរនេះ ។

ខ្ញុំគិតថាប្រហែលជាគាត់ចង់ឆ្លើយសំណួរនេះ ប៉ុន្តែជាបឋមគាត់ចង់និយាយបញ្ហានេះជាមួយនឹងបុព្វជិតសាសនារបស់គាត់ជាមុនសិន ។

[១៣:៥៤:៥៨]

ខ្ញុំមិនដឹងថាតើយើងមិនបានសួរគាត់ ថាតើគាត់បាននិយាយអ្វីខ្លះជាមួយនឹងបុព្វជិតគ្រិស្តសាសនារបស់គាត់ ។ ហើយខ្ញុំគោរពទៅលើសាសនា និងការគោរពសាសនារបស់គាត់ ជាការពិតវាជាបញ្ហាសម្ងាត់របស់គាត់ ហើយវាមិនមែនជាកាតព្វកិច្ចរបស់យើងក្នុងការលាតត្រដាងនូវអ្វីដែលគេបានលើកឡើងក្នុងលក្ខណៈឯកជននោះទេ ។

**ស៖** អរគុណលោកទាំងពីរ ។ សំណួរក្នុងសំណួរដដែលហ្នឹង ដែលអ្នកវិភាគហ្នឹងបានបង្ហាញនៅក្នុងទំព័រទី១៥ នៃរបាយការណ៍នុ៎ង អ្នកវិភាគថា នៅមន្ទីរឃុំឃាំងដទៃផ្សេងទៀតនៅលើពិភពលោកគឺមានកុំឲ្យជនជាប់ឃុំឃាំងទាំងពីរនោះត្រូវរ៉ូវគ្នា បានគេឲ្យវា-- បានន័យថា គេឲ្យវាយគ្នាអ៊ីចឹង ។ ក្នុងហ្នឹងតើអ្នកវិភាគអាចពន្យល់បន្តិចបានទេថា មូលហេតុអ្វីបានជាលោកហ្នឹងប៊ាានអះអាងថា ការឲ្យអ្នកទោសពីរអ្នកវាយគ្នាហ្នឹង គឺជាមធ្យោបាយមួយដើម្បីកុំឲ្យអ្នកទោសទាំងពីរហ្នឹងវាយគ្នា អ៎! ត្រូវរ៉ូវគ្នា បាទសូមទោស ។

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហៀលប៊ូ)** ខ្ញុំហាក់ដូចជាមិនសូវយល់នូវសំណួររបស់លោកតំណាងសហព្រះរាជអាជ្ញា ។ នៅពេលដែលខ្ញុំនិយាយអំពីមន្ទីរឃុំឃាំងដទៃទៀត ខ្ញុំក៏និយាយ ខ្ញុំសំដៅទៅលើចម្លើយរបស់ជនរងគ្រោះដទៃទៀតដែលយើងបានពិចារណានិងពិនិត្យមើល ។ ហើយក៏វាមានកើតជាលក្ខណៈញឹកញយ និងរបៀបនេះដែរតាមចម្លើយទាំងអស់នោះ ។ ដូច្នេះហើយជនរងគ្រោះ គាត់អ្នកលើកឡើងអំពីករណីនេះ ហើយខ្ញុំហាក់ដូចជាមិនសូវយល់នូវសំណួររបស់លោក ហើយខ្ញុំមិនដឹងថាតើមានគោលបំណងយ៉ាងម៉េច? វាអាចអ៊ីចេះ ថានៅពេលដែលបុគ្គលពីររូបគាត់វ៉ៃគ្នា ហើយគាត់បង្កឲ្យមានការឈឺចាប់ នៅពេលដែលយើងបង្ខំឲ្យអ្នកទាំងពីរនោះវ៉ៃគ្នា ហើយវាជាការផ្តល់នូវសញ្ញាមួយ ។ ខ្ញុំអាចផ្តល់ជាឧទាហរណ៍ថា ដោយសារតែវាមានការឈឺចាប់ និងការវាយតប់ពីអ្នកជាប់ឃុំមួយនោះ ហើយវាអាចប៉ះពាល់ទៅដល់អ្នកដែលត្រូវបានទទួលរងនូវអំពើទាំងអស់នេះ ហើយក៏វាជាប់ទាក់ទងទៅនឹង

អ្នកធ្វើទារុណកម្មផងដែរ ។ ហើយវាក៏ពាក់ព័ន្ធទៅនឹងបញ្ហារំលោភផ្លូវភេទផងដែរ ប៉ុន្តែនៅក្នុងករណីវៃតប់គ្នានេះ នៅពេលដែលមានការវាយតប់នោះ គឺពួកគេកើតចិត្តនៅខឹងនៅក្នុងខ្លួន។ ដូច្នេះហើយការឈឺចាប់នៅក្នុងរាងកាយ ហើយនិងកំហឹងនៅក្នុងខ្លួននោះ វាអាចជាលទ្ធផលផ្លូវចិត្តមួយ ហើយនាំឲ្យបុគ្គលមួយដែលរងគ្រោះហ្នឹងស្អប់បុគ្គលម្នាក់ទៀត ហើយមិននឹងមិនត្រូវរ៉ូវជាមួយនឹងបុគ្គលនោះទេ ។ ហើយខ្ញុំសូមរំឭកថា លោកសហព្រះរាជអាជ្ញា នៅពេលដែលខ្ញុំសួរសំណួរនេះទៅកាន់គាត់កាលពីឆ្នាំទៅមិញ យើងអាចយើងបានសួរគាត់ថា តើឲ្យគាត់អាចពន្យល់ទៅលើចំណុចហ្នឹងដែរឬទេ? តើគាត់មានគោលបំណងអ្វីដែរ? ហើយយើងមិនបានទទួលហេតុផល និងចម្លើយនៃសេចក្តីពិតទាក់ទងទៅនឹងព្រឹត្តិ-ការណ៍កើតឡើង ចំពោះការវៃតប់នោះទេ ។

[១៣:៥៩:១៥]

**ស៖** អរគុណ ។ ខ្ញុំសូមបន្តសំណួរទៅមុខទៀតចុះ ។

សំណួរទីពីរ នៅក្នុងទំព័រលេខ៤៨ កថាខណ្ឌទី១ នៃរបាយការណ៍របស់លោកទាំងពីរ លោកបានធ្វើការវិភាគនិងសន្និដ្ឋានថា ការលះបង់សាសនាព្រះពុទ្ធនាំឲ្យ ឌុច បានទទួលនូវសេចក្តីសុខក្នុងបរលោកទៅកាន់សួគ៌ា ប្រសិនបើនៅកាន់សាសនាព្រះពុទ្ធមិនអាចរួចកម្មនេះបានទេ គឺត្រូវសាងបុណ្យច្រើនណាស់។ នៅក្នុងចំណុចនេះ តើលោកអាចពន្យល់ជូនអង្គជំនុំជម្រះឡើងវិញបានទេថាមូលហេតុអ្វីបានជានៅក្នុងរបាយការណ៍របស់លោកទាំងពីរ បានវិភាគនូវចំណុចកម្មផលថា អ្វីដែល ឌុច គាត់បានផ្លាស់ប្តូរសាសនាពីសាសនាព្រះពុទ្ធ មកសាសនាគ្រិស្ត ហើយនៅពេលដែលគាត់បានកាន់ជាសាសនាគ្រិស្ត ហើយគាត់នឹងបានរួចផុតពីទោសទណ្ឌ និងទណ្ឌកម្មនានានៅបរលោកនោះ? សូមអញ្ជើញបាទ ។

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលបូ)** ដែលថាការចាកចេញពីព្រះពុទ្ធសាសនាទៅយកសាសនាផ្សេងនោះទាក់ទងទៅនឹងការប្តូរសាសនារបស់គាត់នោះ ព្រឹកមិញនេះ យើងបាននិយាយពីមូលហេតុដែលគាត់បានបញ្ជាក់ប្រាប់យើងអំពីការផ្លាស់ប្តូរ ហើយយើងក៏បានព្យាយាមយល់ ហើយនិងវិភាគជាមួយសហសេវិកខ្ញុំ ។ អ៊ីចឹងហើយ ការប្តូរសាសនាទៅជាគ្រិស្តសាសនាវិញនោះ វាមានផលប៉ះពាល់មួយគឺថាដើម្បីឯាកចេញពីអំពើបាបដែលបានធ្វើក្នុងអតីតកាលនោះក៏ដោយ ប៉ុន្តែវាជាការបំផ្លែងសាសនាទៅសាសនាថ្មីដែរថាអាចនឹងចាប់ជាតិជាថ្មីឡើងវិញ ដូចថាដូចជាការកើតជីវិតថ្មីនៅក្នុងគ្រិស្តសាសនា ។

ចំណុចទីពីរ នៅក្នុងសាសនាគ្រិស្តអ្វីដែល ឌុច បានប្រាប់យើងនោះ គាត់បានរកឃើញសំខាន់ណាស់ គាត់និយាយថាគឺព្រះជាម្ចាស់ដែល-- ខ្ញុំមិនមានអត្ថបទចំពោះមុខខ្ញុំទេ គឺថាព្រះជាម្ចាស់បាន

ប្រសិទ្ធិពរឲ្យខ្ញុំ គាត់និយាយអ៊ីចឹង ហើយយើងបាននិយាយពិភាក្សាច្រើនជាមួយគាត់អំពីបញ្ហាការអត់ឱនទោស ការលើកទោសពីព្រះនោះ ។ នៅក្នុងសាសនាកាតូលិកនោះ គឺថាព្រះជាម្ចាស់នោះ គឺថាអាចនឹងលើកលែងទោសឲ្យមនុស្សបាន ហើយទទួលស្គាល់ថាជាព្រះរាជបុត្រនៃព្រះ ។ អ៊ីចឹងហើយនេះជាកត្តាសំខាន់សម្រាប់គាត់ នៅក្នុងគំនិតដំណើរការគិតគូរវិភាគរបស់គាត់ ទាក់ទងអំពីថាការប្តូរពីព្រះពុទ្ធសាសនា ទៅជាគ្រិស្តសាសនាវិញនោះ ។

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** ខ្ញុំសូមបន្ថែមផងដែរថា ក្នុងព្រះពុទ្ធសាសនាជាសាសនាអប់រំមនុស្សម្នាក់ៗឲ្យធ្វើល្អ ទោះបីជាប្រពន្ធ ជាប្តី ជាកូន ជាឪពុកម្តាយ បានធ្វើល្អច្រើនយ៉ាងក៏ដោយ តែកុសលបុណ្យនោះមិនបានឃិតយោងកូន ដែលបានធ្វើអាក្រក់ឲ្យរួចផុតពីទុក្ខទោសទេ ។ ដូច្នេះ បើនៅតែជាពុទ្ធសាសនិក ផ្អែកទៅលើអ្វីដែលខ្លួនគាត់បានធ្វើ គាត់មិនអាចចៀសពីបាបនោះបាន គឺអ្វីៗដែលទទួលបានហាក់ដូចវាជាកម្មផលចេញអំពីអ្វីដែលយើងបានធ្វើកន្លងមក ។ ហើយលោក ឌុច គាត់មានប្រសាសន៍ផងដែរថា ក្រោយពីគាត់ពិចារណាទៅ ឃើញថាសាសនាគ្រិស្តនេះឯង ដែលក្នុងនោះព្រះជាម្ចាស់អាចនឹងអនុគ្រោះ លើកលែងទោសឲ្យអ្នកណាជឿទៅលើព្រះនោះបាន ។ ហេតុដូច្នេះហើយបានជាលោកបានសម្រេចជ្រើសរកសាសនាគ្រិស្តនេះ ជំនួសព្រះពុទ្ធសាសនាវិញ ដើម្បីលោកមានជំនឿថាលោកអាចរួចផុតពីកម្មផល ឬក៏លោកអាចរួចផុតពីអំពើបាបដោយសារការអនុគ្រោះ ឬក៏ការលើកលែងទោសរបស់ព្រះជាម្ចាស់ក្នុងសាសនាគ្រិស្ត ហើយដែលនៅក្នុងព្រះពុទ្ធសាសនា មិនមានការលើកលែងទោសបែបនេះទេ គឺទាល់តែបុគ្គលខ្លួនឯង ធ្វើល្អសព្វយ៉ាងទាំងអស់ ទើបបានរួចផុតពីទុក្ខទោសពីអំពើបាប ។

[១៤:០៤:៥៥]

**ស៖** បាទ, អរគុណ លោកទាំងពីរ ។ សំណួរបន្ទាប់ជូនលោកទាំងពីរ នៅក្នុងទំព័រទី៥០ នៃកថាខណ្ឌទី៤ លោកទាំងពីរហ្នឹង នៅក្នុងរបាយការណ៍ហ្នឹងលោកទាំងពីរហ្នឹង បានវិភាគនិងសន្និដ្ឋានថាឌុច ជាមនុស្សឯងប់ងល់ដែលផ្ទត់គំនិតនេះហើយ ដែលជាដើមចមនៃការសម្រេចចិត្តរបស់គាត់ដើម្បីឲ្យក្លាយទៅជាជនបដិវត្តន៍ុង ។ នៅក្នុងន័យនេះ តើលោកទាំងពីរអាចពន្យល់ជូនអង្គជំនុំជម្រះបានឡើងវិញទេថាផ្ទត់គំនិតរបៀបម៉េច ដែលបានក្លាយឲ្យទៅគាត់ហ្នឹងទៅជាមនុស្សដែលថាមានជាងប់ងល់ជាមួយផ្ទត់គំនិតដ៏ឃោរឃៅ និងព្រៃផ្សៃនេះលោក?

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលបូ)** លោកសហព្រះរាជអាជ្ញា ប្រហែលជាយើងមិនយល់ច្បាស់សំណួររបស់លោកទេ ។ ភាពងប់ងល់នោះ តើលោក-- យើងមិនចាំថាបានប្រើនៅកន្លែងណាមួយ ប្រហែលជាបញ្ហានៅក្នុងការបកប្រែពាក្យថា ងប់ងល់នេះ គឺថា តើលោកពន្យល់ថាយោងទៅរកអំពីការសម្រេចចិត្តចូលបដិវត្តន៍របស់គាត់ ឬក៏ក្នុងបរិបទណាមួយដែលលោកបានយោងទៅរកនោះ? គឺសូមអភ័យទោស។

**ស៖** នៅក្នុងន័យនេះ ដែលខ្ញុំសួរហ្នឹង ពីព្រោះឥឡូវវាមានការបកប្រែជាភាសាខ្មែរហ្នឹង ក្នុងទំព័រទី៥០ កថាខណ្ឌទី៤ ដែលជាភាសាខ្មែរហ្នឹងគេបានបកថា “អ្នកវិភាគបានសន្និដ្ឋានថា ឌុច ជាមនុស្សងប់ងល់” ដែលផ្ចិតគំនិតនេះហើយ ដែលជាដើមចមនៃការសម្រេចចិត្តរបស់គាត់ ដើម្បីឲ្យក្លាយទៅជាជនបដិវត្តន៍ ។ ប្រសិនបើលោកមិនអាចឆ្លើយបាន ខ្ញុំសូមបន្តសំណួរតទៅទៀតចុះ ដើម្បីកុំឲ្យវាខាតពេលវេលាពីព្រោះវាជាអាចជាពាក្យបច្ចេកទេសនៅក្នុងការបកប្រែភាសា ហើយធ្វើឲ្យការលំបាក ខ្ញុំមើលឃើញចំណុចហ្នឹង ហើយធ្វើឲ្យលោកបើលោកបកប្រែជាភាសាបារាំង វាមានបញ្ហា ។

សំណួរបន្ទាប់ជូនលោក នៅក្នុងទំព័រទី៥៦ ដែរ ហើយនៅក្នុងនោះនៃកថាខណ្ឌទី២ បានសរសេរថាផ្អែកតាមការស្រាវជ្រាវទៅលើវិធីសាស្ត្រអប់រំកម្មាភិបាលសួរចម្លើយ និងឆ្នាំធ្វើទារុណកម្មនៅមន្ទីរស-២១ហ្នឹង ឃើញថាជាសិល្បវិធីដែល ឌុច បានអប់រំកម្មាភិបាលទាំងអស់ឲ្យគំនិតច្រើន ហើយគំនិតហ្នឹង វាកើតចេញពីសភាវៈខាងក្នុងដោយឯកឯងរបស់សាមីជន ។ តើនៅក្នុងន័យនេះ អ្នកជំនាញសូមលោកអាចពន្យល់ន័យនៃពាក្យថា “សភាវៈគតិ” ទាំងនោះ ដែលកើតចេញពីក្នុងរបស់សាមីជនម្នាក់ៗហ្នឹងជូនអង្គជំនុំជម្រះឡើងវិញបានទេ?

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលបូ)** សូមលោកបញ្ជាក់ចំណុចចុងក្រោយនៃសំណួររបស់លោក ដោយ-សារថាយើងមានការបកប្រែទៅ យើងស្តាប់ចាប់មិនបានខាងចុងក្រោយ ហើយនិងអត្ថបទរបស់យើងវាដូចមិនស្របទៅនឹងការបកប្រែ ។

[១៤:០៩:៤៣]

**ស៖** ដើម្បីកុំឲ្យមានការពិបាក នៅក្នុងការលោកអ្នកជំនាញទាំងពីរហ្នឹង ធ្វើការពិចារណាយូរ ខ្ញុំបន្តសំណួរបន្ទាប់ទៀតចុះ ។ សំណួរបន្ទាប់ក៏មាននៅក្នុងរបាយការណ៍របស់លោកទាំងពីរដែរ ដែលមាននៅក្នុងទំព័រលេខ១២០ នៅក្នុងកថាខណ្ឌ២ហ្នឹង ។ ក្នុងនុ៎ង លោកបានសរសេរថារបបបានជិតចប់ហើយពេលនោះ ឌុច បានដេកទាំងយប់ទាំងថ្ងៃដោយសារតែអស់សង្ឃឹម ។ នៅក្នុងន័យដែលអ្វីដែលលោកទាំងពីរបានសរសេរហ្នឹង តើលោកអាចពន្យល់ជូនអង្គជំនុំជម្រះឡើងវិញបានទេថាមូលហេតុអ្វីបានជា

របបផិតចប់ អ្នកទោសគ្មានដឹកជញ្ជូនពន្ធនាគារទៀត ចូលមន្ទីរស-២១ ទៀត គ្មានការកាប់សម្លាប់ទៀត បែរជា ឌុច នុំង ដេកទាំងថ្ងៃទាំងយប់ ហើយអាច-- វានឹងក្លាយទៅជាមនុស្សអស់សង្ឃឹមនោះ? លោកស្តាប់ខ្ញុំបានទេ?

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** ករណីដែលលោក ឌុច ក្នុងរយៈពេលជាប្រហែលជាមួយអាទិត្យមុនកាលដែលកងទ័ពវៀតណាមចូលមកដល់ ពេលនោះការងារមិនសូវមានមែន ។ ការនាំអ្នកទោសមកថែមទៀតក៏ដូច្នោះដែរ ដូលដែលលោកបានរៀបរាប់អ៊ីចឹង ហេតុអ្វីបានជាគាត់សម្រានទាំងយប់ទាំងថ្ងៃ ហើយអសង្ឃឹម ព្រមទាំងគ្មានកម្លាំងកំហែងនឹងធ្វើអីសោះ?

ត្រង់នេះបញ្ជាក់ថា របបរបស់គាត់នឹងបានបាត់បង់ ហើយគាត់មិនច្បាស់លាស់ថាតើគាត់នឹងក្លាយទៅជាអ្វីទៀត ពិសេសអាយុជីវិតរបស់គាត់ ព្រោះអីពេលនោះដាច់ការទាក់ទងផង តាមដែលគាត់បានឆ្លើយមកថា នៅពេលដែលអង្គការបានភៀសខ្លួនចេញទៅអស់ទៅមានតែអង្គភាពគាត់ទេ ហើយនិងអង្គភាពមួយខាងវិទ្យុផ្សាយសំឡេងដែលនៅមិនរត់នឹងគេ ហើយមិនបានទទួលដំណឹងឲ្យរត់នឹងគេ ។ ដូច្នេះក្នុងសភាពការណ៍ដែលមានរណសិរ្សរំដោះជាតិ ហើយនិងទ័ពវៀតណាមមកដើម្បីផ្តួលរំលំរបបហើយដែលគាត់មិនបានដំណឹងអីសោះ ហើយក៏ប្រហែលជាគាត់អាចដឹងខ្លះផងដែរថា មានទ័ពវៀត-ណាមត្រឡប់មក ហើយដែលមណ្ឌលឃុំឃាំង មន្ទីរឃុំឃាំងរបស់គាត់នេះ បម្រើការងារមួយដែលមានគោលការណ៍ប្រឆាំងនឹងជនជាតិវៀតណាម គាត់អស់សង្ឃឹមខ្លាំង ។ ហើយអការៈដែលអសង្ឃឹមខ្លាំងដែលផ្ទុកមកភ្លេចៗតែម្តងនេះ ធ្វើឲ្យមានការធ្លាក់ទឹកចិត្ត ដែលយើងហៅថាជាភាសាបារាំង ហៅថា *ដេប្រេសស្យុង* ។ អការៈទាំងនេះ គឺជាអការៈនៃជំងឺធ្លាក់ទឹកចិត្តនេះឯង ហៅថា *ដេប្រេសស្យុង* នោះហើយ ដោយសារតែអ្វីៗដែលធ្លាប់មានដំណើរការកន្លងមក វាដោះដូរទាំងអស់ ហើយធ្វើឲ្យខ្លួនគាត់មិនច្បាស់លាស់ តើគាត់ធ្វើអ្វី? នៅទីណា? គាត់អាចធ្វើអីទៀត? បាត់ខ្សែរយៈអស់ អ៊ីចឹងហាក់ដូចជាគាត់ស្ថិតនៅក្នុងកណ្តាលសភាពការណ៍មួយ ដែលគាត់ត្រៀមស្លាប់ដែរ ។

[១៤:១៤:០៧]

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្មៀលបូ)** សូមអនុញ្ញាតបន្ថែមអ្វីដែលលោកបានលើកឡើងនោះ ដែរថាគាត់មានភាពងប់ងល់នោះ ។ ព្រឹកមិញនេះ យើងនិយាយថាគាត់ជាមនុស្សៗរហ័សរហួន គឺយកចិត្តទុកដាក់ក្នុងការងារ ហើយចំពោះមនុស្សដែលមានភាពងប់ងល់នឹងការងារ ឬក៏រហ័សរហួន ហើយយកចិត្តទុកដាក់ ហើយចាប់អារម្មណ៍និងសេចក្តីលម្អិត ហើយនិងចង់ធ្វើការងារអ្វីឲ្យពូកែ ឲ្យល្អសម្រាប់ជាលទ្ធ-

ផលនោះ ។ យន្តការចិត្តសាស្ត្រអំពីភាពងប់ងល់ក្នុងអ្វីមួយនេះ គឺមិនមានហេតុផលអ្វីនឹងកើតមានទេ បើសិនជាវាមានដំណោះស្រាយ ថាពេលដែលមានភាពបាក់ទឹកចិត្តហើយ ឃើញថាមានក្របខ័ណ្ឌផ្លូវចិត្តនោះ ថាបើសិនជាវាមានភាពងប់ងុល គឺថាភាពរឹងមាំ មិនអាចទប់ទល់បាន។ អ៊ីចឹងគឺថាគឺពេលខ្លះគេអាចតែបណ្តែតបណ្តោយឲ្យវាទៅខាងមុខ គឺថាពេលខ្លះវាមានការសង្ស័យ ហើយនិងមានចំណង់ដែលនៅម្ខាងទៀត ។ ដូច្នេះគេត្រូវដើរទៅផ្លូវមួយទៅតាមចំណង់នោះ ។ ខ្ញុំមិនអាចកំណត់ថាពីពេលមួយខែឬក៏ប៉ុន្មានណាទេ ដែលរយៈពេលដែលបន្តនោះ ប៉ុន្តែបើគាត់ស្ថិតនៅក្នុងជួរអង្គការហើយ ដែលធ្វើឲ្យគាត់ត្រូវតែស្ថិតនៅក្នុងស្ថានភាពនោះ ហើយគាត់មានការសង្ស័យថា មិនសូវពេញចិត្ត ។ ប៉ុន្តែ បើសិនជាលទ្ធភាពដូចថា ប៉ុន្តែគាត់ត្រូវតែស្វែងទៅរកអ្វីមួយដូចថាមានភាពងប់ងល់ដូចគ្នានោះ ប៉ុន្តែការដែលបំភ្លេចអំពើអ្នកនោះបាន គឺថាមានតែពេលខ្លះកាលណាមានពេលបាក់ទឹកចិត្ត គឺថាមិនមានដំណោះស្រាយទាក់ទងនឹងជីវិតនោះទេ រហូតដល់ពេលដែលទាល់ច្រក គឺថាទាល់ច្រក គឺភាពដេកលក់នេះហើយ គឺជាជម្រកនៃភាពភ័យខ្លាច និងការបាក់ទឹកចិត្តនោះ ។ អ៊ីចឹងហើយ យើងយល់ចំណុចមួយយើងធ្វើការវិភាគរហូតមកដល់ក្បែរ ដល់ចុងបញ្ចប់នៃរបបហើយ នៅពេលដែលគេសាកសួរអំពីការងាររបស់គាត់នោះ គឺនេះហើយជាមូលហេតុដែលគាត់បានសម្រាន្តច្រើនៗ គឺថាដើម្បីជាជម្រកលាក់កំបាំងនូវការជំងឺបាក់ទឹកចិត្ត នៅក្នុងផ្លូវចិត្តសាស្ត្ររបស់គាត់នោះឯង ។

**ផ៖ (វេជ្ជ. កា ស៊ុនបូណាត)** ខ្ញុំសូមជម្រាបលោក លោកស្រីថា អាការៈបែបនេះយើងធ្លាប់បានទទួលមានបទពិសោធក្នុងពេលដែលកងទ័ពខ្មែរក្រហមវ៉ៃចូលទីក្រុងភ្នំពេញ នាថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ដែលប្រជាពលរដ្ឋជាច្រើននៅក្នុងរាជធានីភ្នំពេញនេះ គាត់ទៅជាមឹងម៉ាំង អស់កម្លាំងចិត្ត អស់ដៃ អស់ជើង គាត់អត់ដឹងធ្វើអីទេ គិតតែពីការសម្រាន្ត ហើយគ្មានគំនិតនឹងទៅណាមកណាទេ គឺអាការៈដូចគ្នាអ៊ីចឹង សូមអរគុណ ។

**ស៖** អរគុណលោកទាំងពីរ ។ សំណួរបន្ទាប់ជូនលោក នៅក្នុងរបាយការណ៍របស់លោកដដែលហ្នឹង នៅក្នុងទំព័រលេខ១២១ ជាភាសាខ្មែរក្នុងកថាខណ្ឌទី៤ហ្នឹង លោកបានសរសេរថា ឌុច នៅតែប្រើប្រាស់ការភូតភរ ដោយតាមរយៈការលាក់លៀមដើម្បីការពារខ្លួន ។ តើលោកទាំងពីរនៅក្នុងន័យនេះ តើលោកទាំងពីរហ្នឹងអាចពន្យល់ពីអង្គហេតុ ថាតើចំណុចណាខ្លះដែល ឌុច ហ្នឹង មានការភូតកុហកហ្នឹង និងភូតភរហ្នឹង?

[១៤:១៨:២៧]

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** នៅក្នុងរបាយការណ៍ យើងបាននិយាយថា លោក ឌុច មិនបាន ឆ្លើយ ឬក៏គាត់បញ្ចៀសនូវចម្លើយដែលជាភាសាបារាំងហៅថា ដេនីមង់ ហើយដែលជាភាសាអង់គ្លេស គេហៅថា *ឌីណាយអល* តែមិនមែនមានន័យថា ភូតកុហកទេ ។

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្គៀលបូ)** នេះហើយជាមូលហេតុដែលខ្ញុំមិនទាន់ច្បាស់ ប៉ុន្តែយើងបានជួប មានការពិបាកអំពីផែនការកុហក ឬក៏ការលាក់លៀម ឬក៏បញ្ចៀសនោះ។ ប៉ុន្តែ យើងមិនទាន់បានមាន អត្ថបទខ្មែរចំពោះមុខលោក កា ស៊ុនបូណាត ។ អ៊ីចឹងសូមអភ័យទោស ។

**ស៖** បាទ អរគុណលោកទាំងពីរ ។ វាអាចថានេះជាបញ្ហាបកប្រែ ប៉ុន្តែលោកអាចរកឃើញនៅ ក្នុងទំព័រលេខ១២១ កថាខណ្ឌ៤ ដែលខ្ញុំបានជម្រាបជូនអម្បាញ់មិញ នេះជាភាសាខ្មែរ ប៉ុន្តែឥឡូវខ្ញុំសូម សួរសំណួរបន្តទៀត ជាសំណួរចុងក្រោយមុននឹងខ្ញុំបញ្ជូនសំណួរទាំងនេះជូនទៅសហការីរបស់ខ្ញុំ ។

តាមការផ្តល់សក្ខីកម្មរបស់សាក្សីដែលមានលេខសម្ងាត់ គឺថា KW-31 របស់ ចាន់ វឿន កាល ពីថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩ ហ្នឹងថា ជនជាប់ចោទសើចសប្បាយហ៊ួកញ្ញៀវពេលជនជាប់ចោទបាន សួរនិងវាយអ្នកទោស ។ នៅក្នុងន័យនេះ ក្នុងនាមលោកជាអ្នកវិភាគចិត្តសាស្ត្រនោះ ថាតើលោកអាច ពន្យល់ និងវិភាគឃើញយ៉ាងដូចម្តេចដែរ ចំពោះចំណុចទាំងនេះ?

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្គៀលបូ)** ជនជាប់ចោទបានសើច គឺជាសម្តែងពីអារម្មណ៍ល្អមួយរបស់គាត់ ដោយហេតុថា គាត់មិនបាននិយាយអំពីខ្លួនគាត់ អំពីស្ថានភាពបែបនេះទេ នៅពេលដែលយើងបានជួប នឹងគាត់ជាដំបូងនោះ ។ ប៉ុន្តែ សេចក្តីអធិប្បាយនិងការរៀបរាប់អំពីអត្តចរិតរបស់គាត់ហ្នឹង គឺផ្អែកទៅ លើអ្វីដែលយើងបាននិយាយព្រឹកមិញនេះ និយាយឲ្យចំគឺថាភាពដែលថា អាណិតអាសូរ ហើយគំនិត ដែលគិតថា អ្នកដទៃសុទ្ធតែខ្លាំងនោះ គឺថាវាមិនមានអារម្មណ៍ទទួលបាន ដឹងពីការឈឺចាប់របស់អ្នក ដទៃ អំពីអំពើទារុណកម្មឬក៏អ្វីដែលបង្កដល់អ្នកដទៃ ប៉ុន្តែយើងនិយាយព្រឹកមិញនេះ អំពីភាពមួយដែល ថា ភាពខូចអាការៈណាមួយនៅក្នុងចិត្តសាស្ត្រ ដែលថាគាត់សប្បាយចិត្ត និងពេញចិត្តអ្វីអំពីប្រព័ន្ធនៃ ការបញ្ជូនការងារល្អ ទៅថ្នាក់លើរបស់គាត់ ហើយដែលគិតថា យើងបានប្រព្រឹត្តទៅលើជនរងគ្រោះ តាមអ្វីដែលគេចង់បាន ប៉ុន្តែយើងពិនិត្យមើលថា អ្វីជាការរីករាយរបស់គាត់ សប្បាយរបស់គាត់ដើម្បីធ្វើ ឲ្យគេឈឺចាប់ ឬមួយយ៉ាងណានោះទេ ។

នៅទីនេះ ខ្ញុំអាចនិយាយថា យើងមិនអាចនិយាយអ្វីបានច្រើនទេអំពីចំណុចនេះ ។ អ្វីដែលការ វាយតម្លៃ យើងបានពិនិត្យឃើញ គឺមិនអាចអនុញ្ញាតឲ្យយើងបញ្ជាក់ថាការណ៍ហ្នឹងវាពិតថាអ៊ីចឹងនោះទេ។

[១៤:២៣:២៥]

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** តាមដែលបានសម្ភាសជាមួយគាត់ យើងមិនបានទទួលនូវដំណឹងនេះទេ ហើយក្នុងនេះទៀត បើអនុញ្ញាតឲ្យយើងខ្ញុំនឹងផ្តល់ជាយោបល់ខ្លះៗបាន លុះត្រាតែយើងបានស្គាល់អំពីលក្ខណៈសម្បត្តិ ដំណើរទាក់ទងរបស់អ្នកទោសនោះ ថាតើគាត់ជាប់ទោសដោយសារអ្វី ហើយគាត់បានធ្វើអ្វីខ្លះជាមួយនឹងបដិវត្តន៍របស់ខ្មែរក្រហម ហើយគាត់មានទំនាក់ទំនងអ្វីជាមួយមេដឹកនាំរបស់លោក ឌុច ឬក៏ជាមួយលោក ឌុច ។ ហើយក្នុងឱកាសដែលគាត់បានវៃអ្នកទោសនោះ តើមានអ្នកណាខ្លះនៅជុំវិញ ហើយបានជាគាត់មានការសើចសប្បាយយ៉ាងនេះ ពីព្រោះអីលោកលើកសួរឡើងនេះ ចម្លល់មួយហើយ ក៏ប៉ុន្តែជាចម្ងល់ដែលខាងយើងខ្ញុំនៅខ្វះព័ត៌មានផ្សេងៗទៀត ដើម្បីអាចនឹងឲ្យជម្រាបជូន ។

**លោក តាន់ សេណារ៉ុង៖**

សូមអរគុណលោកទាំងពីរ ហើយសូមអរគុណអង្គជំនុំជម្រះ ខ្ញុំនឹងបង្វែរសំណួរបន្ទាប់ទៅជូនសហការីរបស់ខ្ញុំ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។

**សួរដោយលោក អានីស អះមេដ៖**

សូមអរគុណលោកប្រធាន ហើយសូមអរគុណចំពោះអ្នកជំនាញដែលបានរៀបចំការវាយតម្លៃដែលមានរបាយការណ៍យ៉ាងពិស្តារ ហើយនិងជួយដល់អង្គជំនុំជម្រះឲ្យយល់បានថា តើអ្វីកើតមានឡើងនៅស-២១ ថាតើការកាប់សម្លាប់ទាំងអស់នោះ វាមានអ្វីជាកត្តាជំរុញខាងផ្លូវចិត្ត ។ អ៊ីចឹងហើយយើងឃើញថា អង្គជំនុំជម្រះបានពិនិត្យ ហើយរបាយការណ៍នេះមានលក្ខណៈលម្អិតពិស្តារ ។ ខ្ញុំមិនមែនជាអ្នកជំនាញចិត្តសាស្ត្រ ប៉ុន្តែខ្ញុំនឹងព្យាយាមសួរសំណួរសាមញ្ញៗមួយចំនួន ដើម្បីជួយដល់អង្គជំនុំជម្រះដើម្បីកំណត់នូវបញ្ហា ពិចារណាបញ្ហាដែលបានដាក់ជូននេះ ខ្ញុំនឹងសួរសំណួរមួយចំនួនដែលខ្ញុំមានហើយខ្ញុំសូមអ្នកជំនាញ មេត្តាផ្តល់ជាយោបល់ ។

លោកបានដកស្រង់សម្តី ឌុច ថា ឌុច និយាយថា គាត់បានបង្រៀន គឺថាចំណង់បង្រៀនរបស់គាត់ គឺនៅក្នុងឈាមលោហិតរបស់គាត់ ។ ថាតើក្នុងជីវិតរបស់គាត់ហ្នឹង គាត់ចូលចិត្តធ្វើជាគ្រូ ចង់ធ្វើជាគ្រូ គាត់ជាអ្នកបរិច្ចាគការបង្រៀនគណិតវិទ្យា មុនពេលចូលបដិវត្តន៍ ហើយគាត់ជាគ្រូនៅម-១៣

ហើយនៅ ស-២១ ក៏គាត់ជាគ្រូ ជាវិធីសាស្ត្រសួរចម្លើយទារុណកម្មពីការឃុំខ្លួន ហើយបន្ទាប់មករហូតដល់ពេលគាត់ឃុំខ្លួនចុងក្រោយនេះ គាត់បានធ្វើជាគ្រូគណិតវិទ្យា ហើយគាត់ជាគ្រូទៀតនៅប្រទេសចិន ហើយកន្លែងផ្សេងទៀតនៅព្រំប្រទល់ថៃ ។

**ស៖** អ៊ីចឹងលោកអ្នកជំនាញអាចនិយាយបានទេថា ការបង្រៀនហ្នឹង គឺជាបេះដូងផុសចេញពីក្នុងចិត្តរបស់គាត់ គាត់ចូលចិត្តបង្រៀនហ្នឹង?

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលបូ)** គឺអ៊ីចឹងមែន យើងឯកភាពជាមួយលោក ដែលនិយាបែបនេះ ។

**ស៖** តើត្រឹមត្រូវទេ ដែលយើងអាចនិយាយថា ដូចជាសិស្សដែលល្អ គឺត្រូវតែគោរពគ្រូ ហើយអ្នកណែនាំ ហើយបើគាត់ជាគ្រូម៉ឺងម៉ាត់ គាត់ធានាថាឲ្យសិស្សគោរពវិន័យ ការត្រួតត្រា ហើយត្រូវតែគោរពមកគាត់វិញ ក្នុងចំណោមសិស្ស ឬក៏អ្នកដែលនៅក្រោមបង្គាប់របស់គាត់ត្រូវគោរពគាត់ តើអ៊ីចឹងដែរឬទេ?

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលបូ)** គឺថាចំពោះមនុស្សដែលគាត់បង្រៀន លោកចង់និយាយអ៊ីចឹង ឬក៏យ៉ាងម៉េច? ចម្លើយយើងមិនបានសួរសំណួរផ្ទាល់ទៅជនជាប់ចោទទេ ប៉ុន្តែយើងបានពិនិត្យមើលកិច្ចការ ហើយនិងរបាយការណ៍ដែលបញ្ជាក់អំពីការបង្រៀន ហើយពីសមត្ថភាពនៃការផ្ទេរចំណេះដឹង អំពីចំណេះ ធ្វើ ហើយតាមពិតនោះ គាត់ជាគ្រូល្អ គាត់ជាមនុស្សដែលជាមនុស្សយកចិត្តទុកដាក់ក្នុងការជួយអ្នកដទៃ ហើយតាមដានការងារ គោរពទៅតាមក្របខណ្ឌនៃការបង្រៀន ហើយតាមដានលទ្ធផលនៃការបង្រៀន ។

**ស៖** សូមអរគុណចំពោះការបំភ្លឺ ។ បន្ទាប់ចូលបដិវត្តន៍ ដែលគាត់អះអាងថា គាត់បានចូលដោយស្ម័គ្រចិត្ត ដោយផ្អែកទៅលើឧត្តមគតិជួយដល់សង្គម ហើយគាត់ក៏និយាយថា ជាមនោគមវិជ្ជាឆ្វេង ប៉ុន្តែគាត់ត្រូវបានគេឃុំខ្លួនពីរឆ្នាំនៅក្នុងគុកនោះ នៅពេលដែលគេឃុំខ្លួនគាត់នោះ គាត់និយាយថា ហើយអ្នកជំនាញបានដកស្រង់ថា គាត់បានរស់នៅក្នុងការភ័យខ្លាចរៀងរាល់ថ្ងៃ ហើយគាត់ខ្លាចគេសម្លាប់ ដោយសារឃើញថា គេយកអ្នកទោសទៅសម្លាប់។ តើត្រឹមត្រូវទេ យើងនិយាយពេលនេះ គឺថាបទពិសោធដែលគាត់ឆ្លងកាត់នោះ ជនជាប់ចោទបានឆ្លងកាត់នោះជាកម្រិតមួយដែលថា គាត់កំណត់រូបភាពមួយឲ្យគាត់យកមកប្រើនៅពេលដែលគាត់ធ្វើជាប្រធានម-១៣ ហើយនិងប្រធានស-២១ដែរឬទេ?

[១៤:២៩:៣៥]

**ឆៈ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលបូ)** ប្រហែលលោកលើកឡើងអំពីសំណួរទាក់ទងទៅនឹងដើមកំណើតនៃតិចនិចដែលគាត់បានប្រើប្រាស់។ យើងមិនអាចធ្វើការសន្និដ្ឋាន ទាក់ទងទៅនឹងសំណួរនេះទេ ។ សំណួរនេះក៏យើងបានសួរខ្លួនឯងផងដែរ ដោយសារតែគាត់ជនជាប់ចោទហ្នឹងក៏បានលើកឡើងអំពីឥទ្ធិពលទទួលបានពីគ្រូបារាំងរបស់គាត់ ដែលគ្រូទាំងអស់នោះ គាត់មានការយល់ឃើញចំពោះជនជាតិវៀតណាម ។ ដូចនៅពេលដែលគេគិតអំពីលទ្ធភាព នៃអង្គការតក់ស្លុតមួយនៃបុគ្គលិកលក្ខណៈរបស់គាត់ ទាក់ទងទៅនឹងការរំលោភប៉ះពាល់ទៅដល់គាត់នោះ ។ ប៉ុន្តែ វាក៏មិនអាចអាចលេចចេញដោយឯកឯងនោះផងដែរ ហើយវាអាចកើត ជំរុញឲ្យគាត់មានភាពក្តៀវក្លា ហើយធ្វើឲ្យគាត់នេះ ធ្វើការរំលោភបំពានទៅលើបុគ្គលផ្សេងក្នុងស្ថានភាពដូចដែលគាត់ធ្លាប់រងគ្រោះ ។

**ឆៈ (វេជ្ជ. កា ស៊ុនបូណាត)** ជាការពិតណាស់ ជនជាប់ចោទធ្លាប់បានត្រូវគេឃុំឃាំងអស់រយៈពេលពីរឆ្នាំ នៅក្នុងរបបលោក លន់ នល់ ។ ប៉ុន្តែអ្វីដែលសំខាន់សម្រាប់ជនជាប់ចោទ គឺចលនាកុម្មុយនីស្ត ដើម្បីជួយដល់ប្រជាពលរដ្ឋក្រីក្រ ដែលជាឧត្តមគតិមួយដែលគាត់ប្រកាន់ជាប់ ។ នៅពេលដែលគាត់ចូលទៅក្នុងចលនាកុម្មុយនីស្តរបស់ខ្មែរក្រហម គាត់បានទទួលនូវនាទីជាប្រធានម-១៣ ដែលគាត់ទទួលទាំងបង្ខំចិត្ត ពីព្រោះគាត់មិនចូលចិត្តនឹងការងារដែលជាប៉ូលិសទេ ។ ប៉ុន្តែ ដោយសារតែតួនាទីគាត់ជាឧបករណ៍ដាច់ខ្នែររបស់បក្ស គាត់ប្រកែកលែងបាន អ៊ីចឹងគាត់ត្រូវតែបំពេញការងារនោះ ហើយដោយសារខ្លួនគាត់ជាមនុស្សម្នាក់ដែលមានទម្លាប់ធ្វើការងារណាក៏ដោយត្រូវធ្វើឲ្យបានល្អ ។ ហេតុដូច្នេះហើយបានជាគាត់ត្រូវបំពេញការងារនៅម-១៣ នោះ ដោយខំប្រឹងប្រែងស្រាវជ្រាវរកវិធីដើម្បីសួរចម្លើយហើយនិងឃុំឃាំង តែការងារនោះក៏មិនបានល្អប៉ុន្មានដែរ ដោយសារកន្លងមកនេះ អ្នកដែលជាប់ទោសនៅម-១៣ ហ្នឹង ត្រូវបានកញ្ឆក់កាំភ្លើងហើយ ដោយបាញ់អ្នកយាមរបួសពីរបីនាក់ ហើយគេរត់ទាំងអស់ ហើយគាត់ក៏សង្ឃឹមថា កំហុសនេះប្រហែលជាគេលែងឲ្យគាត់ធ្វើជាមន្ត្រីសន្តិសុខទៀតហើយ តែត្រូវបានគេរក្សាឲ្យគាត់នៅដដែល ដែលគាត់ក៏មានការមួយខកចិត្តដែរ ដែលគេនៅតែឲ្យគាត់ធ្វើកិច្ចការនេះ ។

លុះដល់គាត់ចូលមកកាន់ស-២១ នេះក៏ដូចគ្នាដែរ ព្រោះអីតួនាទីនេះ គាត់បានសាកល្បងប្រកែកដែរ តែប្រកែកមិនបាន ហើយដោយសារតែក្នុងបទបញ្ជា វិន័យនៃបដិវត្តន៍កុម្មុយនីស្តហ្នឹង គឺតឹងតែងបើថាអង្គការ ឬក៏ថ្នាក់លើថាម៉េច យើងប្រកែកអត់បាន គាត់ក៏ខំទ្រាំធ្វើទៅ ហើយវិធីសួរចម្លើយអីៗទាំងប៉ុន្មាន គាត់បានខំស្រាវជ្រាវរកឃើញហើយ បង្រៀនគេឲ្យចេះធ្វើ ។ ក្នុងនោះគាត់បានលើកឡើង

ថាពេលដែលគាត់ធ្វើការងារនៅស-២១ គាត់ត្រូវប្រកាន់វិន័យឲ្យតឹងតែង ដើម្បីកុំឲ្យអ្នកនៅក្រោមឱវាទហ្នឹង ធ្វើមានការធ្វោះធ្វោយ ។ ដូចជាគាត់មិនបានទៅសួរសុខទុកក្រុមគ្រួសារឪពុកម្ដាយទេ ដើម្បីអ្នកនៅក្រោមឱវាទនោះ ក៏មិនអាចទៅសួរសុខទុក្ខដែរ ពីព្រោះការងារនៅទីនោះ គឺនៅជាប្រចាំ ។

អ្វីដែលខ្ញុំបានឆ្លើយនេះ គឺជាព័ត៌មានដែលបានផ្ទាល់ពីលោក ឌុច ដែលផ្ទាល់តែម្ដង ហើយបើសិនជាចម្លើយខ្ញុំមិនបានចំនូវសំណួររបស់លោកទេ សូមលោកសួរម្ដងទៀត ។

[១៤:៣៤:៤៥]

**ស៖** សូមអរគុណ លោកសាស្ត្រាចារ្យនិងលោកស្រី ។ ប៉ុន្តែ យ៉ាងណាក៏ដោយខ្ញុំនឹងសួរសំណួរស្រដៀងៗហ្នឹងទៀត ។ លោក លោកស្រី អ្នកជំនាញបានលើកឡើងនៅក្នុងរបាយការណ៍ ហើយបានលើកឡើងព្រឹកមិញផងដែរ រហូតដល់ឆ្នាំ១៩៧៨ ឌុច មានការភ័យខ្លាចថា គាត់នឹងត្រូវគេសម្លាប់ផងដែរនៅស-២១ ដោយនៅពេលនោះ គាត់ឃើញសាស្ត្រាចារ្យ វន វ៉េត ត្រូវបានគេបញ្ជូនយកសម្លាប់ចោលដែរ ។ ប្រសិនអ៊ីចឹងមែន គាត់ភ័យខ្លាច ហើយគាត់មានការភ័យខ្លាចអ៊ីចឹងមែន ហេតុអ្វីបានជាលោកលោកស្រីគិតថា គាត់នៅតែបន្តចូលទៅក្នុងចលនាខ្មែរក្រហមទៀត រហូតដល់ចុងទសវត្សរ៍៨០ ហើយរហូតដល់ចុងទសវត្សរ៍ទី៩០ ដោយសារការភ័យខ្លាចទាំងអស់នោះ ហាក់ដូចជាមិនទាន់រំសាយនៅឡើយទេ?

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** សូមអរគុណ ចំពោះការលើកឡើងនូវសំណួរនេះរបស់លោក ។ សំណួរនេះក៏ខ្ញុំបានសួរផ្ទាល់ទៅលោក ឌុច ដែរ ថាចាប់ពីឆ្នាំ១៩៧៣ នៅពេលដែលគាត់បានចូលប្ដេជ្ញាចិត្តហើយ បានចូលប្ដេជ្ញាចិត្ត ហើយបានស្ម័គ្រចិត្តចូលទៅក្នុងចលនាបដិវត្តន៍កុម្មុយនីស្ដនេះ គាត់ក៏មានការខកចិត្តដោយសារឃើញទម្រង់នៃសកម្មភាពរបស់ក្រុមអ្នកកុម្មុយនីស្ដនេះ ដែលពីមុនសន្យាថា រកសេចក្ដីសុខជូនប្រជាជន រកសេចក្ដីរីកចម្រើនជូនប្រជាជន ហើយបែជាឃើញយកមនុស្សទៅសម្លាប់ ។ តែគាត់មានប្រសាសន៍ថា ជាការមួយជ្រុលពេលដកខ្លួនមិនរួច ហើយដូចនឹងពាក្យរបស់គ្រូរបស់គាត់ម្នាក់បាននិយាយថា អ្នកនយោបាយ ប្រៀបបាននឹងស្ពឺដែលនៅក្នុងប្រព័ន្ធខ្សែខ្សែងនៃម៉ាស៊ីន ។ បើកាលណាយើងចង់ដកខ្សែខ្សែងណាមួយចេញពីម៉ាស៊ីន លុះត្រាតែម៉ាស៊ីនរលត់បានដកចេញបាន ។

ដូច្នេះក្នុងពេលដែលចលនាកុម្មុយនីស្ដនេះកំពង់តែដំណើរការខ្លួនគាត់ដកចេញអត់រួចទេ ។ សាកល្បងដកចេញវាមានតែស្លាប់ ។ ហេតុដូច្នេះហើយ បានជាមកទល់នឹងពេលដែលគាត់ឃើញឈ្មោះ វន វ៉េត នេះត្រូវបានសម្លាប់ ខ្លួនគាត់ភ័យ ព្រោះថា វន វ៉េត ជាមិត្តរបស់គាត់ ដែលជិតស្និទ្ធ និងស្មោះត្រង់

ហើយត្រូវបានគេសម្លាប់ ។ គាត់ក៏គិតផងដែរថា តើថ្ងៃណាដល់វេនគាត់? ប៉ុន្តែគាត់មានទស្សនៈមួយយល់ឃើញថា បើគាត់ដកថយវាគ្រោះថ្នាក់ជាង ។ ដូច្នេះគាត់ទ្រាំអត់ និងធ្វើយ៉ាងណាបញ្ចេញកាយវិការសកម្មភាពឲ្យគេឃើញថា គាត់ពិតជាស្មោះត្រង់នឹងអង្គការ ។ ពេលនោះ គាត់រួចផុតពីការចោទប្រកាន់ ពីការសម្លាប់ ។

ដូច្នេះ ការដោះស្រាយរបស់គាត់នៅក្នុងកាលៈទេសៈបែបនោះ ជាការដោះស្រាយមួយសមហេតុសមផល ព្រោះថាបើសិនជាគាត់រត់ចេញក៏មិនដឹងទៅទីណាដែរ ពីព្រោះទីណាក៏ដោយគេតាមដាន គេតាមជាប់រហូត បើចេញទៅមានតែគេតាមសម្លាប់គាត់ ។ សូមអរគុណ ។

[១៤:៣៩:០០]

**ស៖** ខ្ញុំសូមសួរសំណួរនេះទៅកាន់សាស្ត្រាចារ្យ ហ្កៀលបូ ប្រសិនបើបុគ្គលម្នាក់ស្ថិតក្នុងភាពភ័យខ្លាច ក្នុងពេលដែលគាត់ដឹកនាំមន្ទីរសន្តិសុខដូចស-២១ អ៊ីចឹង គឺការភ័យខ្លាចនៃការស្លាប់ ប៉ុន្តែនៅក្នុងអំឡុងពេលបីឆ្នាំ ប្រាំបីខែ ម្ភៃថ្ងៃនោះ គាត់បែជារៀបការ ហើយផ្តល់កំណើតដល់កូនពីររូបនៅពេលនុំង ហើយឪពុកម្តាយមកលេង ។ តែនៅពេលជាមួយគ្នានោះ អ្នកទាំងឡាយត្រូវបានដកសិទ្ធិរស់រានមានជីវិត ត្រូវទទួលរងទណ្ឌកម្ម ស្ត្រីមានផ្ទៃពោះ កូនក្មេងត្រូវបានគេយកទៅសម្លាប់ចោល ។ តើសតិអារម្មណ៍យ៉ាងម៉េច ដែលបង្ហាញនៅក្នុងខ្លួនបុគ្គលនុំង?

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលបូ)** ខ្ញុំចង់ឆ្លៀតឱកាសឆ្លើយតប ទៅនឹងសំណួររបស់លោកតំណាងសហព្រះរាជអាជ្ញាដែលមានលក្ខណៈសំខាន់ណាស់ ។ ខ្ញុំសូមរំឭកសាជាថ្មី អ្វីដែលយើងបានគិតចំពោះជនរងគ្រោះ ដោយសារតែនៅក្នុងករណីណាក៏ដោយ នៅពេលដែលយើងអ្នកជំនាញនៅទីនេះ យើងត្រូវតែពន្យល់ អំពីដំណើរការចិត្តសាស្ត្រទាក់ទងទៅនឹងជនជាប់ចោទ ដែលគាត់ជាជនជាប់ចោទចំពោះឧក្រិដ្ឋកម្មរបស់គាត់ ។

យើងចង់រក្សាតួនាទីអព្យាក្រឹតរបស់យើងនៅក្នុងពេលនេះនិងនៅថ្ងៃស្អែកផងដែរ ។ ខ្ញុំសូមរំឭកភាពអព្យាក្រឹតរបស់យើងខ្ញុំឆ្លើយតបទៅនឹងសំណួររបស់លោកសហព្រះរាជអាជ្ញា ហើយយើងខ្ញុំបានសួរសំណួរមកកាន់ខ្លួនឯង ។ ប៉ុន្តែនៅទីនេះគឺយើងអាចឃើញអំពីសតិស្មារតីធម្មតារបស់បុគ្គលនេះ បានន័យថា នៅពេលជាមួយគ្នា នៅពេលតែមួយគាត់អាចជាឪពុកដ៏ល្អមួយរូប ហើយនៅពេលជាមួយគ្នាគាត់ដឹងថា មានកូនក្មេងសម្លាប់នៅស-២១ផងដែរ ។ តើយើងអាចពន្យល់យ៉ាងម៉េច? យន្តការចិត្តសាស្ត្រដែលយើងនិយាយព្រឹកមិញ គឺវាពាក់ព័ន្ធទៅនឹងភាពប្រទូសរ៉ាយរវាងការទទួល និងការបដិសេធយក

ការពិត គឺភាពភាពប្រទូសរ៉ាយនៅក្នុងខ្លួនយើង ។ យើងបដិសេធមិនសួរសំណួរខ្លួនឯងទាក់ទងទៅនឹងវេទនាអារម្មណ៍ ។

[១៤:៤១:៤២]

យើងអាចមិនមានអារម្មណ៍ថា មនុស្សផ្សេងនោះ គាត់មិនមានលក្ខណៈស្ថិតនៅក្នុងស្ថានភាពអមនុស្សធម៌ទេ ដោយសារយើងមិនយល់ទៅលើស្ថានភាពហ្នឹង ។ អ៊ីចឹងបញ្ហានេះវាទាក់ទងទៅនឹងយន្តការនៃបញ្ហាចិត្តសាស្ត្រ ដោយសារយើងពិចារណាអ្នកផ្សេងថាជាខ្មាំង ហើយយើងទៅផ្ទះ ឬក៏កន្លែងធ្វើការដោយមិនមានអារម្មណ៍ និងវេទនាអារម្មណ៍ និងសេចក្ដីមនោសញ្ចេតនាទាំងអស់នេះ ។ យើងត្រូវយល់ថា បុគ្គលម្នាក់ដែលគាត់មានការយល់ដឹងអំពីអ្វីដែលគាត់ធ្វើ គឺការបម្រើបក្សកុម្មុយនីស្ដអង្គការនោះ គឺគាត់ធ្វើការងារទាំងឡាយសម្រាប់ផលប្រយោជន៍រួម ប្រយោជន៍សមូហភាពនៅពេលនោះ គឺជាប្រយោជន៍សមូហភាពរបស់អង្គការ ។

**ស៖** ដោយសារតែពេលវេលារបស់ខ្ញុំមានកំណត់ ខ្ញុំសូមសួរសំណួរមួយទៀតដែលវាជាប់ពាក់ព័ន្ធទៅនឹងវត្តមានរបស់លោកនៅទីនេះ ។ ចំពោះសេចក្ដីប្រកាសអំពីការសោកស្ដាយ និងវិប្បដិសារីរបស់ជនជាប់ចោទ ។ ដើមបណ្ដឹងរដ្ឋប្បវេណីទាំងឡាយដែលគាត់ជាជនរងគ្រោះ បានមកផ្ដល់សេចក្ដីថ្លែងនៅចំពោះមុខតុលាការនេះ ថាពួកគាត់មិនផ្ដល់ការអត់ឱនទោសដល់ជនជាប់ចោទនោះទេ ដោយ-សារពួកគេមិនអាចទទួលយកបាននូវវិប្បដិសារីរបស់ជនជាប់ចោទ ។ ចំពោះការយល់ឃើញរបស់ខ្ញុំ យើងឃើញថាអាចមានវិប្បសារីចំនួនពីរប្រភេទ ។ វិប្បដិសារីជាទូទៅ បានន័យថា ខ្ញុំសូមអភ័យទោសចំពោះឧក្រិដ្ឋកម្មខ្មែរក្រហម និងវិប្បដិសារីផ្ទាល់ខ្លួនរបស់បុគ្គលដែលគាត់សម្ដែងចំពោះជនរងគ្រោះកើតចេញពីឧក្រិដ្ឋកម្មរបស់ខ្ញុំ ។

សូមឲ្យលោកជម្រាបខ្ញុំឲ្យថាស្ថិតក្នុងស្ថានភាពរបស់ជនជាប់ចោទ ថាតើប្រភេទនៃការ នៃវិប្ប-ដិសារីយ៉ាងម៉េចដែលជនរងគ្រោះចង់បានពីឧក្រិដ្ឋកម្មដែលប៉ះពាល់ និងកើតចំពោះគាត់នោះ?

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលបូ)** វិប្បដិសារីដែលគេចង់បាននៅទីនេះ គឺអាចលទ្ធភាពអាចដាក់ខ្លួនឯងនៅក្នុងស្ថានភាពរបស់បុគ្គលម្នាក់ក្នុងលក្ខណៈជាក់ស្ដែង ។ ជនរងគ្រោះប្រហែលជាមិនមានអារម្មណ៍យល់ឃើញថា ឌុច ពិតជាអាចមានអារម្មណ៍ ឬក៏គិតឃើញ ឬក៏ប្រមើលស្រមើលស្រមៃនូវអ្វីដែលកើតឡើងចំពោះជនរងគ្រោះ និងការឈឺចាប់របស់ពួកគេ ។ យើងក៏បានពន្យល់យន្តការចិត្តសាស្ត្ររបស់ជនជាប់ចោទនៅព្រឹកមិញនេះផងដែរ យើងក៏បាននិយាយអំពីការវិវត្តន៍និងការផ្លាស់ប្ដូរ ។ ជាការពិតយើង

អាចឃើញមានការវិវត្តន៍ អំពីការយល់ដឹងរបស់ជនជាប់ចោទ ។

[១៤:៤៥:00]

ខ្ញុំអាចនិយាយថា របៀបដែលជនជាប់ចោទអាចលើកឡើងដោយខ្លួនឯងចំពោះជនរងគ្រោះកាលពីប៉ុន្មានខែមុននេះ គឺជាអ្វីដែលយើងបានកត់សម្គាល់កាលពីសប្តាហ៍មុន ។ ហើយគាត់ក៏បានធ្វើដំណើរទៅមុខ ហើយធ្វើដំណើរហួសទៅលើស្ថានភាពនៃការសម្តែងចេញនូវមនោសញ្ចេតនារបស់គាត់ផងដែរ។

**ស៖** តើលោកស្រីគិតថា ការស្តាយក្រោយដោយមិនមានការសម្តែងអំពីកំហុសរបស់គាត់ដែលប្រព្រឹត្តចំពោះជនរងគ្រោះទាំងអស់នោះ តើវាមានផលវិបាកដែលវាធ្លាក់ទៅលើជនរងគ្រោះដែរឬទេ?

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហៀលបូ)** ពិតជាមិនដូច្នោះទេ ។ បញ្ហាចោទនៅទីនេះ គឺទាក់ទងទៅនឹងការសោកស្តាយនិងវិប្បដិសារីចំពោះកំហុស ។ យើងនឹងគិតបញ្ហានេះក្នុងលក្ខណៈស៊ីជម្រៅដោយមានសហសេវិករបស់យើងនៅទីនេះផងដែរ ។ គឺយើងសូមលើកអំពីសញ្ញាណនៃការបង្កើតអត្តសញ្ញាណនៅក្នុងរបបខ្មែរក្រហម និងវប្បធម៌នៃការបង្ហាញអំពីការសោកស្តាយចំពោះទោស ។

នៅក្នុងបរិបទលោកខាងលិច ទាក់ទងទៅនឹងការស្វែងយល់អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបែបនេះ យើងរំពឹងថា នឹងមានការបង្ហាញ និងឆ្លើយតបសារភាពអំពីកំហុសរបស់គាត់ ។ ប៉ុន្តែវាអាចសម្តែងចេញតាមលក្ខណៈការធ្លាក់ទឹកចិត្ត ការមានអារម្មណ៍ចង់សម្លាប់ខ្លួន យើងមានគំនិតទាំងអស់នេះនៅក្នុងវប្បធម៌បរទេសខាងលិច ។

បុគ្គលជាច្រើនដែលគាត់មានប្រវត្តិដូច ឌុច នៅពេលដែលពួកគេមានអារម្មណ៍ថាខ្លួនមានទោសនេះជាអ្វីដែលពួកគេអាចសម្តែង ចេញតាមរយៈអារម្មណ៍របស់ពួកគេ ប៉ុន្តែវាខុសពីស្ថានភាពរបស់ជនជាប់ចោទ ដែលវាមានការជឿជាក់ទៅលើបញ្ហាស្មារតីរបស់ជនជាប់ចោទ ។ មិនត្រឹមតែបញ្ហាការទទួលស្គាល់នោះទេ គាត់សួរខ្លួនឯងថា តើគាត់ត្រូវធ្វើអ្វីដើម្បីស្តារនិងប៉ះប៉ូវទៅលើការប្រព្រឹត្តិអំពើទាំងអស់នេះ ។ អ៊ីចឹងវាជាបញ្ហាកើតនៅក្នុងស្មារតីរបស់គាត់ ។ ហើយបញ្ហានោះមិនមែនទាក់ទងទៅនឹងស្ថានភាព ឬក៏យុទ្ធសាស្ត្រនោះទេ គឺជាការចោទសួររបស់គាត់នៅក្នុងស្មារតី គឺវាទាក់ទងទៅនឹងសញ្ញាណនៃជនរងគ្រោះ ដែលវាវិវត្តន៍នៅក្នុងស្ថានស្មារតីរបស់គាត់ ។

**ស៖** ទាក់ទងទៅនឹងការសម្តែងវិប្បដិសារី និងភាពមានទោស ខ្ញុំចង់ឲ្យលោក លោកស្រីសម្តែងអារម្មណ៍ក្នុងស្ថានភាពជាជនរងគ្រោះ ។ តើជនរងគ្រោះគាត់ពេញចិត្តថា ការឈឺចាប់របស់គេគឺវាមានសម្ពាធនិងទម្ងន់ដែរឬទេ? ប្រសិនបើជនជាប់ចោទគាត់បង្ហាញអំពីកំហុសគាត់ទូទៅ ដែលគាត់លើក

ឡើងថា ខ្ញុំសូមអភ័យទោសចំពោះឧក្រិដ្ឋកម្មខ្មែរក្រហម ប៉ុន្តែខ្ញុំមិនមែនជាអ្នកទទួលខុសត្រូវនោះទេ ។ ថាតើការសម្តែងវិប្បដិសារីបែបនេះវាអាចមានផលប៉ះពាល់ទៅដល់ជនរងគ្រោះដែរឬទេ?

[១៤:៤៨:៣៦]

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលប្ង)** វាមិនមានផលវិបាកទេ ។ ខ្ញុំមិនគិតដូច្នោះទេ ។ ខ្ញុំមិនអាចនិយាយក្នុងស្ថានភាពជាជនរងគ្រោះនោះទេ។ ប៉ុន្តែ ប្រសិនបើជាលោកសួរឲ្យខ្ញុំធ្វើជាជនរងគ្រោះ ស្ថិតក្នុងស្ថានភាពជនរងគ្រោះនេះ គឺខ្ញុំសូមលើកឡើងថា ទោះបីជាយើងនៅតែមានសញ្ញាសួរនៅក្នុងខួរក្បាលរបស់យើងទាក់ទងទៅនឹងអត្តចរិតរបស់ជនជាប់ចោទក៏ដោយ ។ គាត់តែងតែផ្តល់ហេតុផលតាមលក្ខណៈគណនាគណិតវិទ្យា ហើយគាត់ផ្តល់ហេតុផលតាមលក្ខណៈតក្កវិទ្យា ។ ហើយគាត់មានឆន្ទៈក្នុងការទទួលស្គាល់នូវអ្វីដែលអាចបង្ហាញត្រឹមត្រូវ និងគាត់មិនទទួលយកនូវភាពៈដែលមិនអាចបង្ហាញបាន ។ ដូច្នេះការបដិសេធមិនទទួលខុសត្រូវចំពោះរបបខ្មែរក្រហមនោះ។ ប៉ុន្តែយ៉ាងណាក៏ដោយគាត់ទទួលខុសត្រូវចំពោះស្នារតីរបស់គាត់ដែលនៅមន្ទីរស-២១ ។ នេះគឺជាដំណើរការចិត្តសាស្ត្រដែលវាស្ថិតនៅក្នុងអត្តចរិតបុគ្គលិកលក្ខណៈរបស់គាត់ ។ វាមិនអាចសម្រាលនឹងជួយទៅដល់ជនរងគ្រោះនោះទេ ចំពោះអារម្មណ៍ឈឺចាប់របស់គាត់ ប៉ុន្តែវាមានសារសំខាន់ក្នុងការលើកឡើងថា គាត់ត្រូវសួរខ្លួនឯងនូវសំណួរថាតើយើងត្រូវធ្វើយ៉ាងម៉េចដើម្បីជួយនិងឲ្យវារំសាយ ឬក៏ប៉ះប៉ូវទៅលើព្យសនកម្មទាំងអស់នោះ?

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** សូមបន្ថែមដែរថា ខ្ញុំមានទស្សនៈនិងយោបល់ដូចអ្នកស្រី ស៊ីលរ៉ូនីដែរ ប៉ុន្តែដោយសារខ្លួនខ្ញុំក៏ជាអ្នករងគ្រោះមួយដែរ អ៊ីចឹងក្នុងពេលនេះខ្ញុំមិនអាចបញ្ចេញ ឬបង្ហាញនូវអ្វីដែលជាប្រតិកម្មផ្លូវចិត្ត ឬក៏ជាគំនិតឯកជនរបស់ខ្ញុំបានទេ ព្រោះខ្ញុំត្រូវបំពេញការងារមួយដែលមានលក្ខណៈអន្តរជាតិ ។

**លោក អានីស អះមេដ៖**

លោកប្រធាន ខ្ញុំដឹងថាខ្ញុំមានប្រហែលជាប្រាំ ឬក៏ប្រាំពីរនាទីទៀត ប៉ុន្តែខ្ញុំសូមការអនុញ្ញាត និងអនុគ្រោះពីលោកប្រធានផ្តល់រយៈពេលឲ្យខ្ញុំ ប្រាំនាទីបន្ថែមទៀត ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត សូមអញ្ជើញ ។

**សួរដោយលោក អានីស អះមេដ៖**

សូមអរគុណលោកប្រធាន ។

**សះ** លោកសាស្ត្រាចារ្យ ស៊ីរ៉ូនី ហ្កៀលបូ ជនរងគ្រោះជាច្រើនដែលគាត់មកផ្តល់សេចក្តីថ្លែងនៅក្នុងតុលាការនេះបានសម្តែងជាសាធារណៈ និងនៅចំពោះមុខតុលាការនេះថា ពួកគាត់មិនយល់ចិត្តសាស្ត្រគណិតវិទ្យារបស់ជនជាប់ចោទនេះទេ ។ ជនរងគ្រោះបដិសេធពុំទទួលយកការឈឺចាប់ក្នុងនាមជាជនរងគ្រោះ ហើយជនជាប់ចោទគាត់ពុំទទួលស្គាល់ជនរងគ្រោះ ដោយសារតែពុំមានឯកសារស-២១ មិនមែនគ្រប់ករណីនោះទេ ប៉ុន្តែគាត់បានលើកឡើងថា ឈ្មោះមិនមាននៅក្នុងបញ្ជីសារភាពដូច្នេះហើយជនរងគ្រោះនោះប្រហែលជាមិនឆ្លងកាត់ស-២១ ឬក៏គាត់លើកឡើងថាមិនមានឯកសារផ្សេងនៅស-២១ តាមការពិនិត្យអ៊ីចឹងហើយគឺគាត់មិនទទួលស្គាល់អំពីជនរងគ្រោះទាំងអស់នោះ ។ ជនរងគ្រោះទាំងនោះគឺបានទទួលនូវការ មិនទទួលស្គាល់ការឈឺចាប់របស់គាត់ពីជនជាប់ចោទ ។ ហើយវាផ្ទុយទៅនឹងការសម្តែងវិប្បដិសារី និងការទទួលស្គាល់ទោសរបស់គាត់ ថាតើវាយ៉ាងម៉េចដែរទាក់ទងទៅនឹងបញ្ហានេះ?

**ឆះ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលបូ)** យើងនៅទីនេះយើងបានស្បថរួចហើយ បានន័យថាយើងសម្តែងនិងនិយាយតែការពិត ។ វាជាបញ្ហាសាមញ្ញនោះទេ ប៉ុន្តែខ្ញុំសូមបន្ថែមប្រធានបទមួយដែលខ្ញុំបានលើកឡើងសួរទៅកាន់ ឌុច កាលពីសប្តាហ៍មុន ទាក់ទងទៅនឹងការវិវត្តន៍របស់ជនជាប់ចោទ យើងបានផ្តោតទៅលើវិវត្តន៍ចិត្តសាស្ត្ររបស់ជនជាប់ចោទ ថាតើគាត់ដំណើរការទៅដល់ណា? ហើយវាកើតឡើងយ៉ាងម៉េចចំពោះគាត់? សាសនាសម្រាប់គាត់គឺជាការសង្គ្រោះ និងព្យាបាលចិត្តគាត់មួយ ។ ហើយគាត់បាននិយាយខ្លួនឯងថា គាត់បានលើកឡើងអំពីបញ្ហាគ្រិស្តសាសនា បានន័យថា យើងស្រលាញ់ព្រះ គោរពព្រះ យើងត្រូវស្រលាញ់អ្នកដទៃ ដូចព្រះអង្គម្ចាស់ស្រលាញ់យើង ។ អ៊ីចឹងគាត់និយាយអំពីជនរងគ្រោះនិយាយអំពីអ្នកដទៃដូចយើងដែរ។ ហើយយើងបានពិភាក្សា។ ការពិភាក្សានោះគឺជាការពិភាក្សាសាមញ្ញគឺការដែលយើងចង់ស្វែង យល់ថាតើជនជាប់ចោទស្ថិតនៅក្នុងស្ថានភាព ដែលថាគាត់បានយល់អំពីអ្នកដទៃដែរឬទេ? គាត់បានលើកឡើងថា វាចំពោះគាត់វាមិនភាពងាយស្រួលនោះទេ គាត់នៅតែជួបបញ្ហាលំបាកក្នុងការឈានជើងចេញពីការគិតតាមលក្ខណៈបែបគណិតវិទ្យា ក្នុងលក្ខណៈនៃការគិតរបស់ខ្មែរក្រហម ។ វាមិនមែនជាអ្វីដែលគេនិយាយយើងត្រូវជឿនោះទេ ប៉ុន្តែវាពាក់ព័ន្ធគ្នា ។ យើងបានពិភាក្សាទៅលើចំណុចទាំងអស់នេះ ។ នៅក្នុងចិត្តសាស្ត្ររបស់ ឌុច សព្វថ្ងៃនេះយើងឃើញមានការវិវត្តន៍ ប៉ុន្តែវាមានភាពលំបាកចំពោះគាត់ ។ ហើយគាត់ខុសពីរយៈពេលដែលគាត់កាលពីប៉ុន្មានខែមុន ។

ខ្ញុំសូមនិយាយដោយខ្លីថា គឺវាមានការវិវត្តន៍ផ្នែកការទទួលស្គាល់និងដឹង ចំពោះអ្នកដទៃជាពិសេសចំពោះជនរងគ្រោះពីជនជាប់ចោទ ។ ហើយយើងដឹងហើយបញ្ហានេះ វាមិនមានភាពងាយស្រួលសម្រាប់

ជនជាប់ចោទទេ ដែលគាត់ប្រើប្រាស់សាសនាជាការព្យាបាលរោគចិត្តរបស់គាត់ ។

[១៤:៥៥:៣២]

**សះ** ខ្ញុំមានសំណួរពីរទៀតទាក់ទងនឹងការស្តារឡើងវិញ ការកែប្រែជនជាប់ចោទឡើងវិញ ។ លោក លោកស្រីបានលើកឡើងនៅក្នុងចំណុចចុងក្រោយនៃរបាយការណ៍របស់លោកស្រីទាក់ទងទៅនឹងការកែប្រែស្តារលទ្ធភាពលទ្ធកម្ម ។ លោក លោកស្រីបានលើកឡើងថា ជនជាប់ចោទ អាចកែប្រែ ឡើងវិញនៅក្នុងចំណោមប្រជាជនរាប់លាននាក់ ដោយសារតែគាត់បង្ហាញនិន្នាការរស់នៅក្នុងសង្គមស៊ីវិលជាមួយគេ ។ តើលោក លោកស្រីយល់ស្របដែរឬទេ សម្រាប់គោលបំណងស្តារលទ្ធភាពកែប្រែឡើងវិញ? គឺវាមានសារសំខាន់ចំពោះបុគ្គលដែលគាត់ត្រូវធ្វើយ៉ាងណាត្រៀមខ្លួនកែប្រែឡើងវិញ ហើយវាអាចជាភាពមានសារសំខាន់ ចំពោះការប្រឈមទៅនឹងបុគ្គលនៅជុំវិញដែលគាត់ត្រូវស្តារលទ្ធភាពនិងកែប្រែពលកម្មនោះ ។ បានន័យថាត្រូវប្រឈមទៅនឹងអ្នកទាំងអស់នោះ ។ ហើយប្រជាជនទាំងឡាយនៅក្នុងប្រទេសនេះ គឺមានការឈឺចាប់ពីរបបខ្មែរក្រហម ។

តើលោក លោកស្រីគិតថា ទោះបីជាការស្រាវជ្រាវរបស់លោកថា គាត់អាចយកមកស្តារលទ្ធ-ភាពពលកម្មឡើងវិញ? ការស្តារលទ្ធភាពនោះលើកលែងតែមានការសោកស្តាយពីបុគ្គលផ្ទាល់តែម្តងហើយនិងការសោកស្តាយអំពីកំហុសរបស់គាត់ចំពោះឧក្រិដ្ឋកម្មទាំងអស់នោះ បើមិនដូច្នោះទេ វានឹងពិបាកណាស់ក្នុងការស្តារលទ្ធភាពពលកម្មកែប្រែ ដោយសារតែប្រជាជនមិនអាចទទួលយកបានទេ ចំពោះវិប្បដិសារី ដែលមិនមានលក្ខណៈជាក់ស្តែងនិងពិតប្រាកដនោះ ។ ហើយខ្ញុំសួរទៅលើបរិបទ នៅក្រៅប្រទេសកម្ពុជា ដូច្នេះទើបខ្ញុំសួរ ស៊ីរ៉ូនី ហ្គៀលបូ ថាតើជនជាប់ចោទនេះគាត់មានអារម្មណ៍យ៉ាងម៉េចទាក់ទងទៅនឹងអារម្មណ៍របស់ជនរងគ្រោះនោះ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី ហ្វ្រង់ស្វ័រ រូ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ ដោយវាផ្អែកទៅនឹងការអះអាង និងគោលការណ៍ដែលថា ឌុច នឹងមិនមានការសម្តែងវិប្បដិសារីផ្ទាល់ខ្លួនរបស់ខ្លួន ហើយវាហាក់ដូចជាអះអាងថា ឌុច គាត់មិនទទួលស្គាល់ទាំងស្រុងទៅលើការទទួលខុសត្រូវរបស់គាត់ ។ នេះគឺជាអ្វីដែលសហព្រះរាជអាជ្ញាបានលើកឡើងអម្បាញ់មិញ ប៉ុន្តែ យើងមិនអាចស្នើសុំអ្នកជំនាញឲ្យឆ្លើយតបសំណួរបិទ

បែបនេះនោះទេ ដូចដែលសហព្រះរាជអាជ្ញាបានសួរ ។ យើងអាចសួរថា យើងអាចនិយាយថា សហព្រះរាជអាជ្ញាបានលើកឡើងអំពីការពុំទទួលស្គាល់ទាំងស្រុងរបស់ជនជាប់ចោទ ។ នេះគឺជាសម្មតិកម្មខាងសហព្រះរាជអាជ្ញាបានលើកឡើងតែប៉ុណ្ណោះ ។

សូមអរគុណលោកប្រធាន ។ ដូច្នេះ ខ្ញុំសូមឲ្យសហព្រះរាជអាជ្ញា ធ្វើការកែតម្រូវទៅលើសំណួររបស់គាត់ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះជូនវេទិកាទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីធ្វើការកត់សម្គាល់ទៅលើមតិជំទាស់របស់មេធាវីការពារដែលបានធ្វើការជំទាស់អម្បាញ់មិញនេះ ។

**លោក អានីស អះមេដ៖**

សូមគោរពលោកចៅក្រម! គឺថាមេធាវីការពារគាត់មានទេពកោសល្យខ្ពស់នៅក្នុងសាលាក្ដីអន្តរជាតិនានា ហើយសាលាក្ដីនោះគឺមានសាលាក្ដីយើងមួយផងដែរ ដែលវាមានភាពខុសគ្នារវាងអ្នកជំនាញបញ្ជាក់ពីអង្គហេតុនិងជំនាញបញ្ជាក់ពីអំពើ ។ ដូច្នេះដែលថាសាក្សីដែលបញ្ជាក់អង្គហេតុយើងអាចសួរតែអ្វីដែលគាត់បានឃើញបានឮ ឬក៏បានឆ្លងកាត់ ។ ប៉ុន្តែជាមួយអ្នកជំនាញវិញ ដោយសារគាត់ គឺចៅក្រមជាអ្នកអញ្ជើញគាត់ ដើម្បីមកជួយធ្វើការវាយតម្លៃ ដោយសារគាត់មានជំនាញពិសេស សំណួរទាំងឡាយដែលត្រូវសួរទៅគាត់ គឺសំណួរអាចសួរឲ្យគាត់បញ្ជាក់មតិយោបល់របស់គាត់ ។ ហេតុនេះហើយលោក លោកស្រីចៅក្រម បានផ្ដល់ការណែនាំទៅដល់សាក្សី ដែលបញ្ជាក់អង្គហេតុ ហើយណែនាំថា សូមឲ្យអ្នកបញ្ជាក់ពីអ្វីដែលលោកបានឃើញ បានដឹង និងបានឮ ។ ប៉ុន្តែ ចៅក្រមមិនបានជូនដំណឹងទៅ អ្នកជំនាញនេះអំពីបញ្ហានោះទេ ដែលថាមានអ្នកជំនាញនៅកម្ពុជាមួយរូប ហើយនៅថ្នាក់អន្តរជាតិផងដែរ ដើម្បីជួយដល់អង្គជំនុំជម្រះដើម្បីស្វែងរកអំពីអត្តចរិតផ្លូវចិត្ត ចិត្តសាស្ត្ររបស់ជនជាប់ចោទ ហើយជាបញ្ហាដែលបញ្ជាក់អំពីរកឲ្យឃើញ អំពីការទទួលខុសត្រូវអំពីបទល្មើសរបស់គាត់នោះ។ អ៊ីចឹងហើយសំណួរដែលសួរឲ្យមានមតិយោបល់ពីអ្នកជំនាញនោះ គឺជាបញ្ហាមួយជាសំណួរដែលសមស្របមិនគួរនឹងមានការបដិសេធទេ ព្រោះគាត់មិនមែនជាសាក្សីរឿងអង្គហេតុទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

ប្រហែលជាខ្ញុំមិនយល់ច្បាស់ពីអ្វីដែលលោកលើកឡើង ។ ប៉ុន្តែ មិនសួរឲ្យសួរសំណួរយកមតិយោបល់អ្នកជំនាញនោះទេ ប៉ុន្តែខ្ញុំជំទាស់ចំណុចមួយ ដែលលោកបានធ្វើសម្មតិកម្មដើម្បីសួរ ដែលជាគំនិតរបស់លោកដែលធ្វើសម្មតិកម្មនោះ ។ ដូច្នេះហើយលោកបានប្រាប់ទៅអ្នកជំនាញថា សួរថានៅក្នុងលក្ខខណ្ឌទាំងអស់នោះ តើជនជាប់ចោទអាចនឹងស្តារសម្បទាបានដែរឬទេ? អ៊ីចឹងហើយគាត់មិនបាននិយាយពីអ្វីៗ ថាតើគាត់អាចនឹងស្តារសម្បទានេះជាគំនិត របស់សហព្រះរាជអាជ្ញាទេ ដែលលោកបានផ្តល់ដែលថាធ្វើការសម្មតិកម្ម ដើម្បីឲ្យអ្នកជំនាញលោកឆ្លើយនោះ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងត្រូវសម្រាកហើយ ។ បើបន្តទៀតអាចមានបញ្ហា ហើយបញ្ហាសំខាន់ចំពោះអ្នកបកប្រែភាសាទៀត ដូច្នេះអង្គជំនុំជម្រះប្រកាសសម្រាកដប់ប្រាំនាទីចាប់ពីពេលនេះទៅរហូតដល់ម៉ោងបីនិងដប់ប្រាំនាទី អញ្ជើញចូលវិញដើម្បីបន្តនីតិវិធី ។

មន្ត្រីតុលាការសម្របសម្រួលផ្តល់ទីកន្លែងសមរម្យ សម្រាប់ដល់អ្នកជំនាញ ហើយនិងអញ្ជើញគាត់មកកាន់ទីកន្លែងនេះឲ្យមុនពេលកំណត់ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមអញ្ជើញក្រោកឈរ!

*[សវនាការសម្រាកពីម៉ោង ១៥:០៤នាទី ដល់ម៉ោង ១៥:១៩នាទី]*

**ប្រធានអង្គជំនុំ៖**

អញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។

ហើយជាបន្តនេះ ខ្ញុំប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ខាតវ៉ាយថ៍ ដើម្បីនិយាយទៅកាន់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ។ សូមអញ្ជើញ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន ។

ការព្រួយបារម្ភរបស់មេធាវីការពារនោះគឺ ពាក់ព័ន្ធទៅនឹងមូលដ្ឋាននៃសំណួរដែលលោកសួរទៅ

អ្នកជំនាញ ប្រសិនបើសហព្រះរាជអាជ្ញាអាចសម្រួលសំណួររបស់លោកឡើងវិញ ជាឧទាហរណ៍នោះ ប្រសិនបើអង្គជំនុំជម្រះ មានរបៀបណាមួយផ្សេងពីអ្វីដែលលោកស្នើហ្នឹង គឺជាការសមស្រប ។

សូមអរគុណ ។

**សួរដោយលោក អានីស អះមេដះ**

សូមអរគុណលោកស្រីចៅក្រម ។ ខ្ញុំនឹងគោរពទៅតាមនោះ ។

**ស៖** លោកស្រីបណ្ឌិត ស៊ីរ៉ូនី ហ្កៀលបូ គឺមិនមែនភាគីណាមួយជាអ្នកសម្រេច អំពីពិរុទ្ធភាព អំពីការសោកស្តាយ ឬការវិប្បដិសារីរបស់គាត់នោះទេ ប៉ុន្តែអ្វីដែលខ្ញុំជម្រាបជូនអ្នកជំនាញនោះ គឺការបកស្រាយរបស់ខ្ញុំទាក់ទងទៅនឹងស្ថានភាពបច្ចុប្បន្នពេលនេះ ។ អ៊ីចឹង ខ្ញុំអាចសួរបានទេ បើសិនជាអង្គជំនុំជម្រះត្រូវសន្និដ្ឋានថា ពិរុទ្ធភាព ការសម្តែងពីពិរុទ្ធភាពរបស់ជនជាប់ចោទមិនពេញលេញ គឺមិនត្រូវបានកំណត់គុណភាព ហើយមិនបានផ្តោះទៅរកជនរងគ្រោះទេ ហើយការសម្តែងការសោកស្តាយហ្នឹងក៏មិនបានផ្តោះទៅរកជនរងគ្រោះម្នាក់ៗ ហើយគាត់ធ្វើជាទូទៅ ។ តើជនរងគ្រោះដែលក្នុងចំណោះនោះដែលថា ជនជាប់ចោទនឹងត្រូវស្តារសម្បទាទៅរស់ជាមួយគេវិញ តើអ្នកជំនាញយល់ថា ការដែលធ្វើស្តារសម្បទារបស់ជនជាប់ចោទ ទៅក្នុងមជ្ឈដ្ឋាននោះលោកយល់ដូចម្តេចដែរ?

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្កៀលបូ)** នៅពេលដែលខ្ញុំមានការអល់អែកបន្តិច អំពីសំណួររបស់លោក គឺថាចំពោះសំណួររបស់លោកថាតើជនជាប់ចោទអាចនឹងត្រូវស្តារសម្បទាវិញ គឺថាផ្អែកទៅលើការសិក្សាវាយតម្លៃរបស់យើងនេះគឺបរិបទ ដែលលោកលើកឡើងអំពីជនរងគ្រោះ ខ្ញុំមិនច្បាស់លាស់នៅក្នុងកម្រិតនេះទេ អ៊ីចឹងហើយខ្ញុំសូមប្រគល់វេទិកានេះជូនទៅសហសេវិករបស់ខ្ញុំ លោកបណ្ឌិត កា ស៊ុនបូណាត ។

[១៥:២២:៣៧]

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** សូមឆ្លើយជូនថា ក្នុងលក្ខខណ្ឌដែលលោកបានលើកឡើងនេះ ហើយដែលយើងបានធ្វើរបាយការណ៍បញ្ជាក់ថា អាចនឹងកែប្រែបាន ដោយយើងយល់ឃើញថា កន្លងមកមុននឹងត្រូវបានឃាត់ខ្លួន ជនជាប់ចោទបានរស់នៅៗក្នុងសហគមន៍ ហើយបានទាំងបម្រើជាគ្រូបង្រៀននៅសាលាបឋមសិក្សារួចទៅហើយ ។ ដូច្នេះឃើញថា គាត់បានរស់នៅដោយសម្របខ្លួនជាមួយនឹងសង្គមថ្មីមួយបាន ជាបណ្តើរៗ ថ្វីដ្បិតតែ ការលើកឡើងនូវការសូមទោស ឬក៏ការសម្តែងនូវទុក្ខភាពដែលមានទោសនោះមិនចំពោះលើបុគ្គលម្នាក់ៗក្តី ក៏ប៉ុន្តែឥរិយាបទដែលគាត់មាននេះអាចឆ្លុះបញ្ចាំងថាគាត់អាចសម្របខ្លួននៅទីណាដែលអាចគាត់ទៅរស់នៅបាន ។ នេះដោយយល់ទៅតាមអ្វីដែលយើងខ្ញុំបាន

សួរនាំ អំពីការរស់នៅកន្លងមករបស់គាត់ មុនពេលដែលគាត់ត្រូវចាប់ខ្លួន ។

**ស៖** លោកប្រធាន! ខ្ញុំមានសំណួរចុងក្រោយមួយ ។ ជាថ្មីម្តងទៀត សំណួរនេះជូនទៅអ្នកជំនាញទាំងពីររូប។ នេះជាករណីរបស់សហព្រះរាជអាជ្ញា ដែលថាយ៉ាងហោចណាស់នៅចុងទស្សវត្សរ៍ ៦០ រហូតដល់ពេលដែលគាត់ត្រូវបានគេចាប់ខ្លួន ជនជាប់ចោទបានរស់នៅៗក្នុងតំបន់មួយចំនួនដែលមានស្វាមីភក្តិចំពោះខ្មែរក្រហម នេះជាការអំណះអំណាងរបស់សហព្រះរាជអាជ្ញា រហូតមកដល់ឆ្នាំ ១៩៧៩ គាត់រស់នៅក្នុងតំបន់ដែលជាតំបន់ស្វាមីភក្តិចំពោះខ្មែរក្រហម ។ ហើយក្រោយមកគាត់បានទៅរស់នៅក្នុងព្រំប្រទល់ តំបន់ព្រំប្រទល់ថៃ ដែលថានៅក្នុងចំណោមនោះមានអតីតពួកខ្មែរក្រហមនោះផងដែរ ។ រហូតដល់ពេលគាត់ត្រូវបានគេចាប់ខ្លួនរហូតដល់ឆ្នាំ១៩៧៩ នោះគឺថាពេលវេលាដ៏ច្រើនបំផុតនោះ គាត់បានរស់ដោយប្រើឈ្មោះក្លែងបន្លំ ។ គាត់ប្រើឈ្មោះជាច្រើន ក្នុងកម្រិតមួយដែលថា កុំឲ្យគេរកឃើញគាត់បាន រហូតដល់ក្រោយបំផុតដែលគេអ្នកកាសែតបរទេសពីរនាក់រកឃើញ ហើយដែលគេបានកត់សម្គាល់ថា ពេលរកឃើញនោះ គាត់មានការខឹងសម្បាទៅគេ ។

តើលោក លោកស្រីយល់ដូចម្តេច អំពីទស្សនៈនៃជនរងគ្រោះ ដែលថាពួកគេរស់នៅក្រៅតំបន់ដែលថាមិនមែនជាតំបន់ ស្វាមីភក្តិចំពោះខ្មែរក្រហម តើទស្សនៈរបស់លោក លោកស្រីនោះខុសដូចម្តេចអំពីដែលថាជនជាប់ចោទអាចនឹងសម្របសម្រួល ឬក៏អាចនឹងស្តារសម្បទារស់នៅវិញបាននោះ? ចុះថាតើសម្បទារបស់គាត់នោះ គឺថាអាចរស់នៅជាមួយនឹងតំបន់មួយ ដែលថាក្នុងចំណោមជនរងគ្រោះនោះមិនមែនជាតំបន់ស្វាមីភក្តិចំពោះខ្មែរក្រហមទេ តើវាមានការប្រែប្រួលចំពោះទស្សនៈរបស់អ្នកជំនាញដែរឬទេ បើសិនជាដូច្នោះ?

[១៥:២៧:១២]

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** ដំណើររស់នៅរបស់ជនជាប់ចោទ តាំងពីឆ្នាំ១៩៦០ រហូតដល់ថ្ងៃចាប់ខ្លួន គឺគាត់រស់នៅៗក្នុងតំបន់ខ្មែរក្រហម ។ ហើយដែលជាតំបន់ ថ្វីដ្បិតតែតំបន់ដែលត្រូវមានចិត្តភក្តីជាមួយនឹងខ្មែរក្រហមមែន តែជាតំបន់ដែលគ្រោះថ្នាក់ ងាយនឹងទទួលគ្រោះថ្នាក់ ។ ហើយគ្រោះថ្នាក់នោះ ក៏ជាគ្រោះថ្នាក់ធ្ងន់ធ្ងរ បើសិនជាធ្វើខុសអាចដល់អាយុជីវិត ហើយដែលយើងគ្រប់គ្នាក៏ធ្លាប់បានរស់នៅដែរ ជាពិសេសគឺខ្លួនខ្ញុំនេះ ។ ប៉ុន្តែ នៅពេលដែលគាត់បានមករស់នៅ ឯជិតទល់ដែនថៃការដូរឈ្មោះជាច្រើនលើកច្រើនសានេះ នេះជាកង្វល់ នេះសេចក្តីបារម្ភរបស់គាត់ ក្នុងការកុំឲ្យគេអាចរកឃើញថា គាត់ឈ្មោះពិតប្រាកដថា ឌុច ឬក៏ កាំង ហ្កេកអ៊ាវ ។ វាជាមធ្យោបាយមួយដែលគាត់អាច

លាក់កំបាំង រក្សាសុវត្ថិភាពរបស់គាត់ ហើយដែលកាលនោះយើងមិនទាន់បានចំហនូវនយោបាយរបស់រាជរដ្ឋាភិបាលអំពីការផ្សះផ្សាជាតិនៅឡើយទេ ។ ដល់ក្រោយមកទៀត ថ្វីដ្បិតតែមានអ្នករងគ្រោះខឹងសម្បា តែបន្ទាប់ពីយើងបានអនុវត្តនយោបាយ ឈ្នះ ឈ្នះ របស់រដ្ឋាភិបាល ឃើញថា មេដឹកនាំខ្មែរក្រហមមួយចំនួនបានមករស់នៅជាថ្នាក់ដឹកនាំនៃរដ្ឋអំណាចមូលដ្ឋាន នៅទឹកដីកម្ពុជាយើងមួយចំណែកដែរ ដូចជានៅទឹកដីប៉ៃលិន ដូចជានៅសំឡូត នៅម៉ាឡៃ ជាដើម ។ ដូច្នេះឃើញថា ក្រោមនយោបាយដែលថាផ្សះផ្សាជាតិ ជាការមួយធ្វើឲ្យប្រជាពលរដ្ឋថ្វីដ្បិតតែមានកំហឹង ក៏ប៉ុន្តែហាក់ដូចជាកំហឹងនោះត្រូវបានគ្រប់គ្រងបាន ហើយដែលអនុញ្ញាតឲ្យអតីតខ្មែរក្រហមនោះរស់នៅជាមួយបានបណ្តើរៗ ។

ដូច្នេះ យោងទៅលើបទពិសោធន៍និងការសង្កេតឃើញបែបនេះ និងមួយទៀតយោងទៅលើសមត្ថភាពរបស់ជនជាប់ចោទ ដែលកន្លងមកគាត់ធ្លាប់បានសម្របខ្លួនក្នុងគ្រាដែលលំបាកលំបិនបំផុតដែលប្រឈមនឹងគ្រោះថ្នាក់ដល់អាយុជីវិតត យ៉ាងណាក៏ដោយ គាត់អាចរស់នៅជាមួយបាន ។ ត្រង់នេះក៏ឆ្លុះបញ្ចាំងដែរថា ប្រតិកម្មពីអ្នករងគ្រោះមិនមានទ្រង់ទ្រាយធ្ងន់ធ្ងរ អាចប៉ះពាល់ដល់សុវត្ថិភាពគាត់ទេ ។

ការមានកំហឹងអាចនៅមាន ហើយខ្លួនគាត់ក៏អាចនឹងសម្របដើម្បីរស់នៅបាន ពីព្រោះថាកាលពីដំបូងគាត់រស់នៅក្រុមគ្រួសារ ឪពុកម្តាយ ក្រោយមកទៀត គាត់សុខចិត្តចាកចោលផ្ទះសម្បែងទៅនៅមិនដឹងផ្ទះ មិនដឹងសម្បែងនៅទីណា ។ ហើយក្រោយមកទៀត រស់នៅក្នុងបរិយាកាសមួយដែលមិនច្បាស់លាស់ បរិយាកាសមួយដែលគេសង្ស័យទៅវិញទៅមក ហើយបរិយាកាសដែលងាយនឹងទទួលគ្រោះដល់អាយុជីវិត គាត់អាចសម្របសម្រួលបាន ។ ដូច្នេះ ឃើញថាបរិយាកាសក្រោយពីបានធ្វើការផ្សះផ្សាជាតិ ក៏បានជាបរិយាកាសមួយដែលអាចធូរស្រាល ហើយដែលសាមីខ្លួនគាត់អាចសម្របបានស្រួលជាងបរិយាកាសមុនៗ ។ ដូច្នេះហើយបានជាយើងអាចបញ្ជាក់ថា គាត់អាចកែប្រែនិងសម្របសម្រួលរស់នៅក្នុងសង្គមជាមួយគេជាមួយឯងបាន ។ សូមអរគុណ ។

**លោក អានីស អះមេដ៖**

សូមអរគុណ ដែលលោក លោកស្រីចៅក្រម បានអនុគ្រោះឲ្យខ្ញុំសួរបន្តអម្បាញ់មិញ ។

ខ្ញុំពុំមានសំណួរទៀតទេ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវី អាឡាំង វ៉ែនណឺ ។

**លោក អាឡាំង វែនណឺ៖**

លោក លោកស្រីចៅក្រម ជាទីគោរព! ខ្ញុំសូមដាក់សំណើខ្លីមួយ ដោយលោក លោកស្រីចៅក្រម ជ្រាបហើយ អ្នកជំនាញអន្តរជាតិបានចាប់ផ្តើមព្រឹកមិញ ដោយធ្វើសេចក្តីថ្លែងគោរពទៅដល់ជនរងគ្រោះ ហើយគាត់ក៏បានលើកឡើងនៅក្នុងរសៀលនេះទៀតៗ ។ ហើយនៅពេលនេះ យើងមិនឃើញមានការចូលរួមពីដើមបណ្តឹង និងជនរងគ្រោះ ។ ដូច្នេះហើយខ្ញុំសូមឲ្យអង្គជំនុំជម្រះពន្យល់ទៅអ្នកជំនាញ ហេតុអ្វីបានជាគាត់មកផ្តល់សក្ខីកម្មដោយមិនមានដើមបណ្តឹងរដ្ឋប្បវេណី? ហេតុអ្វីបានជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណីពុំមានការតាំងសំណួរ? ហើយខ្ញុំចង់ស្នើឲ្យលោកប្រធានជម្រាបទៅដល់អ្នកជំនាញដើម្បីឲ្យមានការយល់ទៅលើបញ្ហានេះ ។ សូមអរគុណ ។

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:៣៤:១២]

**ប្រធានអង្គជំនុំ៖**

ខ្ញុំសូមជម្រាបដល់មេធាវី អាឡាំង វែនណឺ ថាអង្គជំនុំជម្រះពុំមានភារកិច្ចអ្វីពន្យល់ពីហេតុផលណាមួយដែលក្រៅពីបញ្ហាពាក់ព័ន្ធទៅនឹងការផ្តល់សក្ខីកម្មរបស់អ្នកជំនាញនោះទេ ។ ហើយបញ្ហាទីពីរលើអំពីហេតុផលដែលមានការពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះដែលបានប្រកាសនៅក្នុងសប្តាហ៍មុន ដែលមិនអនុញ្ញាតឲ្យភាគីមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការសួរដល់អ្នកជំនាញ ក៏ដូចជាដើមបណ្តឹង-- ដល់សាក្សីដែរ ឬក៏ជនជាប់ចោទ ដែលពាក់ព័ន្ធទៅនឹងសក្ខីកម្មបញ្ជាក់អំពីអត្តចរិតរបស់ជនជាប់ចោទនោះ គឺសេចក្តីសម្រេចបានបង្ហាញយ៉ាងច្បាស់លាស់នូវមូលហេតុដែលថានឹងចេញជូនភាគីក្នុងពេលឆាប់ៗនេះ ដោយសេចក្តីសម្រេចនោះត្រូវសម្រេចជាសមូហភាព ហើយមានទាំងមតិជំទាស់ ដូចអ្វីដែលអង្គជំនុំជម្រះបានជម្រាបជូន ហើយប្រហែលជាហេតុផលមួយទៀត គឺភាគីទាំងអស់មានទាំងលោក អាឡាំង វែនណឺ ផង បានយល់ច្បាស់លាស់ណាស់ អំពីបញ្ហានៅ អ.វ.ត.ក យើងនេះ ស្ថានភាពនៃការបកប្រែឯកសារជាបីភាសានោះ តើត្រូវចំណាយពេលវេលាប៉ុន្មានសមរម្យសម្រាប់បញ្ចេញនូវសំអាងហេតុនៃសេចក្តីសម្រេចនោះ ។ ដូច្នេះគឺយើងបានបញ្ជាក់សព្វគ្រប់នៅក្នុងដីកានោះហើយ ។

សូមអញ្ជើញ មានបញ្ហាអ្វីទេ? បើសិនមានថ្មី សឹមនិយាយ បើបញ្ហាដដែល មិនអនុញ្ញាតឲ្យនិយាយទេ ។

**លោកស្រី ត្រីស្ទីន ម៉ាទីណូ៖**

លោកប្រធានជាទីគោរព! ចំណុចនេះវាមិនថ្មីទេ ទោះបីជាខ្ញុំបានដឹងថា ដឹងអំពីតុលាការនេះក៏ដោយ ។ និយាយឲ្យសាមញ្ញទៅ បញ្ហាដែលបានលើកឡើងដោយសហសេវិករបស់ខ្ញុំ អាឡាំង វ៉ែនណឺ គឺជាបញ្ហាសំខាន់ដែលត្រូវលើកឡើង ដោយសារតែវាជាការចាំបាច់ត្រូវឲ្យអ្នកជំនាញគាត់បានដឹងហេតុបានជាដើមបណ្តឹងរដ្ឋប្បវេណី ពុំមានវត្តមាន? យើងរង់ចាំទៅហេតុផលទាំងអស់នេះ ។

ដើមបណ្តឹងរដ្ឋប្បវេណីពុំមានវត្តមាន ដោយសារតែសិទ្ធិរបស់ពួកគេត្រូវបានដកចេញ ហើយពួកគេចង់បង្ហាញអំពីភាពពុំពេញចិត្តទៅលើចំណុចនេះ ហើយគាត់ចង់បង្ហាញអំពីសារៈសំខាន់ដែលគាត់ចង់ចូលរួមនៅក្នុងដំណើរការក្តីនេះ ក្នុងគោលបំណងស្វែងយល់ និងតាំងសំណួរទៅជនជាប់ចោទ និងអ្នកជំនាញ ។ ដូច្នេះហើយយ៉ាងហោចណាស់ អ្នកជំនាញត្រូវតែដឹងថាមានអ្វីកើតឡើង ហេតុអ្វីបានជាមិនមានដើមបណ្តឹងរដ្ឋប្បវេណីនៅទីនេះ? ហើយខ្ញុំមានវត្តមាននៅទីនេះ ដោយសារតែខ្ញុំគោរពទៅអង្គជំនុំជម្រះសាលាដំបូង ។ ដូច្នេះយើងបញ្ជាក់បញ្ហានេះឲ្យបានច្បាស់ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានបញ្ជាក់នូវជំហររបស់ខ្លួន គឺប្រកាន់នូវជំហរដដែល ។

តទៅនេះ អង្គជំនុំជម្រះប្រគល់វេទិកាទៅមេធាវីការពារក្តី ដើម្បីមានឲ្យឱកាសក្នុងការតាំងសំណួរចំពោះអ្នកជំនាញ ទាក់ទិនជាមួយនឹងរបាយការណ៍ជំនាញរបស់អ្នកជំនាញទាំងពីររូបនេះ ។

**ការតាំងសំណួរដោយមេធាវីការពារក្តី**

**សួរដោយលោក ការ សាវុត្ថ៖**

សូមអរគុណ លោកប្រធាន និងសូមគោរព អង្គសវនាការ ។

សូមគោរព លោក លោកស្រី វេជ្ជបណ្ឌិតជាអ្នកជំនាញ ។

**ស៖** សូមលោកមេត្តាជួយបញ្ជាក់ ថាតើការសុំទោសរបស់ជនជាប់ចោទ ជាការសុំទោសផុសចេញមកពីដោយសុទ្ធចិត្ត ឬយ៉ាងណា? សូមលោកជួយបញ្ជាក់?

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្មៀលបូ)** តើខ្ញុំគួរតែពន្យល់យ៉ាងម៉េច? ការកោសល្យវិច័យចិត្តសាស្ត្រ គឺមិនមែនលាតត្រដាង និងបញ្ជាក់ទៅលើការពិត ឬក៏ការបែងចែកទៅលើអ្វីដែលការពិត និងអ្វីមិនការពិតនោះទេ ។ វាមិនមែនជាតួនាទីរបស់ខ្ញុំនោះទេ យើងគ្រាន់តែចង់បានបង្ហាញអំពីចិត្តសាស្ត្ររបស់ជនជាប់ចោទតែប៉ុណ្ណោះ ។ អ្វីដែលយើងអាចពន្យល់បានអំពីវិប្បដិសារីនិងការសោកស្តាយ ឬក៏អារម្មណ៍ពិរុទ្ធ-

ភាពរបស់គាត់នោះ ។ នៅពេលដែលយើងពិនិត្យពិច័យទៅលើគំរូ គិតពិចារណាតាមលក្ខណៈតក្កវិទ្យា ហើយប្រសិនបើយើងពិនិត្យទៅលើការវិវត្ត នៅក្នុងការទទួលស្គាល់ និងយល់ដឹងរបស់ជនជាប់ចោទ យើងអាចយល់ឃើញថា យើងឃើញមានការផ្លាស់ប្តូរនិងការវិវឌ្ឍន៍ នូវអ្វីដែលគាត់បាននិយាយជូនយើងខ្ញុំនៅពីដំបូង ។ ដូច្នេះហើយ ការនិយាយអំពីពិរុទ្ធគឺវាមានលក្ខណៈពិបាក ហើយយើងស្ថិតនៅក្នុងបរិបទវប្បធម៌ខុសគ្នានៃការជំនុំជម្រះ ។ ហើយយើងមិនយល់ ថាតើការសម្តែងចេញនូវអារម្មណ៍ពិរុទ្ធភាពនៅក្នុងវប្បធម៌មួយ វាខុសគ្នាទៅនឹងវប្បធម៌មួយយ៉ាងម៉េច?

[១៥:៤០:៥៥]

ដោយសារតែនៅក្នុងលោកលិចយើងយល់ឃើញថា ការសម្តែងពិរុទ្ធភាពនោះ គឺជាការលើកឡើងបញ្ហាក់មួយផ្សេង ហើយវាអាចទាក់ទងទៅនឹងបញ្ហាផ្លូវចិត្ត ហើយវាអាចកើតចេញពីការធ្លាក់បាក់ផ្លូវចិត្ត ឬវាអាចដំណើរការវាកើតឡើងនៅក្នុងស្មារតី ទាក់ទងទៅនឹងបញ្ហាអារម្មណ៍ពិរុទ្ធភាពនេះ ។ ហើយយើងមិនអាចស្វែងយល់នៅក្នុងជនជាប់ចោទបានទេ ។ ប៉ុន្តែ សហសេវិករបស់ខ្ញុំអាចជួយពន្យល់ពិរុទ្ធភាពនេះបាន ។ វាជាទស្សនទានរួមនៅលើពិភពលោកឬក៏យ៉ាងម៉េច? ឬក៏វាអាស្រ័យទៅតាមបរិបទវប្បធម៌នីមួយៗ ។ យើងបានបង្ហាញទៅលើចម្លើយនេះ ។ សេចក្តីសន្និដ្ឋានរបស់ខ្ញុំ គឺយើងមិនអាចចម្លើយតប ទាក់ទងទៅនឹងអង្គហេតុការពិតនោះទេ យើងអាចនិយាយអំពីតែការវិវត្តរបស់ជនជាប់ចោទចំពោះការស្វែងយល់ដឹងរបស់គាត់ អំពីអ្វីដែលគាត់បានធ្វើនិងអំពើរបស់គាត់ ។ ហើយនិងអ្វីដែលគាត់អាចគិតពិចារណា និងការទទួលខុសត្រូវរបស់គាត់តែប៉ុណ្ណោះ ។ សូមអរគុណ ។

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** អ្វីដែលយើងត្រូវបានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះសំណូមពរឲ្យធ្វើ មិនផ្តោតទៅលើរកឲ្យឃើញនូវភាពពិតប្រាកដនៃការសុំទោសរបស់ជនជាប់ចោទនោះទេ ។ ហើយម្យ៉ាងទៀត នីតិវិធីដែលយើងបានស្រាវជ្រាវនិងបានសួរនាំក៏យើងមិនបានប្រើប្រាស់សម្រាប់សំដៅទៅលើសារធាតុរបស់ការសុំទោសបែបនេះដែរ ។ តែខ្ញុំអាចជម្រាបថា នៅលើកដំបូងដែលខ្ញុំបានជួបនិងលោក ឌុច យើងខ្ញុំអត់បានសួរនាំអីទាំងអស់ ។ គាត់បាននិយាយថា គាត់នឹងសុំទោស ។ ដូច្នេះឃើញថា ការសុំទោសនេះចង់ឆ្លុះបញ្ចាំងថា ជាការមួយសំដៅដោយសុទ្ធចិត្ត ឬក៏មិនដោយសុទ្ធចិត្ត ខាងខ្ញុំមិនអាចជម្រាបជូន ឬក៏មិនអាចបកស្រាយបានទេ គ្រាន់តែបានឃើញនូវព្រឹត្តិការណ៍ដែលបានជម្រាបជូនតែប៉ុណ្ណោះ ។ សូមអរគុណ ។

**សៈ** សូមអរគុណ លោក លោកស្រី វេជ្ជបណ្ឌិត ។

ខ្ញុំសូមសួរតទៅទៀត នៅក្នុងរបាយការណ៍របស់លោក លោកស្រី បានបញ្ជាក់ថាជនជាប់ចោទជាមនុស្សងាយទទួលឥទ្ធិពលពីអ្នកដទៃ ឬងាយរំភើប ។ អ៊ីចឹង ខ្ញុំបាទសួរថាតើជនជាប់ចោទទទួលឥទ្ធិពលរបបកុម្មុយនីស្តហ្នឹង ចាប់តាំងពីខ្លួននៅក្មេងមក តើអ៊ីចឹងមែនឬទេ?

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** ខ្ញុំសូមជម្រាបថា ការទទួលឥទ្ធិពលពីអ្នកដទៃអាចផ្ទុះបញ្ចាំងថាមានពិតតែកម្រិតអាចខុសៗគ្នាទៅតាមកាលៈទេសៈ។ ដូចជាគាត់ទទួលឥទ្ធិពលពីព្រះសង្ឃ គាត់ទទួលឥទ្ធិពលពីគ្រូ ហើយគាត់ទទួលឥទ្ធិពលអំពីទុក្ខសោករបស់ប្រជាពលរដ្ឋ ។ នេះជាការមួយពិត ដែលគាត់ទទួលឥទ្ធិពល ប៉ុន្តែទាក់ទងទៅនឹងរបបកុម្មុយនីស្ត ការទទួលឥទ្ធិពលនេះ យោងទៅតាមអ្វីដែលយើងបានសួរ ហើយអ្វីដែលលោកសាមីខ្លួន គាត់បានរៀបរាប់ដំណើរបន្តិចម្តងៗ ដែលបានជ្រើសរើសយករបបកុម្មុយនីស្តនេះ គឺដោយសារតែបរិយាកាសជុំវិញនៅកាលៈទេសៈនោះ ខាងក្នុងហ្នឹងជុំវុញផង ពីខាងក្រៅអូសទាញផង ។ បរិយាកាសខាងក្នុងជុំវុញដោយសារតែ បន្ទាប់ពីគាត់បានធ្វើការគាត់ឃើញមានការកេងប្រវ័ញ្ចទៅលើអ្នកក្រីក្រ ដូចជាពេលដែលចងការ យកការប្រាក់ថ្លៃនោះមួយ ។ ទីពីរ គាត់ធ្វើការលំបាកវេទនារបស់គាត់ ជាពិសេសគ្រាន់តែគាត់ក្រ គាត់បាត់កង់គាត់មិនអាចបន្តការរៀនសូត្រទៅទៀតបានរហូតទៅដល់គាត់ប៉ានបរិច្ចាគប្រាក់ខែគាត់មួយចំនួនដើម្បីជួយជនក្រីក្រតាមរយៈចលនាកុម្មុយនីស្តដោយឡែកទៀត ដោយសារតែក្នុងកាលៈទេសៈនោះ ឥទ្ធិពលពីក្រៅបង្ហាញឲ្យឃើញថា លិទ្ធិម៉ៅ ហើយជាលិទ្ធិកុម្មុយនីស្តនោះ បានឈ្នះ ហើយធ្វើឲ្យប្រជាពលរដ្ឋក្រីក្រនោះ មានការធូរធារក្នុងជីវិត ។ អ៊ីចឹងបានជាឆន្ទៈ ឬក៏គោលបំណងរបស់គាត់ដែលប៉ងធ្វើយ៉ាងណាឲ្យអ្នកក្រីក្រអាចប្តូរជីវភាពរស់នៅបានល្អទៅជាយល់ឃើញថា មានតែរបបកុម្មុយនីស្តនេះទេ ដែលអាចជាមធ្យោបាយឲ្យគាត់សម្រេចបំណង ។ អ៊ីចឹងហើយបានជាក្នុងពេលនោះ គាត់បានសម្រេចយកមាគ៌ាដែលត្រូវដើរ គឺមនោគមវិជ្ជាកុម្មុយនីស្តរបស់ម៉ៅ ។ ត្រង់នេះអាចបញ្ជាក់ថា គាត់អាចទទួលឥទ្ធិពលពីអ្នកដទៃបាន ។

ដោយឡែកទៀត ក្នុងដំណើរការរស់នៅក្នុងជីវិតរបស់គាត់ក្នុងរបបខ្មែរក្រហម ថ្វីដ្បិតតែគាត់មិនចង់ តែត្រូវបានគេសម្រេចប្រគល់តួនាទីគាត់ជាប្រធានមន្ទីរឃុំឃាំងម-១៣ គាត់ត្រូវតែទទួលការងារនេះ ហើយយកមកអនុវត្តឲ្យបានត្រឹមត្រូវ មិនមែនធ្វើប្រជួសប្រសោកឲ្យតែរួចពីដៃ រហូតទៅដល់គាត់បានទទួលតួនាទីជាប្រធានស-២១ ទាំងមិនពេញចិត្ត ក៏គាត់ទទួលឥទ្ធិពលពីគ្រូ ហើយខំប្រឹងធ្វើការងារនេះឲ្យបានល្អទៅតាមភារកិច្ច ។ អ៊ីចឹងឃើញថា ជាដំណាក់មួយដែរ ដែលមានការផ្លាស់ប្តូរ ហើយដែលគាត់ទទួលឥទ្ធិពលពីអ្នកដឹកនាំយកមកធ្វើ ឲ្យសមរម្យទៅតាមភារកិច្ច និងកាលៈទេសៈនោះ ។

លុះមកដល់ក្រោយមកទៀត គាត់បានមករស់នៅជាមួយគ្នាជាមួយឯង ហើយបានធ្វើជាគ្រូបង្រៀននៅសាលាមួយ បឋមសិក្សា ហើយគាត់បានបង្រៀនជាភាសាបារាំង ។ ត្រង់នេះឃើញថា បើសិនជាគាត់មិនអាចទទួលឥទ្ធិពលពីសង្គម ឬក៏សហគមន៍ដែលគាត់បានរស់នៅនោះទេ ប្រាកដជាគាត់មិនជាទ្រាំទ្ររស់នៅធ្វើជាគ្រូបានទៀតទេ ។ ហើយជាពិសេសទៅទៀត គឺត្រង់ថា គាត់ទទួលឥទ្ធិពលពីអ្នកដទៃ ហើយគាត់សមស្របសម្រួលទៅតាមកាលៈទេសៈបាន ទោះជាកាលៈទេសៈនោះលំបាកលំបិន ឬក៏ធូរស្រាលក៏ដោយ ។ ទាំងអស់នេះហើយ គឺជាភាពជាក់ស្ដែងដែលបង្ហាញថា គាត់អាចទទួលឥទ្ធិពលពីអ្នកដទៃបាន ។

[១៥:៥០:០៨]

**ស៖** សូមអរគុណលោកវេជ្ជបណ្ឌិត ។ មួយទៀត យើងខ្ញុំឃើញថា ជនជាប់ចោទមានភាពទន់ខ្សោយនិងភាពក្រីក្រដែលញាំញីជីវិតគ្រួសារគាត់តាំងពីគាត់កើតមក ។ សួរថាតើជនជាប់ចោទអាចមានជំងឺផ្លូវចិត្តដោយសារបញ្ហានេះដែរឬទេ?

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** នេះគឺជាសំណួរមួយដែលល្អ-- ចប់ហើយនៅបាទ?

**ស៖** បាទ ចប់ហើយ សំណួរតែប៉ុណ្ណឹង ។

**ឆ៖ (វេជ្ជ. កាស៊ុនបូណាត)** នេះជាសំណួរដែលល្អ ។ កាលពីនៅកុមារ ជនជាប់ចោទ គាត់ស្ថិតក្នុងគ្រួសារមួយ ដែលមានជីវភាពក្រីក្រ នៅជនបទ ហើយថែមទាំងមានបន្ទុកច្រើនទៅទៀត ដោយសារតែឪពុកត្រូវជាប់ជំពាក់បំណុលគេ ហើយដែលពិបាកនឹងដោះ ។ ការលំបាកទាំងនេះ មិនបានធ្វើឲ្យជំហរ ឬក៏ទុកចិត្តទាំងអស់របស់គាត់ទន់ខ្សោយទេ ផ្ទុយទៅវិញធ្វើឲ្យគាត់ស្វែងយល់នូវមូលហេតុនៃទុក្ខលំបាក ធ្វើឲ្យគាត់ខំប្រឹងរៀនសូត្ររហូតដល់គាត់បានរៀនសូត្រ ក្នុងចំណោមសិស្សពូកែក្នុងថ្នាក់ ។ បើប្រៀបធៀបទៅនឹងការលំបាកវេទនា គួរតែគាត់ពិបាកនឹងធ្វើការសិក្សារហូតទៅដល់គាត់បានមករៀននៅភ្នំពេញធ្វើជាសាស្ត្រាចារ្យណាស់ ព្រោះកាលនោះ ការរៀនសូត្រត្រូវចំណាយលុយច្រើន មិនងាយនឹងអាច--អ្នកណាម្នាក់រៀនបានដូចគាត់ទេ ។ លើសពីនេះទៀត បើសិនជាគាត់មានបញ្ហាអំពីផ្លូវចិត្ត ជាពិសេសដោយសារភាពទល់ក្រ ហើយនិងការលំបាកទាំងប៉ុន្មាននេះ ភាគច្រើនបើមានជំងឺផ្លូវចិត្ត គឺជាជំងឺធ្លាក់ទឹកចិត្ត ដែលជាភាសាបារាំងហៅថា *ដេប្រេសស្យុង* ។ ក្នុងជំងឺ *ដេប្រេសស្យុង* នេះ អាការៈនៃជំងឺនេះមានកត្តាមួយគឺធ្វើឲ្យមានទឹកចិត្តមិនចង់ធ្វើអ្វីទាំងអស់ បាត់បង់នូវកម្លាំងចិត្ត ទីពីរភ្លេចភ្លាំង ទីបី លែងចងចាំអ្វីទាំងអស់ ។

បើសិនជាកាលនោះគាត់មានជំងឺហ្នឹងមែន គាត់គ្មានសមត្ថភាពនឹងរៀនបានចប់ចុងចប់ដើម ហើយក្លាយទៅជាសាស្ត្រាចារ្យផ្នែកខាងគណិតវិទ្យាទេ ។

[១៥:៥៣:០០]

លើសអំពីនេះទៀត កាលដែលគាត់បានជ្រើសរើសមុខវិជ្ជាគណិតវិទ្យា ជាការមួយផ្ទុះបញ្ជាំងថា គាត់ជាមនុស្សស្រឡាញ់តក្កវិទ្យាដែលផ្ទុះបញ្ជាំងថា ការលំបាកទាំងប៉ុន្មានដែលគាត់បានជួបប្រទះធ្វើឲ្យគាត់ខំប្រឹងប្រែងស្វែងយល់ការពិត មូលហេតុ ធ្វើឲ្យឆន្ទៈគាត់ ធ្វើឲ្យទឹកចិត្តគាត់ ធ្វើឲ្យជំហរគាត់កាន់តែរឹងមាំ ដែលជាភាសាបារាំងហៅថា *រេហ្ស៊ីលីយ៉ង់* ដែលវាបញ្ច្រាសទៅនឹងការបង្កើតនូវជំងឺផ្លូវចិត្ត ។ ដូច្នេះហើយបានជាផ្អែកទៅលើជម្រើសយកវិជ្ជាជីវៈជាសាស្ត្រាចារ្យខាងគណិតវិទ្យានេះ គឺជាការមួយផ្ទុះបញ្ជាំងផងដែរថា បញ្ញាស្មារតីគាត់នៅច្បាស់លាស់ល្អ ។ អ៊ីចឹងឆ្លងកាត់ការលំបាក មិនសុទ្ធតែបង្កើតនូវជំងឺផ្លូវចិត្តទេ ។ ឆ្លងកាត់ការលំបាក បានធ្វើឲ្យបញ្ញាស្មារតីនិងគំនិតកាន់តែល្អ ជំហរកាន់តែរឹងប៉ឹងដែលហៅថា *រេហ្ស៊ីលីយ៉ង់* ។ សូមអរគុណ ។

**ស៖** សូមអរគុណលោកសាស្ត្រាចារ្យ ខ្ញុំសូមសួរបន្តទៀត ។ នៅស-២១ ជនជាប់ចោទដឹងថា ចម្លើយសារភាពទាំងអស់មិនមែនជាការពិតទេ ។ ជនជាប់ចោទនៅតែទទួលយកចម្លើយមិនពិតនេះចារបញ្ជូនទៅថ្នាក់លើ តើការងារនេះប៉ះពាល់ដល់ផ្លូវចិត្តរបស់ជនជាប់ចោទឬទេ? សូមលោកសាស្ត្រាចារ្យមេត្តាបញ្ជាក់ ។

**ឆ៖ (វេជ្ជ.កា ស៊ុនបូណាត)** ចំពោះមនុស្សធម្មតា ការធ្វើបែបនេះជាការមួយធ្វើឲ្យមានការសោកស្តាយខ្លាំង ហើយអាចនឹងប៉ះពាល់ដល់ផ្លូវចិត្តធ្ងន់ធ្ងរ ប៉ុន្តែដោយសារពីរនេះ ក្នុងវ័យកុមារ ក្នុងវ័យជំទង់ ជំហរនេះបានរឹងមាំមួយចំណែកហើយ ។ ពិសេសទៀត ដែលក្នុងរបាយការណ៍ យើងបាននិយាយថា ជំហរនេះដែលមានចាប់ពីវ័យជំទង់រហូតដល់ពេញវ័យ ហើយត្រូវបានពង្រឹងបន្ថែមទៀត ដោយសារមនោគមវិជ្ជាកុម្មុយនីស្ត បានធ្វើឲ្យសាមីខ្លួនគាត់អាចប្រឈមនឹងការលំបាកបែបនេះបាន ។ ថ្វីដ្បិតតែយើងមិនបានដឹងថា មានការសោកស្តាយ ឬក៏អត់? ប៉ុន្តែយើងអាចដឹងថា គាត់អាចមានសមត្ថភាពប្រឈមនឹងសភាពការណ៍បែបនេះបាន ។ សូមអរគុណ ។

[១៥:៥៦:៥៩]

**ស៖** សូមអរគុណលោកសាស្ត្រាចារ្យ ។ បាទៗ សូមអញ្ជើញ ។

**ឆ៖ (វេជ្ជ. ស៊ីរ៉ូនី ហ្គៀលបូ)** សូមអរគុណ ។

ខ្ញុំសូមធ្វើការបន្ថែមចំណុចមួយចំនួន ជាពិសេសចំណុចចុងក្រោយ ដែលសហសេវិករបស់ខ្ញុំបានលើកឡើង យើងបាននិយាយច្រើនហើយអំពីការសម្ដែងនូវការសោកស្ដាយ អំពីពិរុទ្ធភាព ហើយយើងដោយសារតែយើងមិនយល់ច្បាស់អំពីការសោកស្ដាយនោះ វាទាក់ទងទៅនឹងបញ្ហាអារម្មណ៍ ហើយនិងការបន្ទូល់អារម្មណ៍ៗនៃភាពគ្មានទោសទេ គឺអារម្មណ៍ដែលធ្លាប់ឆ្លងកាត់ទៅលើស្ថានភាពទាំងអស់នោះ។

ជាការពិតយើងអាចមានការយល់ឃើញខុសគ្នា ពាក់ព័ន្ធទៅនឹងបញ្ហាហ្នឹង ទាក់ទងទៅនឹងកុមារភាពរបស់ជនជាប់ចោទ ខ្ញុំសូមបន្ថែមថា ខ្ញុំយល់ស្របជាមួយនឹងសហសេវិករបស់ខ្ញុំ ហើយខ្ញុំសូមបញ្ជាក់អំពីផលប៉ះពាល់ទាក់ទងទៅនឹងការបន្ទុះបង្អាប់ គឺអារម្មណ៍ចាញ់ច្រាប អារម្មណ៍ស្ថិតនៅក្រោមគេ ដែលអារម្មណ៍ទាំងអស់នេះហើយ វារុញច្រាន ឌុច ឲ្យជំរុញខ្លួនឯងឆ្លងកាត់ ហើយនិងរុញច្រានចេញពីស្ថានភាពបែបនេះ ហើយទាក់ទងទៅនឹងចម្លើយសារភាព ដោយគាត់ដឹងថា ចម្លើយទាំងអស់នោះមិនពិតនោះ យើងត្រូវពិចារណាថា ឌុច ប្រហែលជាធ្វើឡើងដើម្បីបង្គាប់មេរបស់គាត់ ហើយជាពិសេសនៅពេលដែល សុន សេន ជាមេកើយរបស់គាត់ ។ ដូច្នេះបញ្ហានេះ អាចពន្យល់តាមរយៈការសរសេរចម្លើយសារភាពតាមអ្វីដែលគេចង់បាន ហើយវាជាការបញ្ជាក់ទៅលើជំនឿទាំងអស់ហ្នឹង ហើយយើងឃើញថា មានការស្រមើលស្រមៃកើតឡើងនៅពេលហ្នឹង ហើយការធ្វើដូច្នោះ គឺដើម្បីឲ្យគាត់រក្សានូវតួនាទីរបស់គាត់ ហើយគាត់អាចបំពេញទៅតាមការងារនៅក្នុងប្រព័ន្ធនោះបាន ។

**ស៖** សូមអរគុណលោកស្រីវេជ្ជបណ្ឌិត ។ ខ្ញុំសូមសួរមួយសំណួរទៀតថា ជនជាប់ចោទបានប្រកាសជាញឹកញាប់ថា ឧក្រិដ្ឋកម្មនៅស-២១ គាត់ទទួលទាំងអស់ ដោយមិនឲ្យកូនចៅគាត់ ជាបុគ្គលិកស-២១ទាំងអស់ មកជាប់ពាក់ព័ន្ធជាមួយគាត់ទេ ព្រោះបុគ្គលិកទាំងនោះ បានទទួលបញ្ជាពីគាត់ ។

ហេតុអី? ខ្ញុំសួរថា តើហេតុអីបានជាជនជាប់ចោទ មានអត្តចរិតផ្លូវចិត្តបែបនេះ?

[១៦:០០:៣០]

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** យោងទៅតាមវិភាគដំណើរការតាក់តែងផ្លូវចិត្ត ផ្នត់គំនិតរបស់គាត់តាំងពីតូចឃើញថា គាត់ហាក់ដូចជាមានការឈឺឆ្អាលចំពោះអ្នកដទៃ ដែលមានការលំបាកវេទនា ដែលការឈឺឆ្អាលនេះ ជាភាសាបារាំងហៅថា *អាល់ទ្រីស៍* អង់គ្លេសហៅថា *អាល់ទ្រីស៍ហ្សឹម* ។ ហើយដោយសារតែការឈឺឆ្អាលអ្នកដទៃនេះហើយដែលជាការមួយជំរុញឲ្យគាត់មានការអាណិតអាសូរ គិតគូទៅដល់ប្រជាពលរដ្ឋជាច្រើនដែលរងទុក្ខវេទនា រហូតទៅដល់គាត់ប៉ានប្រឈមទៅនឹងការតតាំងជាមួយនឹងរដ្ឋាភិបាលដើម្បីរកខុសត្រូវ ហើយនិងរកសេចក្តីសុខឲ្យប្រជាពលរដ្ឋទៅតាមអ្វីដែលគាត់បានរំពឹង

គិត រហូតទៅដល់ប៉ានចាកចោលក្រុមគ្រួសារចូលក្នុងចលនាកុម្មុយនីស្តខ្មែរ ដោយសង្ឃឹមថាចលនានេះជា មធ្យោបាយ ជាមាគ៌ា ដែលអាចរកសេចក្តីសុខជូនប្រទេសជាតិ ។ ត្រង់នេះក៏បញ្ជាំងផ្ទុះបញ្ជាំងថាគំនិតអាណិតអាសូរអ្នកដទៃនេះមានកម្រិតធំទៅៗ ។

ដោយឡែក ការទទួលខុសត្រូវនៅស-២១ អ្នកដែលធ្វើជាមេ អ្នកដែលបញ្ជា គឺលោក ឌុច ផ្ទាល់តែម្តង ហើយសកម្មភាពអ្វីៗទាំងអស់ ទាំងការដាក់បញ្ជា ទាំងការបង្រៀនឲ្យចេះអំពីវិធីសួរចម្លើយក៏គាត់ជាអ្នករៀបចំ ហើយគាត់រៀបចំនេះក្នុងគំនិតមួយថាគាត់ជាគ្រូ ។ ក្នុងនាមគាត់ដែលជាអ្នកទទួលខុសត្រូវគាត់យល់ឃើញថាទាំងនេះមុនបង្អស់គឺគាត់ជាអ្នកទទួលខុសត្រូវ ព្រោះអីសកម្មភាពនៅក្នុងស-២១ រៀបចំនិងដំណើរការក្រោមបញ្ជារបស់គាត់ ក្រោមការចាត់ចែងរបស់គាត់ ។ អ្នកប៉ុន្មានដែលអនុវត្តតាមគាត់ គឺត្រូវស្តាប់បញ្ជាគាត់ ។

ដូច្នេះឃើញថា មួយដោយសារគំនិតគាត់ជាអ្នកការពារ ឈើឆ្កាលហើយ ការពារអ្នកដទៃ មិនចង់ឲ្យគេលំបាកជាមួយ។ ទីពីរក្នុងនាមគាត់ជាអ្នកទទួលខុសត្រូវដែលជាប្រធាននៃអង្គភាពនោះ ។ កត្តាពីរនេះហើយដែលជំរុញឲ្យគាត់សុំទទួលខុសត្រូវតែម្នាក់ឯងទៅលើអ្វីដែលបានធ្វើនៅស-២១ នេះ ។ សូមអរគុណ ។

**ស៖** សូមអរគុណ លោក វេជ្ជបណ្ឌិត ។ ភ្ជាប់នឹងបញ្ហានេះ ខ្ញុំហាក់ដូចជាមានសំណួរមួយទៀតចង់សុំឲ្យលោកវេជ្ជបណ្ឌិតបញ្ជាក់ ព្រោះថាសំណួរនេះវាទៅឲ្យនាំរបាយការណ៍ របស់លោកវេជ្ជបណ្ឌិតបានសន្និដ្ឋានថា ឌុច (ទំព័រ៥៥) ឌុច ជាមនុស្សម្នាក់ដែលគ្មានសម្បជញ្ញៈយល់ដល់ទឹកចិត្តអ្នកដទៃតាំងពីដើមរហូតមកដល់បច្ចុប្បន្ននេះ ។ ប៉ុន្តែ កូនសិស្សរបស់ ឌុច នៅទំព័រ៣៣ ពិពណ៌នាថា ឌុច ជាមនុស្សស្មោះត្រង់ មានការប្តេជ្ញាចិត្ត មានភក្តីភាព ហើយតែងតែជួយអ្នកដែលក្រីក្រជាងគេ ។ អ៊ីចឹងខ្ញុំមើលទៅឃើញហាក់ដូចជាលោកវេជ្ជបណ្ឌិតបានពន្យល់អម្បាញ់មិញ គឺវាស្របទៅនឹងកូនសិស្សរបស់ ឌុច តែវាហាក់ដូចជាមិនស្របទៅនឹងសេចក្តីសន្និដ្ឋានដែលថា ឌុច ជាមនុស្សម្នាក់ដែលគ្មានសម្បជញ្ញៈយល់ដឹងយល់ដល់ទឹកចិត្តអ្នកដទៃតាំងពីដើមរហូតមកដល់ពេលបច្ចុប្បន្ននេះ ។ អ៊ីចឹង ខ្ញុំមិនសូវច្បាស់កន្លែងនេះ សូមលោកវេជ្ជបណ្ឌិតមេត្តាជួយបញ្ជាក់បន្ថែម ។ សូមអរគុណ ។

[១៦:០៥:៣២]

**ឆ៖ (វេជ្ជ.ស៊ីរ៉ូនី ហ្គៀលបូ)** អ៊ីចឹងយើងនិយាយអំពីចំណុចមួយដែលលើកឡើងដោយសហសេវិករបស់ខ្ញុំ គឺនិយាយអំពីការឈើឆ្កាលដែលយើងស្គាល់គាត់នៅពេលនេះ គឺជាបញ្ហាការឈើឆ្កាលនេះ ទៅ

តាមលក្ខខណ្ឌមួយ គឺវាជាការឈឺឆ្កួលដែលមានទៅតាមលក្ខខណ្ឌ គឺមើលទស្សនៈវិស័យទៅតាមពិភពលោក ឬក៏សម្រួបទៅតាមពិភពមួយ គឺមិនមែនជាការឈឺឆ្កួលដែលយើងអាចយល់បានជាភាសាបារាំងដែលយើងនិយាយឧទាហរណ៍ គឺមានតម្រង់ទិសដៅពីការឈឺឆ្កួលនេះ អំពីការបង្កើតនូវសង្គមថ្មីមួយ ។ អ្វីដែលលោកលើកឡើងអំមិញនេះ ខ្ញុំមិនមើលឃើញថាវាមានភាពផ្ទុយគ្នាទៅអ្វីដែលយើងបានសរសេរនៅក្នុងរបាយការណ៍នេះទេ ។

បញ្ហាអំពីការអាណិតអាសូរ គឺអាចពន្យល់នៅក្នុងពេលចំណុចក្រោយមួយនៅក្នុងបរិបទជាក់លាក់ដែលគាត់បានទទួលមុខងារជាប្រធានម-១៣ ហើយនិងស-២១ មិនមែនជាចំណុចមួយវាក្លាយទៅជាមានអារម្មណ៍មានក្តីអាណិតអាសូរ ថាជាកត្តាតម្រង់ឲ្យគាត់ដើរតួនាទីនោះទេ។ នៅក្នុងដំណាក់កាលចំណុចណាមួយនៅក្នុងខ្សែជីវិតនោះគឺថា អ្វីដែលអាចរៀបរាប់ទៅតាមលក្ខខណ្ឌអត្តចរិកក្នុងចំណុចពេលមួយ ហើយគឺគេអាចបង្ហាញគំនិតមួយដែលថាគេអាចនឹងបូជាការងារក្នុងមួយជីវិតរបស់គេសម្រាប់គោលដៅនោះ ។

អ៊ីចឹងគឺថា ពេលខ្លះគេទទួលការងារមួយដែលត្រូវគេប្រគល់ឲ្យធ្វើ ដូចជាទៅចាប់អ្នកដទៃថាជាខ្មាំងនៅខណៈពេលនោះហើយ គឺថាមនុស្សម្នាក់នោះ គឺខ្លាចស្ថិតនៅក្នុងស្ថានភាពមួយ គឺបន្ទោសបង្អាប់មនុស្សជាតិក្នុងលក្ខខណ្ឌហ្នឹង ។

**ស៖** សូមអរគុណ ខ្ញុំសូមសួរសំណួរចុងក្រោយមួយទៀត ។ ជីដូនជីតាទាំងសងខាងរបស់ ឌុច សុទ្ធតែមានដើមកំណើតពីចិន តើឈាមជីដូនជីតាជាចិន តើអារម្មណ៍របស់ជីដូនជីតាជាចិនអាចឆ្លងមកឌុច ឲ្យឌុច ស្រឡាញ់ចូលចិត្ត ហើយជឿនឹងចង់បានរបបកុម្មុយនីស្តដូចចិនដែរឬទេ?

[១៦:០៨:៥១]

**ឆ៖ (វេជ្ជ. កា ស៊ុនបូណាត)** ខ្ញុំសូមជម្រាបថា ក្នុងដំណើរតំណពូជ អ្វីដែលជាកត្តាចម្លងឪពុកម្តាយ ជីដូនជីតា គឺក្រូម៉ូហ្សូម ជាទូទៅការចម្លងអាចកើតមានចំពោះតែអ្វីដែលជារូបភាព អ្វីដែលជា គេហៅថា *ហ្វីហ្សុីក* ដូចជាភ្នែក អាចដូចគ្នា រាងរៅដូចគ្នា ប៉ុន្តែទឹកចិត្តមិនពិតជាអាចចម្លងបានទេ ។ ព្រោះថាមានការសិក្សា អំពីកូនភ្លោះដែលប្រសូតចេញពីស៊ុតតែមួយ បានសេចក្តីថាដូចគ្នាទាំងអស់ មិនមានអ្វីខុសទេ ក្រូម៉ូហ្សូម ក៏ដូចគ្នាដែរ ។ មួយត្រូវបានអប់រំនៅកន្លែងផ្សេង មួយទៀតត្រូវបានអប់រំនៅកន្លែងផ្សេង អ្នកទាំងពីរនេះមានចរិត មានទឹកចិត្តខុសគ្នា ។

ដូច្នេះ ឧទាហរណ៍នេះអាចបញ្ជាក់ថា ថ្វីដ្បិតតែជីដូនជីតាគាត់មានឈាមជ័រជាចិន អាប្បកិរិយា

ប្រពៃណីជាចិន តែមិនមានអ្វីមួយដែលចម្លងតាមបែបនេះទៅលោក ឌុច ដើម្បីឲ្យប្រកាន់យកឥរិយាបថនេះឡើយ ប៉ុន្តែយើងរស់ទីណាយើងតែប្រកាន់យកអត្តសញ្ញាណមួយ។ លើកឧទាហរណ៍ថា ខ្មែរយើងដែលរស់នៅក្នុងប្រទេសបារាំង នៅប្រទេសអាមេរិក នៅអូស្ត្រាលី តែងតែស្វែងរកខ្មែរគ្នាឯង ហើយយកញាតិសន្តានជាដើម ហើយប្រកាន់យកនូវគំនិត ឬក៏ផ្លាស់ប្តូរយោបល់នៅពេលដែលគេមានបញ្ហាអីនានា ។

អ៊ីចឹងឃើញថា និន្នាការនេះគឺមិនមានការដែលកំណត់ឲ្យកើតបាននូវអត្តសញ្ញាណនេះ វាទាក់ទងទៅនឹងសញ្ជាតិនេះឯង ប៉ុន្តែក្នុងករណីនេះខ្ញុំជឿថាលោក ឌុច គាត់មានអត្តសញ្ញាណចេញពីជីដូនជីតាដែលមានឈាមជ័រជាចិន ហើយមានគំនិតខ្លះៗជាចិន ដោយសារថា ពីជីដូនជីតាគាត់មកៗដល់ឪពុកម្តាយតែងប្រកាន់យកនូវប្រពៃណី ចរិតខ្លះដែលជាឥរិយាបថរបស់ប្រជាជនចិន ប៉ុន្តែមិនមែនទទួលបានទាំងស្រុង ទាំងមូលពីជីដូនជីតាទេ ។

ដោយឡែក ដោយសារនាសម័យនោះ សូម្បីខ្លួនខ្ញុំក៏អាច ដែលកើតក្រោយមកក៏អាចបានដឹងដែរ ជនជាតិចិន ឬក៏ជនជាតិបរទេសដែលជាវៀតណាមដែលរស់នៅទឹកដីខ្មែរយើងមកនៅតាមជនបទ គឺត្រូវបានយើង ចួនកាលមើលងាយមើលថោកអ៊ីចឹងមែន ឬក៏បង្អាប់បន្ទោស នេះជាការពិត ហើយការបង្អាប់បន្តុះនេះឯងធ្វើឲ្យមានការឈឺចាប់ ហើយជាការកាន់តែខំធ្វើឲ្យរឹងប៉ឹងឡើង តែមិនមែនជាការមួយដែលគាត់ប្រកាន់យក ជាយកជ្រើសរើសនយោបាយរបស់ប្រទេសចិនទេ ព្រោះគាត់បានទទួលយកការអប់រំនៅសាលាខ្មែរ អ្វីដែលទាំងអស់ គោលគំនិតរបស់គាត់ភាគច្រើនជាខ្មែរ គ្រាន់តែថាអ្វីដែលជាផ្នែកប្រពៃណីទំនៀមទម្លាប់មានសល់ជាបែបចិន ។

មួយវិញទៀត ក្នុងកាលៈទេសៈនោះ ដោយសារខ្មែរយើងមានទំនាក់ទំនងជាមួយនឹងប្រទេសចិន ហើយដែលម៉ៅសេទុង គាត់បានធ្វើបដិវត្តន៍តាមបែបកុម្មុយនីស្តរបស់គាត់ទៅ បានជួយឲ្យប្រជាពលរដ្ឋក្រីក្របានកែនូវជីវភាពរស់នៅ ។ ទស្សនៈយល់ឃើញបែបនេះបានជាគាត់ជ្រើសរើសយកមាគ៌ានយោបាយរបស់ម៉ៅសេទុង មិនមែនដោយសារគាត់ជាជនជាតិចិនទេ តែដោយសារឃើញឧទាហរណ៍នេះ មាគ៌ានេះ ជាមាគ៌ាមួយដែលឲ្យគាត់បាន ដោយគាត់រំពឹងថាអាចនឹងទទួលបានជោគជ័យ ហើយនិងអាចកែប្រែជីវភាពរបស់ប្រជាពលរដ្ឋ ។

ថ្វីដ្បិតតែក្នុងនោះ មានជនជាតិចិនដែរ តែគាត់បានសម្តែងថា ចង់ឲ្យអ្នកក្រ ដោយភាគច្រើនសុទ្ធតែជាខ្មែរដែរនោះ ទទួលបាននូវការកែលម្អ ការកែប្រែជីវិភាពមកធូរធារ ។

ដូច្នេះ ឃើញថាពុំមានការឆ្លងតំណពូជន៍នូវឥរិយាបថ នូវគំនិតទេ។ តែផ្ទុយទៅវិញ ការឆ្លងនូវឥរិយាបថ គោលគំនិត និងប្រពៃណីមួយចំនួនទៅតាមការរស់នៅជាមួយគ្នា តែត១មកយើងធ្វើជាមួយគ្នា ។ សូមអរគុណ ។

**លោក ការ សាវុត្ថ៖**

សូមអរគុណ លោក លោកស្រីវេជ្ជបណ្ឌិត ។ ខ្ញុំអស់សំណួរហើយ សូមលោកប្រធានមេត្តាអនុញ្ញាតឲ្យលោកមេធាវីការពារអន្តជាតិមេត្តាសួរបន្ត ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីការពារអន្តរជាតិ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន ខ្ញុំមើលម៉ោងទៅឃើញថា ប្រហែលជាមិនសមស្របឲ្យខ្ញុំសួរសំណួរស្អែកព្រឹកទេ បើខ្ញុំមានពេលប្រហែលជាជិតសែសិបនាទីទៀត ថាតើគប្បីអនុវត្តនីតិវិធីដូចម្តេច?

[១៦:១៦:០៦]

**ប្រធានអង្គជំនុំ៖**

ដោយសារអង្គជំនុំជម្រះបានពិភាក្សាឃើញថា ការចំណាយពេលវេលារហូតដល់ទៅសែសិបមីនុតឬហាសិបមីនុតទៀតនោះ វាអាចវែងដែរ ហើយមានអាចប៉ះពាល់ដល់ការងារ ជាពិសេសអ្នកបកប្រែក៏ដូចជាអស់លោក លោកស្រីជាជំនាញដែរ ។ ដូច្នេះ អង្គជំនុំជម្រះសម្រេចដំណើរការសវនាការសម្រាប់ថ្ងៃនេះ គឺផ្អាកត្រឹមនេះ ហើយសវនាការនឹងលើកទៅបន្តទៅថ្ងៃស្អែកចាប់ពីម៉ោងប្រាំបួនព្រឹក ហើយដោយសារការសាកសួរចំពោះអ្នកជំនាញ លោកស្រី ហ្វ្រង់ស័រ ស៊ីរ៉ូនី ហ្កៀលបូ ហើយនិងលោក កាស៊ុនប៊ូណាត ដែលអង្គជំនុំជម្រះបានអញ្ជើញលោកមកធ្វើសេចក្តីថ្លែងការណ៍អំពីភាពជំនាញរបស់លោកពាក់ព័ន្ធជាមួយនឹងចិត្តសាស្ត្រជនជាប់ចោទនេះ មិនទាន់បានចប់ទេ ។ អ៊ីចឹង អង្គជំនុំជម្រះសូមអញ្ជើញលោក លោកស្រីមកកាន់សាលសវនាការ នៅថ្ងៃស្អែកចាប់ពីម៉ោងប្រាំបួនព្រឹកបន្តទៀង ហើយប្រហែលជាត្រូវចំណាយពេលមិនលើសពីមួយម៉ោងទេ ។

អនុរក្សមន្ទីរឃុំឃាំង ឲ្យនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ហើយឲ្យនាំគាត់មកកាន់សាលសវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួនព្រឹកជាកំណត់ ៕

*[សវនាការផ្អាកនៅម៉ោង១៦:១៧នាទី]*